ក្រសួងអប់រំយុវជន និង កីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការបញ្ជ្រាបការអប់រំ ពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជា ភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ

THE SITUATION OF INTEGRATING CITIZENSHIP EDUCATION ON UPPER SECONDARY ENGLISH'S CURRICULUM IN ODDOR MEANCHEY PROVINCE

**រស់ សុភាន់ / ROUS SOPHORN**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការបញ្ជ្រាបការអប់រំ ពលរដ្ឋពេញលេញនៅក្នុងកម្មវិធីសិក្សាមុខវិជ្ជា ភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ

THE SITUATION OF INTEGRATING CITIZENSHIP EDUCATION ON UPPER SECONDARY ENGLISH’S CURRICULUM IN ODDOR MEANCHEY PROVINCE

**រស់ សុភាន់ / ROUS SOPHORN**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២១**

**គ្រូណែនាំបង្គោលៈ លោក ម៉ន មុនិន្ទ**

**គ្រូណែនាំរងៈ បណ្ឌិត នួន វីរ៉ា**

# **សេចក្តីអះអាងរបស់បេក្ខជន**

ខ្ញុំបាទ សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវ ដែលមានចំណងជើងថា «**ស្ថានភាពនៃការបញ្ច្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០...

**ហត្ថលេខា**

**រស់ សុភាន់**

# លិខិតបញ្ជាក់

**លោក** **ម៉ន មុនិន្ទ** ជាគ្រូណែនាំបង្គោល

**បណ្ឌិត** **ឆ្វូច ទីរ៉ា** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **រស់ សុភាន់** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញនៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ**» ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ព.ស. ២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០...

...................................... ......................................

**ម៉ន មុនិន្ទ** **បណ្ឌិត ឆ្វូច ទីរ៉ា**

ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ នាយករងវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧២០៥ អយក. វ ១ន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | នី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | នី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វ៉ាំ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី ផ្កា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្ហាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ុំ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង ភិសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។/

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ដល់ខ្ញុំបាទបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ
ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដមមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកសាស្ត្រចារ្យដឹកនាំលោក **ម៉ន មុនិន្ទ** ដែលតែងតែចំណាយពេលវេលាមកពន្យល់ខ្ញុំបាទគ្រប់ជំហានទើបធ្វើឲ្យការស្រាជ្រាវរបស់ខ្ញុំនាពេលនេះទទួលបានជោគជ័យ និងភាពរលូន។ ជាមួយគ្នានេះដែរខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យដឹកនាំរង បណ្ឌិត **នួន ទីរ៉ា** និងមិត្តរួមជំនាន់ទី៨ទាំងអស់ដែលតែងតែផ្តល់ ជាគំនិតល្អៗ និងកម្លាំងចិត្ត តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទដើម្បីឲ្យការស្រាវជ្រាវ នេះមានភាពងាយស្រួល។

បន្ថែមពីនេះទៀតខ្ញុំសូមថ្លែងអំណរគុណដល់ ក្រុមគ្រួសាររបស់ខ្ញុំ ដែលបានផ្តល់នូវពេលវេលា ប្រាក់កាស និងតែងតែជំរុញ និងលើកទឹកចិត្តដើម្បីឲ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។ ខ្ញុំបាទក៏សូមថ្លែងអំណរអរគុណដល់លោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាអង់គ្លេសនៅវិទ្យាល័យទាំង៩ និងនាយកសាលាវិទ្យាល័យទាំងអស់នៅខេត្តឧត្តរមានជ័យ ព្រមទាំងប្រធានរដ្ឋបាលមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាពិសេសលោក ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលបានជួយសម្របសម្រួល និងអនុញ្ញាត្តិអោយខ្ញុំបាទបានធ្វើការប្រមូលពត៌មានស្រាវជ្រាវបានគ្រប់ជ្រុងជ្រោយ និងទទួលបានលទ្ធផលល្អ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជូនចំពោះ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ លោកគ្រូ អ្នកគ្រូ និងក្រុមគ្រួសាររបស់ខ្ញុំបាទ ឲ្យជួបតែពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មាតិកា


សេចក្តីអះអាងរបស់បេក្ខជន ........ ii

លិខិតបញ្ជាក់ ........ iii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ iv

សេចក្តីថ្លែងអំណរគុណ ........ vi

បញ្ជីតារាង ........ x

បញ្ជីអក្សរកាត់ ........ xii

មូលន័យសង្ខេប ........ xiii

Abstract ........ XV

**ជំពូក១ សេចក្តីផ្តើម ........ 1**

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 2

១.៣. គោលបំណងនៃការស្រាវជ្រាវ ........ 4

១.៤. សំណួរស្រាវជ្រាវ ........ 5

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ 5

១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ 6

១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ ........ 6

**ជំពូក២ រំលឹកទ្រឹស្តី ........ 7**

២.១. ស្ថានភាពទូទៅនៃខេត្តឧត្តរមានជ័យ ........ 7

២.១.១. ស្ថានភាពភូមិសាស្ត្រ ......7

២.១.២. ស្ថានភាពប្រជាសាស្ត្រ ......8

២.១.៣. វិស័យអប់រំ ......8

២.២. និយមន័យ ......9

២.៣. កម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ ......13

២.៤. ការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅ ក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សា ទុតិយភូមិ ......14

២.៥. សារៈសំខាន់នៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុង កម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ ......19

២.៦. បញ្ហាលំបាកនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេស ......21

**ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ** ......23

៣.១. គម្រោងវិភាគ ......23

៣.២. ការប្រមូលទិន្នន័យ ......24

៣.៣. ឧបករណ៍ស្រាវជ្រាវ ......24

៣.៤. ការជ្រើសរើសភាគសំណាក ......25

៣.៥. ការវិភាគទិន្នន័យ ......27

**ជំពូក៤ លទ្ធផលស្រាវជ្រាវ និង ការពិភាក្សា** ......28

៤.១. លទ្ធផលស្រាវជ្រាវសំណួរទី១ ......28

៤.២. លទ្ធផលស្រាវជ្រាវសំណួរទី២ ......35

៤.៣. ការពិភាក្សា ......54

**ជំពូក៥ សេចក្តីសន្និដ្ឋាន និង សំណូមពរ** ...... 56

៥.១. សេចក្តីសន្និដ្ឋាន ...... 56

៥. ២. សំណូមពរ ...... 58

ឧបសម្ព័ន្ធទី ១៖ កម្រងសំណួរ ...... 64

ឧបសម្ព័ន្ធទី ២៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ...... 69

ឧបសម្ព័ន្ធទី ៣៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជននិងកីឡាខេត្តឧត្តរមានជ័យ ...... 70

# បញ្ជីតារាង


តារាង៣.១៖ ចំនួនភាគសំណាក ភេទ និង ភាគរយ គ្រូបង្រៀនភាសាអង់គ្លេសនៅវិទ្យាល័យទាំង៩ ក្នុងខេត្តឧត្តរមានជ័យ.....26

តារាង៤.១៖ ប្រេកង់ និង ភាគរយ កម្រិតបណ្តុះបណ្តាលគ្រូតាមកម្រិតថ្នាក់ មុខវិជ្ជាភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិ (N=19).....29

តារាង៤.២៖ ចំនួនម៉ោងបង្រៀនតាមកម្រិតថ្នាក់ (N=19).....30

តារាង៤.៣៖ ចំនួនម៉ោង នៃការអនុវត្តកម្មវិធីសិក្សា ធៀបជាមួយនឹងចំនួនម៉ោងដែលគ្រូបង្រៀន ត្រូវការ(N=19).....30

តារាង៤.៤៖ មធ្យម គម្លាតស្តង់ដា នៃរយៈពេលបង្រៀន ១សប្តាហ៍ ក្នុង១កម្រិតថ្នាក់ធៀបជាមួយនឹង ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល (N=19).....31

តារាង៤.៥៖ មធ្យម គម្លាតស្តង់ដា នៃខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោលធៀបជាមួយ នឹង ពេលវេលាបង្រៀនក្នុង១ឆ្នាំសិក្សា (N=19).....32

តារាង៤.៦៖ មធ្យម គម្លាតស្តង់ដា នៃខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោលធៀបជាមួយនឹង សមត្ថភាពសិស្ស (N=19).....33

តារាង៤.៧៖ មធ្យម គម្លាតស្តង់ដា នៃខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោលធៀបជាមួយនឹង សមត្ថភាពគ្រូ (N=19).....33

តារាង៤.៨៖ មធ្យម គម្លាតស្តង់ដា នៃស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុង កម្មវិធីសិក្សា (N=19).....34

តារាង៤.៩៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមនៃខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាអង់គ្លេសធៀបជាមួយនឹង ពេលវេលាបង្រៀនក្នុង១ឆ្នាំសិក្សា (N=19).....37

តារាង៤.១០៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមនៃខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជា អង់គ្លេសធៀបជាមួយនឹងសមត្ថភាពរបស់សិស្ស (N=19).....38

តារាង៤.១១៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមនៃខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជា អង់គ្លេស ធៀបជាមួយនឹងសមត្ថភាពរបស់គ្រូបង្រៀន (N=19).....40

តារាង៤.១២៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនទំនាក់ទំនងរបស់សិស្ស (N=19)....41

តារាង៤.១៣៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនកិច្ចសហប្រតិបត្តិការរបស់សិស្ស (N=19)....43

តារាង៤.១៤៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិននៃភាពជាអ្នកដឹកនាំ ឬ ការតស៊ូមតិរបស់សិស្ស (N=19)....44

តារាង៤.១៥៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិននៃការគិតពិចារណា របស់សិស្ស (N=19)....45

តារាង៤.១៦៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិននៃការច្នៃប្រឌិត ឬគំនិតបង្កើតថ្មីរបស់សិស្ស (N=19)....47

តារាង៤.១៧៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិននៃការវិភាគ និងការដោះស្រាយបញ្ហារបស់សិស្ស (N=19)....48

តារាង៤.១៨៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនក្នុងការបន្តការសិក្សាពេញមួយជីវិតរបស់(N=19)....49

តារាង៤.១៩៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនក្នុងការសិក្សា និងការរស់នៅក្នុងបរិបទទំនើបនៃបច្ចេកវិទ្យា (N=19)....50

តារាង៤.២០៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនក្នុងការសិក្សាស្រាវជ្រាវ របស់សិស្ស (N=19)....51

តារាង៤.២១៖ មធ្យម គម្លាតស្តង់ដា នៃវិធីសាស្ត្រនានាក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសា (N=19)....52

# បញ្ជីអក្សរកាត់

DV: Dependent Variable

EFL: English as Foreign Language

ELT: English Language Teaching

F: Frequency

GDC: Global Development Citizenship

IV: Independent Variable

M: Mean

MoNE: Ministry of National Education

N: Number of respondents

SDG4: Sustainable Development Goal 4

Std: Standard Diviation

# មូលន័យសង្ខេប

ថ្មីៗនេះក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការនានា និងគោលនយោបាយថ្មីៗ ដើម្បីធានាបានថាក្រោយបញ្ចប់ការសិក្សាអប់រំ នៅមធ្យមសិក្សាចំណេះទូទៅ សិស្សគ្រប់រូបមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ឱ្យក្លាយជាពលរដ្ឋល្អ និងចេះរួមរស់ជាមួយគ្នា ប្រកបដោយភាពសុខដុមនៅក្នុងសង្គម និងដើម្បីអោយបុគ្គលគ្រប់រូបត្រូវទទួលបានការបណ្តុះបណ្តាលនូវវប្បធម៌សិក្សាពេញមួយជីវិត។ បញ្ញត្តិ ទាំងអស់នេះគឺជាធាតុចូលដ៏សំខាន់ៗ ដើម្បីអោយពលរដ្ឋគ្រប់រូបក្លាយជាពលរដ្ឋពេញលេញ។ ហើយដើម្បីសម្រេចបាននូវភាពជាពលរដ្ឋពេញលេញ ចាំបាច់ត្រូវតែមានការបញ្ជ្រាបការអប់រំពលរដ្ឋពេលលេញ ទៅក្នុងកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស។ ដោយមើលឃើញពីសារៈសំខាន់ និងភាពចាំបាច់នេះហើយបានជាអ្នកសិក្សាសម្រេចជ្រើសរើសប្រធានបទ "**ស្ថានភាពនៃការបញ្ជ្រាបការអប់រំ ពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ**" មកធ្វើការសិក្សា តាមរយៈគោលបំណងពីរសំខាន់ៗគឺទី១ សិក្សាពីស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ និងទី២ រកអោយឃើញនូវឧបសគ្គ ឬបញ្ហាទាំងឡាយណាដែលរាំងស្ទះដល់ដំណើរការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ និងដើម្បីរកដំណោះស្រាយអោយបានប្រសើរឡើង។

ការសិក្សាស្រាវជ្រាវនេះបានប្រព្រឹត្តទៅនៅខេត្តឧត្តរមានជ័យ ដោយផ្តោតលើវិទ្យាល័យគោលដៅទាំង៩ មាន៤ស្រុក និងក្រុង១ ដោយជ្រើសរើសយកតែគ្រូបង្រៀនមុខវិជ្ជាអង់គ្លេសដែលបង្រៀននៅ វិទ្យាល័យទាំងអស់ដើម្បីបំពេញកម្រងសំណួរស្រាវជ្រាវបែបបរិមាណវិស័យ។ គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសដែលបានចូលរួមក្នុងការសិក្សាសរុបមានចំនួន១៩នាក់ ក្នុងនោះស្រី៦នាក់។ ចំណែកកម្រងសំណួរចែកចេញជាពីរផ្នែក គឺផ្នែកទី១ និយាយពីពណ៌មានទូទៅរបស់លោកគ្រូ-អ្នកគ្រូ និងផ្នែកទី២ និយាយអំពីស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅខេត្តឧត្តរមានជ័យ និងបង្ហាញពីបញ្ហាប្រឈមទៅតាមគោលបំណងនៃសំណួរស្រាវជ្រាវនីមួយៗ។ បន្ទាប់មកអ្នកស្រាវជ្រាវយកចម្លើយដែលទទួលបានពីកម្រងសំណួរទាំងអស់នោះ មកធ្វើការវិភាគតាមកម្មវិធី SPSS Statistics និងបង្កើតជាតារាងតាមរយៈ កម្មវិធី Ms. Excel ដើម្បីបកស្រាយពន្យល់អំពីលទ្ធផលសិក្សាតាមរយៈពិន្ទុ មធ្យម គម្លាតស្តង់ដា ប្រេកង់ និង ភាគរយនៃលទ្ធផលស្រាវជ្រាវតាមបែបបរិមាណវិស័យ។

តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា ការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ ទទួលបានលទ្ធផលមធ្យមដោយមាន មធ្យមសរុប២.៩០ (M=2.90) និងមានគម្លាតស្តង់ដា០.៨៦ (Std=0.86) [Oxford និង

Burry-Stock (1995) - មធ្យម កម្រិតខ្ពស់ (M=3.50 ឡើង) កម្រិតមធ្យម (M=2.50 – 3.49) និង កម្រិតទាប (M=2.49 ចុះ)]។ យោងទៅលើលទ្ធផលនេះយើងអាចសន្និដ្ឋានបានថាការបញ្រ្ជាបការអប់រំពលរដ្ឋពេញលេញនៅមានបញ្ហាប្រឈមច្រើនដូចជាៈ កត្តាសិស្ស កត្តាគ្រូបង្រៀន កត្តាសៀវភៅសិក្សាគោល និងកត្តាកម្មវិធីសិក្សា។ ដូចនេះដើម្បីអោយការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមានភាពប្រសើរឡើងត្រូវ មានកត្តាជាច្រើនដូចជាៈ ផ្តល់ពត៌មានត្រឡប់ទៅដល់សិស្ស ព្យាយាមនូវវិធីសាស្ត្រថ្មី និងលើកទឹកចិត្តសិស្សអោយខិតខំសិក្សារៀនសូត្រ ធ្វើបច្ចុប្បន្នភាព ឬបង្កើតសៀវភៅសិក្សាគោលថ្មីទាក់ទងនឹងការរស់នៅក្នុងបរិបទទំនើប បន្ថែមម៉ោងសិក្សា ការបង្រៀន ការរៀន ការអនុវត្ត និងកិច្ចការស្រាវជ្រាវនានាត្រូវមាននៅក្នុងសៀវភៅសិក្សាគោល ការបង្រៀនត្រូវតែបញ្ចូលឬជាប់ទាក់ទងទៅនឹងបរិបទនៃការរស់នៅបច្ចុប្បន្នរបស់សិស្ស គ្រូបង្រៀនត្រូវធ្វើជាគំរូល្អសម្រាប់សិស្សានុសិស្ស បន្ថែមមេរៀន កិច្ចការ និងលំហាត់ទាក់ទងទៅនឹងការអប់រំពលរដ្ឋពេញលេញ ផ្តល់ឱកាសដល់គ្រូបង្រៀនដើម្បីទទួលបានចំណេះដឹងថ្មី និងវិធីសាស្ត្របង្រៀនថ្មីតាមរយៈវគ្គបណ្តុះបណ្តាលនានាទាំងក្នុង និងក្រៅប្រទេសអំពីការអប់រំពលរដ្ឋពេញលេញ ដាក់មុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាសិក្សាគោលមានរបបពិន្ទុដូចមុខវិជ្ជាដទៃ (មិនមែនជាពិន្ទុថែម) ជាពិសេសក្នុងការប្រឡងសញ្ញាបត្រថ្នាក់ជាតិ។ គ្រប់សាលារៀនទាំងអស់ត្រូវតែមានការប្រកួតប្រជែងផ្នែកភាសាអង់គ្លេសតាមរយៈ ការសរសេរអត្ថបទ ឬការការពារនានាដើម្បីអោយសិស្សក្លាយទៅជាពលរដ្ឋពេញលេញនាថ្ងៃអនាគត។

# Abstract

The Ministry of Education, Youth, and Sports Recently, sets up new approaches and education policies to ensure that after finished high school, all students must have enough knowledge, skills, good attitude, fitness, living in harmony together, to be good citizens, and to make all people recieve training on lifelong learning culture. These concepts are important input that make people to become citizenship. To achieve this, must be integrate citizenship education in to general and techniques education. Based on these importance and necessaries, the researcher decided to study the topic of **“The situation of integrating citizenship education on upper secondary English’s curriculum in Odor Meanchey province**” by two main objectives; firstly, the study focus on the situation of integrating citizenship education into upper secondary English’s curriculum in Oddor Meanchey province, and secondly, to find to any problems affected on integrating citizenship education into upper secondary English’s curriculum in Oddor Meanchey Province and to find solution to any problems to be better.

This research conducted in Oddor Meanchey province, taking 9 high schools of 4 districts and a town by choosing all 19 high school English’s teachers, there’re 6 females. The questionnaire divided into two parts; first, focus on general information, and the second focus on situation of integrating citizenship education on upper secondary English’s curriculum in Oddor Meanchey province and finding solution to any problems of each question’s objectives. Then the researcher analyzed the data from respondents by SPSS Statistics, and creating table on Ms. Excel and made explanation by means, standard deviations, frequencies and percentage of quantitative data.

The result show that integrating citizenship education on English’s curriculum in Oddor Meanchey province result as average, point by Mean 2.90 and standard deviation 0.86 [Oxford and Burry-Stock (1995), mean; high 3.50 and over, average 2.50 – 3.49, and low 2.49 and under]. According to this result, there’re many problems in integrating citizenship such as student’s factors, teachers, textbooks, and the curriculum factors. To prove citizenship education better must follow such principles as; feedback students, try new teaching strategies and persuade students to study hard, update new textbooks of English language with new context of student’s lives base on new technology, extra teaching times, teaching, learning, practicing, and researching base on textbooks, teaching must include real situation of student’s lives, teachers must be a good example of students, extra classwork, homework, and exercise base on citizenship education. Give teachers opportunity of getting new knowledge and teaching strategies base on vocational trainings both outside and inside about citizenship education. Make base English subject as other subjects (non-additional score), especially for national exams. All schools have to make competition of English language by writing and debating to improve student’s ability to be good citizenship in the future.

# ជំពូក១

# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាសតវត្សរ៍ទី២១ បានឈានដល់ដំណាក់កាលថ្មីមួយនៃការអភិវឌ្ឍវិស័យអប់រំ ឆ្លើយតបទៅនឹងបរិបទនៅក្នុងតំបន់ និងសាកលលោកមានមហិច្ឆិតាធំទូលាយជាងមុន ដោយបានអនុវត្តគោលនយោបាយអប់រំថ្មី ដែលធានាឱ្យការអប់រំ មានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ក្នុងក្របខណ្ឌធំទូលាយលើគ្រប់មុខជំនាញ និងគ្រប់កម្រិតនៃការអប់រំដើម្បីឱ្យកម្ពុជាឈានទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹម ឆ្នាំ ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ សេចក្តីប្រកាសទីក្រុង អ៊ីន ឈ័ន សាធារណៈរដ្ឋកូរ៉េ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៥ ក្នុងវេទិកាអប់រំពិភពលោក គឺជាចំណុចចាប់ផ្តើមនៃការបន្តចក្ខុវិស័យអប់រំជាសកលឆ្នាំ២០៣០ ស្របជាមួយគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ (SDG4) ដោយផ្តោតលើគុណភាពអប់រំ និងមានក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញជាស្នូល។ ដើម្បីធានាឱ្យមានការអប់រំជាសកលនៅឆ្នាំ២០៣០ ក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញដើរតួនាទីយ៉ាងសំខាន់ដោយមានកម្មវិធីសិក្សាលម្អិតគ្រប់ជ្រុងជ្រោយដើម្បីធានាឱ្យពលរដ្ឋគ្រប់រូប មានចំណេះសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញជាពលរដ្ឋសកល។ ដើម្បីឱ្យពលរដ្ឋកម្ពុជាគ្រប់រូបមានគុណភាពអប់រំជាពលរដ្ឋសកល ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញបានដាក់ចេញនូវកម្មវិធីសិក្សាជាច្រើន និងគ្រប់លក្ខខណ្ឌ ដើម្បីឱ្យការអនុវត្តកម្មវិធីសិក្សាមានប្រសិទ្ធភាព ក្នុងនោះមុខវិជ្ជា ភាសាអង់គ្លេស បានដើរតួយ៉ាងសំខាន់ និងជាគន្លឹះដែលអាចឱ្យអ្នកសិក្សាគ្រប់រូប មានលទ្ធភាព អភិវឌ្ឍចំណេះជំនាញ និងការសិក្សាពេញមួយជីវិតជាសកលបាន ដោយប្រើប្រាស់ភាសាអង់គ្លេស ជាគោលក្នុងការសិក្សា ការស្រាវជ្រាវ ការទំនាក់ទំនង និងការប្រើប្រាស់សម្ភារៈបច្ចេកទេស គ្រឿងអេឡិច ត្រូនិចជាដើម។

អស់រយៈពេលជាច្រើនឆ្នាំ កម្មវិធីសិក្សានៅបណ្តាប្រទេសជាច្រើនបានដាក់បញ្ចូលកម្មវិធីសិក្សា

អប់រំសាធារណៈ ដែលផ្ដោតសំខាន់ទៅលើចំណេះដឹងនិងជំនាញដែលបានបង្រៀន មានលក្ខណៈឆ្លុះបញ្ចាំងពីស្ថានភាពរស់នៅប្រចាំថ្ងៃ និងពីបញ្ហាស្មុគស្មាញនៃពិភពទំនើប (Young, Commins, and Kington, 2002)។ ការបង្រៀនផ្នែកវិទ្យាសាស្រ្តសង្គមជាមធ្យោបាយដើម្បីឈានទៅដល់ការអភិវឌ្ឍផ្នត់គំនិតដែលឆ្លុះបញ្ចាំងពីបញ្ហាជាក់ស្តែងនៃសង្គម ជាយុទ្ធសាស្រ្តចូលរួមនៅក្នុងរបបលទ្ធិប្រជាធិបតេយ្យ។ តាមការរកឃើញថ្មីៗនេះ ការអប់រំពលរដ្ឋពេញលេញបានក្លាយជាបញ្ញត្តិនៃការដាក់បញ្ច្រាបគោលបំណងអប់រំផ្សេងៗជាច្រើន ដែលមានគោលដៅរួមក្នុងការដាក់បញ្ចូលជាមជ្ឈមណ្ឌលសិក្សាអប់រំសកល(Dewey, 2018) ។

ក្រសួងអប់រំយុវជន និងកីឡា បានដាក់បញ្ចូលការសិក្សាមុខវិជ្ជាភាសាអង់គ្លេសជាផ្លូវការទៅក្នុងកម្មវិធីសិក្សាមធ្យមសិក្សាក្នុងឆ្នាំ១៩៨៩ និងមានការកែប្រែកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន ដែលកម្មវិធីសិក្សាបានអនុវត្តចាប់ពីថ្នាក់បឋមសិក្សា (ថ្នាក់ទី៤)ឡើង និងបានផលិតសៀវភៅសិក្សាគោលថ្មី (ឆ្នាំ២០១៤) នៅបឋមសិក្សា និងនៅកម្រិតបន្តបន្ទាប់រហូតដល់ ថ្នាក់ទី១២ ដើម្បីឱ្យកម្មវិធីសិក្សាមានកម្រិតស្តង់ដាស្របតាមកម្មវិធីសិក្សា ក្នុងបរិបទសកលលោកជាផ្លូវ ដែលអាចឱ្យយុវជនមាន ចំណេះដឹង និងបំណិនផ្នែកភាសាអង់គ្លេសអាចប្រើប្រាស់ និងមានសមត្ថភាព បំណិនដែលអាចឱ្យពួកគេអាចបន្តការសិក្សាពេញមួយជីវិតរបស់ពួកគេបាន (Vira, 2002)។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យពលរដ្ឋគ្រប់រូបមានលទ្ធភាពសិក្សាពេញមួយជីវិត និងក្លាយជាពលរដ្ឋសកល ពិភពលោកបានខិតខំរិះរកគ្រប់មធ្យោបាយ តាមរយៈសាកលភាវូបនីយកម្មលើគ្រប់វិស័យ ជាពិសេសផ្នែកអប់រំ ទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ វប្បធម៌និងសេដ្ឋកិច្ចជាដើម។ ភាសាអង់គ្លេសគឺជា ដើមចមក្នុងការសម្រេចជោគជ័យនៅក្នុងសាកលភាវូបនីយកម្មលើគ្រប់វិស័យ ដោយសារប្រើប្រាស់ភាសាអង់គ្លេសជាយាន្ត។ ដូច្នេះពលរដ្ឋគ្រប់រូបត្រូវចេះភាសាអង់គ្លេសដើម្បីជាមូលដ្ឋានក្នុងការស្វែងយល់ប្រើប្រាស់ និងការសិក្សានានាបានយ៉ាងទូលំទូលាយ ជាពិសេសប្រទេសដែលមិនប្រើភាសាអង់គ្លេស ឬប្រទេសដែលយកភាសាអង់គ្លេសជាភាសាទីពីរ ដូចជាកម្ពុជាជាដើម។

តាមរយៈសេចក្តីណែនាំស្តីពីការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សារបស់ក្រសួងអប់រំ ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧ ក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាចំណេះទូទៅ ពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ដើម្បីផ្តល់ឱកាសឲ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេស សម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។ ក្នុងគោលបំណងបង្កើនរយៈពេលសិក្សាភាសាបរទេសនៅតាមសាលាឲ្យបានគ្រប់កម្រិតដើម្បីពង្រឹង និងបង្កើនសមត្ថភាពសិស្សានុសិស្សផ្នែកភាសាអង់គ្លេសឲ្យកាន់តែមាន សក្តានុពល គឺ ៣ កម្រិតនៅបឋមសិក្សា ៣ កម្រិតនៅអនុវិទ្យាល័យ និង ៣ កម្រិតទៀតនៅវិទ្យាល័យ និងដើម្បី បន្តការសិក្សាពេញមួយជីវិត។

តាមការសិក្សារបស់ Sithika (2019) បានបង្ហាញឱ្យឃើញថា ការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សានៅកម្ពុជា ស្ថិតនៅក្នុងការពិចារណា ត្រូវធ្វើការពិនិត្យ និង កែតម្រូវឱ្យប្រសើរឡើងវិញដោយសារនៅមានបញ្ហាមួយចំនួនដូចជា៖ (១) គ្រូមួយចំនួនធំនៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ទៅតាមកម្រិតសញ្ញាបត្រជាគ្រូបង្រៀនភាសាអង់គ្លេស មានន័យថាក្រោយពីពួកគាត់បានរៀនចប់ថ្នាក់ទី១២ ពួកគាត់បានក្លាយជាគ្រូភាសា អង់គ្លេស តាមរយៈការប្រឡងចូលគ្រូ ដោយទទួលការបណ្តុះបណ្តាលរយៈពេលពីរឆ្នាំ (គ្រូកម្រិតមូលដ្ឋាន) គឺមិនទាន់មានចំណេះដឹងគ្រប់គ្រាន់ក្នុងការបង្រៀនសិស្សនោះទេ ដោយសារការ សិក្សានៅសាលាបណ្តុះបណ្តាលគ្រូ ត្រូវរៀនច្រើនមុខវិជ្ជា ហើយចំណេះដឹងមូលដ្ឋានរបស់ពួក គាត់គឺមានកម្រិត ដូច្នេះការបង្រៀនភាសាអង់គ្លេសរបស់គ្រូភាគច្រើនគឺ មិនទាន់មានសមត្ថភាព ឆ្លើយតបទៅនឹងគុណភាពអប់រំនោះទេ (២) ការបង្រៀន និងរៀនភាសាអង់គ្លេសនៅអនុវិទ្យាល័យនិងវិទ្យាល័យ ត្រូវបានអនុវត្តដោយប្រើ ពេលវេលាសិក្សាតិចពេកក្នុង១សប្តាហ៍ ជាហេតុធ្វើឱ្យគ្រូបង្រៀនមិនអាចអនុវត្តតាមកម្មវិធីសិក្សាបាន និងមិនអាចប្រើវិធីសាស្ត្រច្រើនក្នុងការបង្រៀនឱ្យបានល្អ (៣) សិស្សភាគច្រើនខ្វះជំនាញស្តាប់ និងនិយាយ ដែលមិនអាចអនុវត្តការស្តាប់ ការសម្តែងនានា និងមិនអាចរៀនទាន់កម្មវិធីសិក្សាមានន័យថាខ្លឹមសារនៃមេរៀនក្នុងសៀវភៅសិក្សាគោលនិង ចំណេះដឹងមូលដ្ឋានរបស់សិស្សមិនស៊ីគ្នា ខ្លឹមសារមេរៀនច្រើនមានកម្រិតខ្ពស់ តែសិស្សមានចំណេះដឹងទាប។

ដោយយោងទៅលើស្ថានភាពនៃការសិក្សាខាងលើ ធ្វើអោយយើងអាចវាយតម្លៃបានថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិនៅមានបញ្ហា និងមិនទាន់ទទួលបានគុណភាពល្អនៅឡើយ ហើយការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញគឺអាស្រ័យទៅលើគុណភាពនៃមុខវិជ្ជាភាសាអង់គ្លេសជាកត្តាសំខាន់។ រីឯការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅ កម្រិតមធ្យមសិក្សាទុតិយភូមិ នៅមានបញ្ហាប្រឈមប្រហាក់ប្រហែល នឹងករណីសិក្សាខាងលើដែរដោយសារតែភាគច្រើននៃកម្មវិធីសិក្សាគឺប្រហាក់ប្រហែលគ្នា ហើយស្ថិតនៅក្នុងមជ្ឈដ្ឋាន និងសាលាតែមួយ រវាងបឋមភូមិ និង ទុតិយភូមិ ខុសម៉ោងសិក្សាគ្នាតែបន្តិចបន្តួចតែប៉ុណ្ណោះ គឺនៅកម្រិតមធ្យមសិក្សាបឋមភូមិ ពីថ្នាក់ទី៧ដល់ ទី៩ ត្រូវសិក្សា ៤ម៉ោង ក្នុង១សប្តាហ៍ ចំណែកឯនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅថ្នាក់ទី១០ មានរយៈពេលសិក្សា ៤ម៉ោងក្នុង ១សប្តាហ៍ ដូចបឋមភូមិដែរ តែនៅថ្នាក់ទី១១ និង ថ្នាក់ទី១២ គឺមានពេលវេលាតិចជាង បឋមភូមិទៅទៀតគឺត្រូវសិក្សាតែ ២ម៉ោងក្នុង១សប្តាហ៍តែប៉ុណ្ណោះ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១០) ដូច្នេះមានន័យថានៅកម្រិតមធ្យមសិក្សាទុតិយភូមិអាចមានបញ្ហាច្រើនជាងកម្រិតបឋមភូមិទៅទៀតដោយសារតែការអនុវត្តកម្មវិធីសិក្សាមានរយៈពេល តិចពេកជាពិសេសថ្នាក់ទី១១ និងថ្នាក់ទី១២។

ហេតុនេះ ក្នុងឆ្នាំសិក្សាថ្មីនេះ អ្នកសិក្សានឹងធ្វើការសិក្សាទៅលើស្ថានភាពទាំងស្រុងនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដោយយកខេត្តឧត្តរមានជ័យជាគោលដៅសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីបានដឹងអំពីស្ថានភាពជាក់ស្តែងថ្មីៗ ពីបញ្ហាប្រឈមនានាដែលកើតមាន និងដើម្បីស្វែងរកដំណោះស្រាយឱ្យបានល្អប្រសើរសម្រាប់ពេលបច្ចុប្បន្ន និងទៅអនាគត។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះ ផ្តោតលើការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដោយមានគោលបំណងសំខាន់ៗពីរគឺ៖

ក. សិក្សាពីស្ថានភាពនៃការការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជា

ភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅក្នុងខេត្តឧត្តរមានជ័យ។

ខ. ស្វែងយល់ពីបញ្ហាប្រឈមនានា ដែលកើតមានលើការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅក្នុងខេត្តឧត្តរមានជ័យ។

## ១.៤. សំណួរស្រាវជ្រាវ

ក. តើការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ មានស្ថានភាពបែបណា?

ខ. តើអ្វីខ្លះជាបញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ណាស់ ក្នុងការចូលរួមចំណែក លើកកម្ពស់ គុណភាពនៃកាបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាចំណេះទូទៅដើម្បីឱ្យពលរដ្ឋគ្រប់រូបមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការចាប់យកឱកាសនានានៅក្នុងសង្គម ជាពិសេសអាចមានសមត្ថភាពក្នុងការសិក្សាពេញមួយជីវិត ដែលជាគន្លឹះយ៉ាងសំខាន់ដើម្បីឱ្យពលរដ្ឋកម្ពុជាគ្រប់រូបក្លាយជាពលរដ្ឋសកល និងមានសេដ្ឋកិច្ចរីចម្រើនជាប្រទេសអភិវឌ្ឍ ដែលមានចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣០ និងមានចំណូលកម្រិតខ្ពស់ត្រឹមឆ្នាំ២០៥០។

ក្រោយបញ្ចប់ការសិក្សា អ្នកសិក្សានឹងទទួលបានទិន្នន័យជាក់លាក់ ទាក់ទងនឹងប្រធានបទស្រាវជ្រាវដើម្បីជាពត៌មាន សម្រាប់អ្នកគ្រប់គ្រងកម្មវិធីសិក្សាអប់រំចំណេះទូទៅ អាចធ្វើការកែលម្អនូវ ចំណុចខ្វះខាត និងសម្រួលនូវបញ្ហារាំងស្ទះនានាដល់ដំណើរការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឱ្យមានលក្ខណៈស្តង់ដាឈានទៅកម្រិតពីភពលោក និងដើម្បីអាចបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញបានល្អប្រសើរទៅថ្ងៃអានគត។

## ១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាមានភាពលម្អិត និងស៊ីជម្រៅ អ្នកស្រាវជ្រាវផ្ដោតការសិក្សាតែទៅលើមុខវិជ្ជាភាសាអង់គ្លេសក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញនៅកម្រិតមធ្យមសិក្សាទុតិយភូមិប៉ុណ្ណោះ ដោយមិនផ្ដោតលើ មុខវិជ្ជាបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញដទៃទៀតនោះទេ។ ក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវនឹងសិក្សាស្រាវជ្រាវ ជាមួយគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៃវិទ្យាល័យទាំង៩ ក្នុងខេត្តឧត្តរមានជ័យ។

## ១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូកធំៗ៖

**ជំពូក១ សេចក្តីផ្តើម៖** ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង និងដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ។

**ជំពូក២ រំលឹកទ្រឹស្តី៖** នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងប្រមូលទ្រឹស្តី និងឯកសារនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី។

**ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ៖** ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវគម្រោងវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ វិធីជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។

**ជំពូក៤ លទ្ធផលការស្រាវជ្រាវ និងការពិភាក្សា៖** នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវ នឹងយកទិន្នន័យបានវិភាគមកធ្វើការបកស្រាយ និងពិភាក្សា ដើម្បីរកឲ្យឃើញនូវចំណុចល្អ និងចំណុច ដែលត្រូវធ្វើការកែលម្អពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ។

**ជំពូក៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានធ្វើការបកស្រាយនិងវិភាគព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនក្នុងបំណងចូលរួមចំណែក ធ្វើឲ្យស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ កាន់តែមានភាពល្អប្រសើរឡើង

# ជំពូក២

# រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះផ្តោតសំខាន់ទៅលើបញ្ញត្តិនៃពាក្យគន្លឹះ សារៈសំខាន់ និងភាពលំបាកនៃការបញ្ច្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស និងខ្លឹមសារដែលទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវ ផ្សាភ្ជាប់ជាមួយនឹងស្ថានភាពទូទៅនៅខេត្តឧត្តរមានជ័យ។

## ២.១. ស្ថានភាពទូទៅនៃខេត្តឧត្តរមានជ័យ

### ២.១.១. ស្ថានភាពភូមិសាស្ត្រ

ខេត្តឧត្តរមានជ័យជាខេត្តមួយស្ថិតនៅភាគខាងជើងឆៀងខាងលិច នៃប្រទេសកម្ពុជា ដែលមានចម្ងាយ៤៤៧គីឡូម៉ែត្រពីរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ៦ កាត់តាមខេត្តកំពង់ចាម កំពង់ធំ សៀមរាប និងបត់ស្តាំតាមផ្លូវជាតិលេខ៦៨ ពីស្រុកក្រឡាញ់ខេត្តសៀមរាប មកដល់ខេត្តឧត្តរមានជ័យ និង ផ្លូវមួយទៀតមានចម្ងាយ៤៦៩គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៥ ឆ្លងកាត់ខេត្តកណ្តាល កំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ។ ខេត្តឧត្តរមានជ័យបានបង្កើតឡើងជាបីដំណាក់កាលលើកទី១ នៅឆ្នាំ១៩៦៤ តាមរាជក្រមលេខ១៩៤ ប.រ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៦៤។ បង្កើតលើកទី២ ដោយព្រះរាជក្រមលេខ ២៨៤ ប.រ ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ១៩៦៦ នៅសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះបាទនរោត្តមសីហនុ ប៉ុន្តែក្រោយឆ្នាំ ១៩៧០ សង្គ្រាមបានឆាបឆេះឡើង រាល់រចនាសម្ព័នរដ្ឋបាលត្រូវបានលើកទីតាំងដាក់នៅខេត្តសៀមរាប ក្រោយមកនៅឆ្នាំ១៩៩៥ ខេត្តឧត្តរមានជ័យត្រូវបានបង្កើតជាលើកទី៣ យោងព្រះរាជក្រឹត្យលេខនស/រកត/០១៩៥/០៧ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥ ខេត្តនេះត្រូវបានផ្តាច់ចេញពីខេត្តសៀមរៀប នៅពេលនោះរាល់រចនាសម្ព័នពុំទាន់បានដំណើរការនៅឡើយ លុះដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្ថិតក្រោមអធិបតីភាពឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានប្រកាសដាក់អោយដំណើរការការងាររដ្ឋបាលជាផ្លូវការ។ ខេត្តនេះមានព្រំប្រទល់ ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយ

មានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប ខាងជើងជាប់ជាមួយខេត្តចំនួន៣របស់ប្រទេសថៃ គឺខេត្តសុរិន្ទ ខេត្តបុរីរ៉ាំ និង ខេត្តស៊ីសាកេត មានប្រវែង២២៤គីឡូម៉ែត្រតាមបណ្តោយ ជួរភ្នំដងរែក។ ខេត្តឧត្តរមានជ័យមានផ្ទៃដីសរុប៦.៨៤០,៩១ គ.ម$^{២}$ មានក្រុង០១ និង ស្រុកចំនួន០៤ សង្កាត់០៥ ឃុំ១៩ និង ភូមិចំនួន៣០៤ ។ ខេត្តនេះមានច្រកទ្វារអន្តរជាតិចំនួនបី គឺច្រកជុបគគីរ នៅស្រុកបន្ទាយអំពិល ច្រកអូរស្មាច់ នៅក្រុងសំរោង និងច្រកជាំស្រង៉ាមនៅស្រុកអន្លង់វែង។

### ២.១.២. ស្ថានភាពប្រជាសាស្ត្រ

ខេត្តឧត្តរមានជ័យមានប្រជាជនសរុប២៦៤៩៦៩នាក់ ស្រី១៣១៤៩៦នាក់ មានចំនួនគ្រួសារសរុប៦៤៦៥៦គ្រួសារ មានស្ត្រីជាមេគ្រួសារស្មើនឹង៩.៧២% ប្រជាជនអាយុក្រោម១៨ឆ្នាំ មាន ១០៣៦២៧នាក់ អាយុពី១៨ឆ្នាំដល់៦០ឆ្នាំមាន១៤៥៥៥១នាក់ និងអាយុ៦០ឡើងមាន១៥៧៩១នាក់ ។ ជនជាតិដើមភាគតិច ជនជាតិគួយ មាន៧៣គ្រួសារ មានប្រជាជនសរុប៣៨៤នាក់ ជនជាតិចារ៉ាយ ២គ្រួសារស្មើនឹង៤នាក់ ជនជាតិការ៉េត ២គ្រួសារស្មើនឹង២នាក់ និង ជនជាតិផ្សេងៗ មាន១គ្រួសារមានសមាជិក២នាក់។ សេដ្ឋកិច្ចចំបងរបស់ប្រជាជនក្នុងខេត្តឧត្តរមានជ័យរួមមាន៖ ផ្នែកកសិកម្ម៧៩.២% ផ្នែកសិប្បកម្ម០.៥% ផ្នែកសេវាកម្មមាន២០.៣% (ឯកសារពត៌មានស្ថានភាពស្តីពី សេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០២១ ខេត្តឧត្តរមានជ័យ)។

### ២.១.៣. វិស័យអប់រំ

ខេត្តឧត្តរមានជ័យមានសាលារៀនសរុប៣៦៤សាលា ស្មើនឹង២១៥៣ថ្នាក់ មានចំនួនសិស្សសរុប៥៦៣៤២នាក់ ស្រី២៧៨២៣នាក់ និងមានបុគ្គលិកសរុប១៩៣៤នាក់ ស្រី៨៣៣នាក់។ មត្តេយ្យសិក្សាមាន១០៧សលា ស្មើនឹង១៣១ថ្នាក់ មានសិស្សសរុប ៣៨៩៤នាក់ ស្រី ១៩៦៥នាក់ និង បុគ្គលិកសរុប៩៥នាក់ ស្រី៩០នាក់។ សាលាបឋមសិក្សាមាន២១៨សាលា ស្មើនឹង១៦៦៨ថ្នាក់ មានសិស្សសរុប ៣៧០៤១នាក់ ស្រី១៧៦៨៣នាក់ និងមានបុគ្គលិកសរុប១២៤៣នាក់ ស្រី៥៣៩នាក់។ សាលាអនុវិទ្យាល័យមាន៣០សាលា ស្មើនឹង១៤០ថ្នាក់ មានសិស្សសរុប៦៣៥៧នាក់ ស្រី៣៣៩៥នាក់ និងមានបុគ្គលិក

សរុប២៣៦នាក់ ស្រី៨០នាក់។ វិទ្យាល័យមាន៩សាលា ស្មើនឹង២១៨ថ្នាក់ មានសិស្សសរុប៩០៥០នាក់ ស្រី៤៧៨០នាក់ និង មានបុគ្គលិកសរុប៣៦០នាក់ ស្រី១២៤នាក់។ មន្ទីរអប់រំ យុវជន និង កីឡាខេត្ត មានបុគ្គលិកសរុប៥១នាក់ ស្រី១២នាក់។

## ២.២. និយមន័យ

"ស្ថានភាព" ទីតាំងនៅពិតប្រាកដ អាកប្បកិរិយា, ហេតុភេទ, ដំណើរទំនង, បែបបទ, ដើងការ, ដំណើរការដែលប្រព្រឹត្តិទៅ, ជំហរ, ស្ថានការណ៍ (ជួន ណាត, ១៩៦៧)។

តាមវចនានុក្រុម Cambridge Advanced Dictionary (2008) "ការអនុវត្ត" គឺជាសកម្មភាពនៃការចាប់ផ្តើមក្នុងគម្រោងការ ឬប្រព័ន្ធប្រតិបត្តិណាមួយ។ ការអនុវត្តគឺជាការលាតត្រដាង ឬការដាក់បង្ហាញនូវកម្មវិធី ឬ ជាការប្រតិបត្តិផែនការ គំនិតគំរូ ការបង្កើតថ្មី ស្តង់ដា ឬ បទដ្ឋានច្បាប់នានា (Wikipedia, 2009)។

"ការបញ្ជ្រាប" គឺជាការសម្តែង ការសម្របសម្រួល ឬជាការដាក់បញ្ចូលទៅក្នុងចនាសម្ព័នណាមួយ ឬទៅជាជំពូក ឬក្រុមណាមួយទាំងស្រុង (Merriam, 1828)។ ឧទាហរណ៍៖ សេចក្តីល្អ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ដូច្នេះអ្នកត្រូវតែរកវិធីសាស្ត្រ ធ្វើបែបណាដើម្បីបញ្ជ្រាបចំណែកដ៏តូច មួយទៅក្នុងធន្ទះនៃការរស់នៅប្រចាំថ្ងៃ (Astrologers, 2020)។

"ការអប់រំ" តាម WIKIPEDIA (2021) ការអប់រំគឺជាដំណើរការនៃការសម្របសម្រួល ការសិក្សារៀនសូត្រ ឬជាការទទួលយកនូវចំណេះដឹង ជំនាញ តម្លៃ សីលធម៌ ជំនឿ និងទំនៀមទម្លាប់។ ការអប់រំត្រូវបានធ្វើឡើងតាមរយៈការបង្រៀន កាបណ្តុះបណ្តាល ការដំណាលរឿង ការពិភាក្សា និងការសិក្សាស្រាវជ្រាវផ្ទាល់។

"ការអប់រំពលរដ្ឋពេញលេញ" មានន័យថាគឺជាដំណើរការនៃការសិក្សារៀនសូត្រ ឬជាការទទួលយកចំណេះដឹង ជំនាញ តម្លៃ សីលធម៌ និងទំនៀមទម្លាប់ ដើម្បីឱ្យពលរដ្ឋមានកាយសម្បទា ចំណេះសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញ ជាពលរដ្ឋដែលមានទំនួលខុសត្រូវខ្ពស់ សមា

ហារន្តកម្មក្នុងតំបន់ និងពិភពលោកជាពល (ក្រសួងអប់រំយុវជន និង កីឡា, ២០១៥)។ ការអប់រំពលរដ្ឋពេញលេញ គឺមានភាពចាំបាច់យ៉ាងខ្លាំងសម្រាប់សិស្សានុសិស្សគ្រប់រូប ដោយវាបានជួយឱ្យសិស្សបានយល់គ្រប់ភារកិច្ចទាំងអស់ ទំនួលខុសត្រូវ និង សិទ្ធិជាពលរដ្ឋ និង មានគំនិតពិចារណាថ្លឹងថ្លែងលើអ្វីដែលជាតម្លៃនៅក្នុងសង្គម យុត្តិធម៌ ប្រជាធិបតេយ្យ និង ការគោរពច្បាប់សង្គម (National Curriculum Council, 1990a)។

"កម្មវិធីសិក្សា" គឺជាមុខវិជ្ជាសិក្សាជាច្រើនដែលត្រូវបានដាក់ឱ្យសិក្សា នៅក្នុងសាលារៀន ឬសាកលវិទ្យាល័យនានា (Oxford Language, 2021)។ កម្មវិធីសិក្សាត្រូវតែរួមបញ្ចូលគោលការណ៍ចាំបាច់នៃការសិក្សាដោយមានធាតុសំខាន់ៗ ៥យ៉ាងគឺ មូលដ្ឋាននៃភាសាកំណើត និងរចនាសម្ព័ន្ធនៃការសិក្សាវេយ្យាករណ៍ អក្សរសាស្ត្រ និងការសរសេរ, គណិតវិទ្យា, វិទ្យាសាស្ត្រ, ប្រវត្តិវិទ្យា, និងភាសាអង់គ្លេស (Bestor, 1956) ។ កម្មវិធីសិក្សា គឺជាកម្មវិធីអប់រំនៃសាលារៀន (Oliver, 1977) ហើយវាបានបែងចែកជា៤ ផ្នែកសំខាន់ៗ គឺ (១) កម្មវិធីផ្នែកសិក្សា (២) កម្មវិធីផ្នែកបទពិសោធន៍ (៣) កម្មវិធីផ្នែកសេវាកម្ម និង (៤) កម្មវិធីសិក្សាសម្ងាត់។ វាជាបណ្តុំនៃអ្វីៗ ដែលយុវជន និងសិស្សគ្រប់រូបត្រូវធ្វើ និង មានបទពិសោធន៍ ដោយមធ្យោបាយនៃការអភិវឌ្ឍ សមត្ថភាពធ្វើអ្វីៗបានសម្រេច ហើយសម្រេចបាននូវជីវិតយុវវ័យ ដើម្បីឱ្យមានការគោរពឱ្យតម្លៃនូវអ្វីដែលយុវជនគួរធ្វើ (Bobbit, 1918) ។ លោក Doll (1988) បានបន្ថែមថាវាជាដំណើរការអប់រំផ្លូវការ និងក្រៅផ្លូវការដែលអ្នកសិក្សាទទួលយកចំណេះដឹង និង ការស្វែងយល់ការអភិវឌ្ឍជំនាញ បុគ្គលិកលក្ខណៈ ការស្ងើចសរសើរ និងតម្លៃដែលផ្តល់ដោយសាលារៀន។ វាជាបទពិសោធន៍ទាំងឡាយដែលអ្នកសិក្សារំពឹងទុកថានឹងទទួលបាននៅក្នុងសាលា រៀនក្រោមការបង្ហាត់បង្រៀនរបស់គ្រូ (Bonsor, 1920) & (Caswell, 1935)។ លោក Palma (2017) បានបំភ្លឺអោយយើងយល់ថា កម្មវិធីសិក្សាមិនមែនមានន័យត្រឹមតែបញ្ជីមុខវិជ្ជា ឬខ្លឹមសារមេរៀន ឬសេចក្តីណែនាំសង្ខេបអំពីមេរៀនដែលត្រូវបង្រៀន ឬខ្លឹមសារដែលមាននៅក្នុងសៀវភៅនោះទេ។ វាជាការ រួមបញ្ចូលគ្នារវាងខ្លឹមសារដែលត្រូវរៀន បទពិសោធន៍ និងធនធានដែលជ្រើសរើស រៀបចំ និងអនុវត្តយ៉ាងហ្មត់ចត់ ដើម្បីនាំសិស្សនិស្សិតទៅដល់ផលសម្រេច ក្លាយជាអ្វីមួយក្នុងរយៈកាលកំណត់ សកម្មភាពបង្រៀន រៀន ស្រាវជ្រាវ និង

ការអភិវឌ្ឍនធនធានមនុស្ស។ អ្វីៗដែលសាលារៀនមានចិត្តចង់ បង្រៀនដល់សិស្ស និស្សិត ហើយកម្មវិធីនោះត្រូវតែបញ្ជាក់យ៉ាងច្បាស់នូវគោដៅជាក់លាក់ អាចវាស់បាន ដែលកំណត់ដោយវត្ថុបំណង ចំណុចចាប់ផ្ដើមនៃការអភិវឌ្ឍ និង សកម្មភាពប្រតិបត្តិកម្មវិធីសិក្សានោះ គឺជាកម្មវិធីសិក្សា (Witt, 2012)។

"មធ្យមសិក្សាទុតិយភូមិ" គឺជាកម្រិតនៃការសិក្សា ដែលត្រូវបានបែងចែកទៅតាមកម្មវិធី សិក្សាទៅតាមសម័យកាល ដែលសព្វថ្ងៃត្រូវបានអនុវត្តចាប់ពីថ្នាក់ទី១០ដល់ទី១២ ដែលឱ្យឈ្មោះថាវិទ្យាល័យ (ក្រសួងអប់រំយុវជន និង កីឡា, ២០១៧)។

ដូច្នេះ "ស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ" មានន័យថា គឺជាហេតុភេទ ស្ថានការណ៍ ឬដំណើរប្រព្រឹត្តិទៅនៃការដាក់បញ្ចូលកម្មវិធីសិក្សាដើម្បីឱ្យពលរដ្ឋគ្រប់ទទួលបាននូវចំណេះដឹង ចំណេះធ្វើ តម្លៃសីលធម៌ និងទំនៀមទម្លាប់ មានសមត្ថភាព ពេញលេញជាពលរដ្ឋសកលប្រកបដោយគុណភាពដែលអាចប្រៀបធៀបជាមួយពលរដ្ឋនៅក្នុងសាកលលោកបាន។

ការសិក្សាពេញមួយជីវិត គឺជាដំណើរការនៃការសិក្សាដែលកើតឡើងរហូតដល់ដង្ហើម ចុងក្រោយនៃជីវិត (Javis P, 1990) & (Cohen, 1975)។ការសិក្សាពេញមួយជីវិត បានកំណត់ជាដំណើរការនៃការអប់រំដែលបានផ្ដល់ទៅដល់ជនគ្រប់រូប គ្រប់វ័យ (Cheng KM, 1999)។ ហើយជាផ្នែកសំខាន់មួយនៃវាយនភាពនៃការរស់នៅ (Dowd, 1979)វាបានរួមបញ្ចូលគ្រប់ប្រភេទបទពិសោធន៍នៃការរៀនក្នុង ឆាកជីវិត (Candy PC, 1994)។ ជារួម ការសិក្សាពេញមួយជីវិត គឺត្រូវចូលរួមនៅក្នុងសង្គមទាំងមូល និង រួមបញ្ចូលគ្រប់ទំរង់នៃការអប់រំ ទាំងការអប់រំជាផ្លូវការ មិនផ្លូវការ និងការអរប់រំក្រៅផ្លូវការគ្រប់វ័យ និងគ្រប់ស្ថានភាពនៃជីវិត ដោយមិនគិតពីទីកន្លែង ឬអ្នកណាជាអ្នករៀបចំ [(Candy, 2000), (Cropley, 1979), (Davw, 1975), (Dinevsk, 2004), (Faure, 1972), (Lengrand, 1970), (Preece, 2011), (Tuschling A, 2006), (Wain, 2009)]។ វាគឺជាដំណើរការនៃការ បំពេញតម្រូវការផ្ទាល់ខ្លួន សង្គម និងជំនាញនៃការអភិវឌ្ឍតាមអាយុកាលរបស់បគ្គលម្នាក់ (Dave, 1976)។ ម្យ៉ាងវិញទៀតវាសំដៅដល់គ្រប់សកម្មភាព រួមទាំងគ្រប់ជំនាញដែលជាចង្កោមនៃចំណេះដឹង ការប្រើប្រាស់ គ្រប់អត្ថន័យដែលអាច

ប្រើប្រាស់បាន និងផ្តល់ឱកាសសម្រាប់គ្រប់គ្នា សម្រាប់ការអភិវឌ្ឍបុគ្គលបានពេញលេញ (Sell, 1978)។ វាបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំ សំដៅធានា សិទ្ធិសេរីភាព និងសុភមង្គលគ្រួសារ និងសង្គម ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មី។ ហើយវាជាដំណើរការរៀនសូត្រទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ តាំងពីចាប់កំណើតរហូតដល់វ័យជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា គុណសម្បទា ឱ្យក្លាយជាពលរដ្ឋល្អ និង ចេះរួមរស់ជាមួយគ្នាប្រកបដោយភាពសុខដុមនៅក្នុងសង្គម (គោលនយោបាយជាតិ, ២០១៩)។

តាម London Metopolitan University (2017) បានបង្ហាញថា ដើម្បីបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ គឺត្រូវមានមូលដ្ឋាន ៦យ៉ាងសំខាន់ៗគឺៈ ១) មូលដ្ឋានចំណេះដឹងក្នុងការអប់រំពលរដ្ឋពេញលេញជាលក្ខណៈតំបន់ ប្រទេស និងលក្ខណៈអន្តរជាតិដោយរួមបញ្ចូលនូវនយោបាយ សង្គមវិទ្យា ចិត្តវិទ្យា គរុកោសល្យ ក្រមសីលធម៌ និង ផ្នែកផ្សព្វផ្សាយ។ល។ ២) សមត្ថភាពវិធីសាស្ត្រ ដោយផ្តោតសំខាន់លើបទពិសោធន៍នៃការអនុវត្ត និងការរៀន ដោយការធ្វើ។ ៣) សមត្ថភាពវិធីសាស្ត្រ ដោយផ្តោតសំខាន់ទៅលើការបង្រៀន ដោយប្រើប្រាស់វិធីសាស្ត្របង្ររៀនសកម្ម រួមមានការសន្ទនា ការសរសេរព្រៀង ការសំដែង ការងារក្រុម ល្បែងរៀបចំផែនការ ។ល។ ៤) ចំណេះដឹង និងជំនាញបុគ្គល ការអប់រំ សុខភាព និងសង្គម។ ៥) សមត្ថភាពវិធីសាស្ត្រ ក្នុងការអភិវឌ្ឍ បរិយាកាសថ្នាក់រៀនវិជ្ជមានដែលផ្តល់ផលទៅដល់បុគ្គលិកលក្ខណៈ និងជំនឿរបស់សិស្ស។ ៦) សមត្ថភាពមូលដ្ឋានដូចជាការគិតពិចារណា ការវិភាគបញ្ហា ។ល។ ដូច្នេះដើម្បីអោយការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញគ្រូបង្រៀនគឺត្រូវអនុវត្តការបង្រៀនដោយឈរលើមូលដ្ឋាននៃសមត្ថភាពទាំង៦ខាងលើ ទើបអាចទទួលបានលទ្ធផលល្អប្រសើរ។

តាមរយៈក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស បានបែងចែកសមត្ថភាពសំខាន់របស់សិស្ស ដើម្បីក្លាយជាពលរដ្ឋពេញលេញ ជា៨ចំណុចសំខាន់ៗគឺ ១. អក្សរសាស្ត្រនិងលេខសាស្ត្រ ២. ភាសាបរទេស ៣. បច្ចេកវិទ្យានិង ទូរគមនាគមន៍ ៤. ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម ៥. ពិចារណានិងការបង្កើតថ្មី ៦. អនុវត្តចំណេះដឹង និងជំនាញ ៧. អភិវឌ្ឍន៍បុគ្គល គ្រួសារ និងសង្គម ៨. សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ។ ចំណែកភាសាបរទេសជាជីវៈភាសាទី១ (ភាសាអង់គ្លេស ឬបារាំង)

ដែលត្រូវសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាមានសមាសភាព៤ យ៉ាងសំខាន់ៗគឺៈ ការនិយាយ ការអាន ការស្ដាប់ និងការសរសេរ។

គោលបំណងនៃភាសាបរទេសជាជីវៈភាសាទី១ គឺដើម្បីធានាអោយសិស្ស មានសមត្ថភាពទំនាក់ទំនងក្នុងបំណិនទាំង៤ (ការអាន ការស្ដាប់ ការនិយាយ និងការសរសេរ) និងក្លាយជាអ្នករៀនពេញមួយជីវិតប្រកបដោយភាពច្នៃប្រឌិត និងការជឿជាក់។

## ២.៣. កម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ

ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ គឺនៅតែបន្តអនុវត្តកម្មវិធីសិក្សាចាស់ដោយយោងទៅលើសៀវភៅសិក្សាគោល (English for Cambodia, Book4, Book5, Book6) រយៈពេលនៃការសិក្សាគឺ មានរយៈពេល៤ម៉ោង ក្នុង១សប្ដាហ៍នៅថ្នាក់ទី១០ និង២ម៉ោងក្នុង១សប្ដាហ៍នៅថ្នាក់ទី១១ និងទី១២ (ក្រសួងអប់រំយុវជន និង កីឡា, ២០១០)។ រីឯរបបពិន្ទុ គឺនៅថ្នាក់ទី១០ មានរបបពិន្ទុ១០០ មេគុណ២ ថ្នាក់ទី១១ របបពិន្ទុ៥០ មេគុណ១ និងថ្នាក់ទី១២ របបពិន្ទុគឺ៥០-២៥ មេគុណសូន្យ (ក្រសួងអប់រំយុវជន និង កីឡា, ២០១៨)។

ការបង្រៀន និងរៀន គឺត្រូវពឹងផ្អែកទៅលើសៀវភៅសិក្សាគោលជាមូលដ្ឋាន ដែលមានខ្លឹមសារលម្អិតដូចតទៅ (១) ថ្នាក់ទី១០មាន២០មេរៀន ស្មើនឹង៦០ជំពូក ហើយក្នុង១ជំពូកគឺត្រូវសិក្សារយៈពេល ២ម៉ោង ដូច្នេះ៦០ជំពូកគឺត្រូវសិក្សារយៈពេល១២០ម៉ោង ស្មើនឹង៣០សប្ដាហ៍ក្នុង១ឆ្នាំសិក្សា និង (២) ថ្នាក់ទី១១និងថ្នាក់ទី១២មាន២០មេរៀន ស្មើនឹង៦០ជំពូក ហើយក្នុង១ជំពូកគឺត្រូវ សិក្សារយៈពេល២ម៉ោង ដូច្នេះ ៦០ជំពូក គឺត្រូវសិក្សារយៈពេល១២០ម៉ោង ស្មើនឹង ៦០សប្ដាហ៍ក្នុង១ឆ្នាំសិក្សា។ តែដោយពេលវេលាដែលត្រូវសិក្សាមានរយៈពេលតែ២ម៉ោង ក្នុង១សប្ដាហ៍សម្រាប់ថ្នាក់ទី១១និងទី១២ ការអនុវត្តកម្មវិធីសិក្សា មិនអាចបញ្ចប់បាន ទាំងស្រុងតាមសៀវភៅសិក្សាគោលនោះទេ ដូច្នេះក្រសួងអប់រំយុវជន និងកីឡា បានចេញសេចក្ដីណែនាំដោយសម្រួលយកតែពាក់កណ្ដាលនៃមេរៀន ទាំងអស់គឺ ត្រូវបង្រៀន ១០មេរៀនស្មើនឹង៣០ជំពូក ដែលតម្រូវអោយបង្រៀន៦០ម៉ោងស្មើនឹង៣០សប្ដាហ៍ ក្នុង១ឆ្នាំសិក្សា (ម៉ោងបង្រៀនសុទ្ធសាធ)។

ដោយយោងទៅលើស្ថានភាពនៃការអនុវត្ត ការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសរវាងម៉ោងពេលបង្រៀន ជាមួយនឹងខ្លឹមសារមេរៀននៃសៀវភៅសិក្សាគោលខាងលើ យើងសង្កេតឃើញថាការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិគឺមានបញ្ហា ជាពិសេស គឺ ភាពមិនស៊ី គ្នារវាងខ្លឹមសារមេរៀន និងម៉ោងពេលបង្រៀននេះតែម្តង។ ដូច្នេះការសិក្សានេះ គឺសិក្សាស្វែង យល់ថាតើគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យមានទស្សនៈបែបណាទៅលើដំណើរការនៃការអនុវត្តកម្មវិធីសិក្សាស្រុង ដើម្បីអោយមានភាពរីកចម្រើន និងអាចបញ្ជ្រាបការអប់រំពេញលេញអោយមានភាពល្អប្រសើរ។

## ២.៤. ការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញនៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ

តាមរយៈ Oxfam (1997) បានដកស្រង់ទស្សនៈរបស់លោក Davies (2006) អំពីសមាសភាគសំខាន់ៗ បីយ៉ាងរបស់ការអប់រំពលរដ្ឋពេញលេញគឺៈ ទី១ ចំណេះដឹង និងការស្វែងយល់អំពីមូលដ្ឋាននៃបញ្ហាសកល ដូចជា បញ្ញត្តិនៃការស្វែងយល់អំពី យុត្តធម៌សង្គម ជម្លោះ និងសន្តិភាព ភាពចម្រុះសាសន៍ ការអភិវឌ្ឍប្រកបដោយចៃរភាព និងសកលភាវូបនីយកម្ម។ ទី២ ជំនាញដែលមានដូចជា គំនិតក្នុងការត្រិះរិះពិចារណា សមត្ថភាពក្នុងការជជែកតវ៉ា សហប្រតិបត្តិការ ដំណោះស្រាយជម្លោះ ព្រមទាំងសមត្ថភាពក្នុងការប្រឆាំងជាមួយ អសមភាព និងអយុត្តិធម៌សង្គម។ ទី៣គឺ តម្លៃ និងអាកប្បកិរិយា ដែលមានដូចជាការប្តេជ្ញាចិត្តទៅលើសមភាព ការគោរព និងអោយតម្លៃទៅលើភាពចម្រុះសាសន៍ ការយល់ចិត្ត ការយកចិត្តទុកដាក់ទៅលើបរិស្ថាន ការប្តេជ្ញាចិត្តទៅលើការអភិវឌ្ឍប្រកបដោយចីរភាព ការអោយតម្លៃទៅលើអត្តសញ្ញាណ និងការអោយតម្លៃទៅលើខ្លួនឯង។ ការសិក្សាស្រាវជ្រាវដ៏ទូលំទូលាយមួយ បានបង្ហាញថា ពលរដ្ឋពេញលេញ និងប្រធានបទដែលជាប់ទាក់ទងជាមួយគ្នានោះគឺ អាចបញ្ជ្រាបបានតាមរយៈ ខ្លឹមសារនៃមុខវិជ្ជាជាច្រើនដូចជា ប្រវត្តិវិទ្យា ភាសា និងសិក្សាសង្គម ហើយគ្រូបង្រៀនហាក់ដូចជាត្រូវបានបង្ហាញអំពីឧទាហរណ៍សកល នៅក្នុងការអនុវត្តក្នុងថ្នាក់របស់ពួកគេដោយយោងទៅលើ ករណីសិក្សាជាច្រើនដែលបានសិក្សា (Wagner, Parkhouse, Glazier and Cain, 2016)។ ការសិក្សាសង្គម និង

ការអប់រំសីលធម៌ គឺជាផ្នែកដែលមានប្រជាប្រិយភាពយ៉ាងខ្លាំងក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ។ ដើម្បីជាឧទាហរណ៍បញ្ជាក់នៅក្នុងការសិក្សាមួយនៅសហរដ្ឋអាមេរិច ដែលបង្ហាញថាការអប់រំពលរដ្ឋពេញលេញ គឺជាផ្នែកមួយនៃវិទ្យាសាស្ត្រសង្គម ហើយនិងមធ្យោបាយនៃការបញ្ជ្រាបរបស់វាគឺត្រូវបានបង្ហាញថា សកលនិយម ពិភពសកល អន្តរជាតិនិយម និង ព្រឹត្តិការណ៍ជាប់ទាក់ទងនឹងសកលនិយម ជាញឹកញាប់ត្រូវបានអនុវត្ត និងពិភាក្សានៅក្នុងការពិភាក្សានៅក្នុងថ្នាក់រៀន (Ropport, 2013)។ ជាងហ្នឹងទៀតការពន្យល់អំពីការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងការអនុវត្តក្នុងថ្នាក់រៀន និងកម្មវិធីសិក្សារបស់អ៊ីតាលី បានសំគាល់ឃើញថាការអប់រំសម្រាប់ពលរដ្ឋពេញលេញ ឬពលរដ្ឋសកល គឺជាសកម្មភាពពហុគំរូនៃការរៀបចំនៅក្នុងសាលា និងកម្រិតនៃគ្រូបង្រៀន។ សម្រាប់សកម្មភាពនេះ ខណៈពេលដាក់បញ្ចូលសកម្មភាពកម្មវិធីរបស់គ្រូបង្រៀន ជាមួយនឹងពលរដ្ឋពេញលេញ សមត្ថភាពរបស់គ្រូបង្រៀន និងសមាសភាពនៃការរៀបចំកម្មវិធីគួរតែត្រូវបានគិតពិចារណា (Damiani, 2018)។ យោងទៅលើរបាយការណ៍របស់អង្គការ UNESCO ខាងផ្នែកការអប់រំពលរដ្ឋសកល ឬ ការអប់រំពលរដ្ឋពេញលេញ (GDC) ក្នុងឆ្នាំ២០១៥ ក៏បានបង្ហាញអំពីសមភាពទាំងបីរបស់ការអប់រំពលរដ្ឋពេញលេញដែលមានការយល់ដឹង ការស្វែងយល់ ពីទស្សនៈវិស័យអារម្មណ៍សង្គម និងផ្នែកអាកប្បកិរិយា។ សមាសភាពនៃការយល់ដឹង នៃពលរដ្ឋសកលគឺ សំដៅទៅដល់សមត្ថភាពនៃការបង្ហាញ និង ការស្វែងយល់អំពីប្រទេសដទៃ វប្បធម៌ និងសហទំនាក់ទំនងរវាងមនុស្សនៅលើពិភពលោក។ ការស្វែងយល់ពីទស្សនៈវិស័យអារម្មណ៍សង្គមគឺសំដៅដល់អារម្មណ៍ ដែលជាកម្មសិទ្ធទំនួលខុសត្រូវរបស់មនុស្សជាតិ ការគោរពវប្បធម៌ដទៃ ពូជសាសន៍ និងជាតិសាសន៍ដទៃ។ រីឯសមាសភាពអាកប្បកិរិយាគឺសំដៅដល់អាកប្បកិរិយារបស់មនុស្សដែលមានការគោរព និង ប្រសិទ្ធភាពនៃការបែងចែក និងគ្រប់គ្រងទឹកដីដើម្បីរក្សានូវសន្តិភាពពិភពលោក។

ការរៀនភាសាគឺជាដំណើរការដ៏ស្មុគស្មាញមួយ ដែលមិនត្រឹមជាការពិតនោះទេ ប៉ុន្តែវាស្ថិតនៅក្រោមអត្ថន័យដ៏ស្មុគស្មាញ និងតម្លៃបង្កប់នានាដែលពាក់ព័ន្ធ (Guilherme, 2007)។ វគ្គសិក្សាភាសា និងសៀវភៅសិក្សាគោល ត្រូវបានគេមើលឃើញថាជាឧបករណ៍ សម្រាប់បញ្ជ្រាបវប្បធម៌ មនោគមន៍វិជ្ជានយោបាយ នៅក្នុងបរិបទសង្គមផ្សេងៗជាច្រើន ដោយសារការវិភាគសៀវភៅសិក្សាគោល បានបង្ហាញ

និង ពន្យល់អំពីតំណាងមនោគមវិជ្ជា និងវប្បធម៌នៃប្រទេសជាតិ (Liu, 2005)។ មានការប៉ុនប៉ងជាច្រើនក្នុងការរួមបញ្ចូលគ្នារវាង ការសិក្សាភាសាបរទេស និងពលរដ្ឋពេញលេញរហូតមកដល់បច្ចុប្បន្ន ហើយវាត្រូវបានគេរកឃើញថាការប៉ុនប៉ងទាំងនេះ បានរួមចំណែកដល់ការយល់ដឹងរបស់សិស្ស ទាំងលក្ខណៈជាតិ និងអន្តរជាតិ និងសកម្មភាពក្នុងការចូលរួមរបស់ពួកគេសង្គមស៊ីវិល (Byram & Porto, 2015)។ កម្មវិធីសិក្សាភាសាអង់គ្លេសរបស់ចិន បានបង្ហាញពីទំនោរក្នុងការបញ្ចូលការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីកំណត់តួនាទីនៃភាសាអង់គ្លេស (Xiaohong & Zeegers, 2010) ដោយសារតែការអប់រំពលរដ្ឋពេញលេញជួយ អោយបុគ្គលគ្រប់រូបក្លាយជាពលរដ្ឋសកល ហើយមានចំណេះដឹងនៃព្រឹត្តិការណ៍សកល និងទំនួលខុសត្រូវ (Pinet, 2006)។ ក្នុងការកំណត់អំពីពលរដ្ឋពេញលេញ នៅក្នុងកម្មវិធីសិក្សាភាសាអង់គ្លេស មានទាំងគំរូដែលល្អពេញចិត្ត និងមិនពេញចិត្ត ដែលប្រទេសទាំងឡាយគួរតែយកជាមេរៀន។ ការសិក្សានៅក្នុងប្រទេស កូឡុំប៊ី បានបង្ហាញថា កម្មវិធីសិក្សាភាសាអង់គ្លេសឆ្លុះបញ្ចាំងពីសមាសធាតុនៃពលរដ្ឋពីទស្សនៈវិស័យខាងលើ ហើយការអានហាក់ដូចជាជំនាញតែមួយដែលត្រូវបានបញ្ច្រាបពលរដ្ឋពេញលេញ (Calle-Diaz, 2017)។ បញ្ញត្តិនៃពលរដ្ឋពេញលេញត្រូវបានបែងចែកជាធាតុបីសំខាន់ៗគឺ ពលរដ្ឋ នយោបាយ និងសង្គម (Marshall, 1964)។ ពលរដ្ឋភាពនៃពលរដ្ឋពេញលេញ សំដៅដល់ សិទ្ធិបគ្គលដូចជា សេរីភាពនៃការនិយាយ សិទ្ធិក្នុងភាពជាម្ចាស់ និងភាពស្មើគ្នារវាងបុគ្គលទាំងឡាយ ក្នុងសង្គម។ ពលរដ្ឋពេញលេញ នៃនយោបាយគឺសំដៅដល់អំណាចនៃពលរដ្ឋ តាមរយៈការចូលរួមក្នុង នយោបាយ។ ចំណែកឯពលរដ្ឋពេញលេញនៃសង្គមគឺគ្របដណ្តប់លើផ្នែកសុខភាព ការអប់រំ ទ្រព្យសម្បត្តិ បុគ្គល នៅក្នុងប្រទេសមួយ។ យ៉ាងណាក្តីពលរដ្ឋពេញលេញសកម្ម សង្កត់ធ្ងន់លើអំណាច និង ការចូលរួម នៃបុគ្គល ដើម្បីក្រសោបយកតម្លៃទាំងឡាយដូចជា ការទទួលខុសត្រូវ និងការគោរព ហើយការសិក្សាបានធ្វើសំគាល់ទៅលើសារៈសំខាន់នៃការមើលឃើញការបង្រៀន និងរៀនភាសា គឺជាគន្លឹះសម្រាប់ការចូលរួម និងពលរដ្ឋសកម្ម ដែលអាចធ្វើអោយមានការផ្លាស់ប្តូរសង្គម (Brady, 2006)។

ចាប់តាំងពីភាសាអង់គ្លេសត្រូវបានដាក់ជាភាសាអន្តរជាតិ វាបានក្លាយជាតំណាងដែលទទួលបានការយកចិត្តទុកដាក់ពីអ្នកស្រាវជ្រាវជាច្រើន ហើយវាច្បាស់ណាស់ថា EFL ជាបណ្តុំនៃវប្បធម៌ និងអន្តរវប្បធម៌ និងជាតំណាងដែលដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការយល់ដឹងអំពីពិភពលោក និងខ្លួនរបស់ពួកគេក្នុងនាមជាពលរដ្ឋ (Song, 2013)។ ការសិក្សាមួយបានធ្វើឡើងដើម្បីពិភាក្សាថាតើភាសាដើរតួនាទីសំខាន់នៅក្នុងអន្តរទំនាក់ទំនងរវាងសិស្ស និងក្របខណ្ឌខ្លឹមសារដូចជាវប្បធម៌ វាបានសង្កត់ធ្ងន់ថាវប្បធម៌ និងទស្សនៈអន្តរជាតិនៃវប្បធម៌ ត្រូវបានបញ្ជ្រាបតាមរយៈសៀវភៅសិក្សាគោល គ្រូបង្រៀនដូចជា អ្នកសម្របសម្រួល និងអ្នកសម្រុះសម្រួលគួតែដឹងពីខ្លឹមសារបង្កប់ទាំងអស់នោះ និងយុទ្ធសាស្ត្រនៃការផ្តល់ការងារធ្វើ (Kiss & Weninger, 2013)។ ការសិក្សាមួយផ្សេងទៀតបានធ្វើការ ផ្តោតការយកចិត្តទុកដាក់ជាច្រើនទៅលើគោលបំណងនៃពលរដ្ឋពេញលេញ ដើម្បីបង្ហាញពីលទ្ធផលនៃទស្សនៈយល់ឃើញរបស់គ្រូបង្រៀន ទៅលើការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងការបង្រៀនភាសាអង់គ្លេស (ELT) ហើយលទ្ធផលបានបង្ហាញថា គ្រូបង្រៀនបានចាប់យកច្បាប់របស់ពួកគេក្នុងការរៀបចំពលរដ្ឋ ប៉ុន្តែពួកគេមិនបានផ្តល់បច្ចេកទេសពិសេសនោះទេ នៅក្នុងបរិបទអប់រំក្នុងប្រទេសទួគី (Basarir, 2017) ដែលនាំអោយតម្រូវការ ត្រូវផ្តោតសំខាន់ទៅលើសមត្ថភាពយល់ដឹង របស់គ្រូបង្រៀន និង រួមបញ្ចូលការអនុវត្តភាពជាពលរដ្ឋពេញលេញនៅក្នុងថ្នាក់រៀន។ កម្មវិធីសិក្សា EFL ដែលរៀបចំដោយ MoNE របស់ប្រទេសទួគី មាន៩ផ្នែកសំខាន់ៗ ដែលគោលបំណងរួមមាន ទស្សនៈវិជ្ជា និង គន្លឹះសមត្ថភាពនៃកម្មវិធីសិក្សា ដែលត្រូវបានគេរំពឹងទុកថាសិស្សនឹងទទួលបានសមត្ថភាពសំខាន់ៗគឺ ការទទួលខុសត្រូវសង្គម និងភាពជាពលរដ្ឋ ការយល់ដឹងអំពីវប្បធម៌ និងការច្នៃប្រឌិត។ ដោយយោងទៅលើការរៀបចំកម្មវិធីសិក្សាផ្លូវការ មុខវិជ្ជាភាសាអង់គ្លេសថ្នាក់មធ្យម ដែលរៀបចំដោយ MoNE របស់ប្រទេសទួគីមានជំនាញបីយ៉ាង គឺជំនាញប្រពៃណី ជំនាញឌីជីថល និងជំនាញស្រប ដែលត្រូវបានកំណត់ដោយគណកម្មការអ៊ឺរ៉ុប។ ទំនួលខុសត្រូវសង្គម និងពលរដ្ឋ ចំណេះដឹងផ្នែកវប្បធម៌ និងការបង្កើតថ្មី គឺជាផ្នែកសំខាន់នៃសមត្ថភាពនៃកម្មវិធីសិក្សាដែលមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយ នឹងការអប់រំពលរដ្ឋពេញលេញ។ ទំនួលខុសត្រូវភាពជាពលរដ្ឋគឺជាគន្លឹះមួយនៃជំនាញ ដែលបុគ្គលគ្រប់រូបត្រូវទទួលយកតាមរយៈការអប់រំ EFL។ ដែល

មានន័យថាកម្មវិធីសិក្សា EFL គឺមានគោលបំណង ដឹកនាំពលរដ្ឋគ្រប់រូប ដែលមានចំណេះដឹងនៃភាពជាពលរដ្ឋ និងទំនួលខុសត្រូវអោយមានភាពប្រសើរឡើង។ ទំនួលខុសត្រូវនៃភាពជាពលរដ្ឋ នេះគឺជាសញ្ញាណនៃសមាសភាគដ៏សំខាន់មួយដែល ត្រូវបានបញ្ជ្រាបយ៉ាងលើសលុប និងគ្របដណ្តប់ទៅលើកម្មវិធីសិក្សា។ ចំណែកឯវប្បធម៌ដែលមាន ទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងពលរដ្ឋពេញលេញ និងសមាសភាពនៃការអប់រំពលរដ្ឋពេញលេញ បានក្លាយជាសមត្ថភាពសំខាន់ដែលមានការព្រួបារម្ភ ចាប់តាំងពីពលរដ្ឋពេញលេញមិនបានចាត់ទុកថា ជាផ្នែកមួយនៃវប្បធម៌។ នៅពេលដែលវាត្រូវបានពិចារណាថាជាវប្បធម៌នៅក្នុងវិសាលភាពនៃការអប់រំ EFL នោះគឺមានទស្សនៈវិស័យពីរ ដែលជាវប្បធម៌ក្នុងតំបន់ និងវប្បធម៌គោលដៅ។ វប្បធម៌ក្នុងតំបន់ប្រហែលជាត្រូវបានបញ្ចូលតាមរយៈ រឿង ជីវប្រវត្តិនានា ការប្រារពពិធីនានា ឬទីកន្លែងដែលជាវប្បធម៌ របស់ប្រទេសទួគី ដែលជាគោលបំណងមួយដ៏សំខាន់នៃកម្មវិធីសិក្សាថ្មីៗ រីឯវប្បធម៌គោលដៅ ប្រហែល ជាត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីសិក្សា EFL តាមរយៈការអធិប្បាយរបស់មនុស្ស ព្រឹត្តិការណ៍ ទីកន្លែង ពីវប្បធម៌អង់គ្លេស ឬពីប្រទេសដទៃនៅលើពិភពលោក ដើម្បីបង្កើតវប្បធម៌ចម្រុះសាសន៍ក្នុងកម្មវិធីសិក្សា EFL។ តាមការស្រាវជ្រាវរបស់លោក (Matthew Hayes) បានបង្ហាញថាការបញ្ជ្រាបការអប់រំពលរដ្ឋ ពេញលេញតាមរយៈមុខវិជ្ជាភាសាអង់គ្លេស ដែលលោកបានចាត់ទុកថាជាជំនាញសកល ឬជំនាញជីវិត នោះមាន៦ចំណុចសំខាន់ៗ គឺ ១. ការទំនាក់ទំនង ២. កិច្ចសហប្រតិបត្តិការ ៣. កិច្ចសហការ ៤. ការដោះស្រាយបញ្ហា ៥. គំនិតបង្កើតថ្មី និង៦. ការត្រិះរិះពិចារណា។ តាមការសិក្សាពីសៀវភៅ សិក្សាគោល Global Stage របស់ Macmillan លោកបានសង្ខេបខ្លឹមសាររួមនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ តាមរយៈការសិក្សាមុខវិជ្ជាភាសាអង់គ្លេសជាបីចំណុចសំខាន់ៗគឺៈ (១) ការដោះស្រាយបញ្ហាៈ សិស្សានុសិស្សត្រូវបានស្នើអោយពន្យល់អំពីឧទាហរណ៍ដ៏ធំមួយនៃព្រឹត្តិការណ៍កីឡា នៅសាលារៀនដែលបានបញ្ចប់ទៅ ពួកគេត្រូវធ្វើការងារជាក្រុមដើម្បីកំណត់បង្ហាញនូវ អ្វីដែលជាបញ្ហាដែលបានកើតមានក្នុងព្រឹត្តិការណ៍កីឡានោះ។ ធ្វើដូច្នេះពួកគេនឹងអាចដោះស្រាយឬអាចកែប្រែបញ្ហានោះបាននៅថ្ងៃអនាគត។ នេះជាឧទាហរណ៍ដ៏ល្អមួយក្នុងការដោះស្រាយបញ្ហារបស់សិស្ស (២) កិច្ចសហការៈ សិស្សានុសិស្សត្រូវបានស្នើអោយស្តាប់ទៅលើការសន្ទនារបស់

សិស្សពីរនាក់ ដែលបានធ្វើការជាមួយគ្នាដើម្បីបំពេញកិច្ចការ ក្រោយការស្តាប់យ៉ាងច្បាស់ ការបញ្ជាក់ និង ការកែតម្រូវ នូវចំណុចទាំងអស់បានរួចរាល់ សិស្សទាំងអស់ ត្រូវធ្វើការសម្តែងការងារជាក្រុមដៃគូទាំងអស់គ្នា។ នេះជាកិច្ចសហការគ្នាដែលជាបទពិសោធន៍មួយដែលទទួលបានពីការសិក្សាមុខវិជ្ជាភាសាអង់គ្លេស និង(៣) គំនិតបង្កើតថ្មី៖ សិស្សានុសិស្សត្រូវបានស្នើអោយគិតអំពីបញ្ហាដែលកើតមានក្នុងតំបន់របស់ពួកគេរស់នៅ ហើយប្រើប្រាស់គំរូដែលមានរចនាសម្ព័នដើម្បីកំណត់អត្តសញ្ញាណថាតើវាបានកើតឡើងដោយរបៀបណា វាមានប្រសិទ្ធភាពយ៉ាងដូចម្តេច ហើយតើដំណោះស្រាយណាខ្លះ ដែលពួកគេត្រូវរៀបចំ ដើម្បីដោះស្រាយទៅលើបញ្ហាទាំងអស់នោះ។ តាមរយៈបញ្ហាតូចៗដែលកើតមានក្នុងតថភាពជាក់ស្តែងរបស់សិស្ស ដែលពួកគេបានធ្វើការរិះគិតពីបញ្ហា និងដំណោះស្រាយ វាជាគន្លឹះសម្រាប់អោយពួកគេអាចអភិវឌ្ឍការគិតរបស់ពួកគេឈានទៅរកការគិត និងដោះស្រាយនូវរាល់បញ្ហាធំៗ ឬបញ្ហាសកលបាន។ ទាំងនេះហើយគឺជាភាពច្បាស់លាស់នៃជំនាញនៅក្នុងបរិបទសកល ដែលអាចអោយសិស្សក្លាយទៅជា ពលរដ្ឋសកល ឬ ហៅថាពលរដ្ឋពេញលេញ តាមរយៈជំនាញ ឬបំណិនសកលដែលបានបញ្ជ្រាបតាមរយៈ សិក្សាមុខវិជ្ជាភាសាអង់គ្លេស។

## ២.៥. សារៈសំខាន់នៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុង កម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ

មូលដ្ឋាននៃការអប់រំពលរដ្ឋពេញលេញត្រូវបានបែងចែកជាបីផ្នែកសំខាន់ៗ គឺ សីលធម៌សាលាសេវាសហគមន៍ និង កម្មវិធីសិក្សា (Arthur & Wright, 2001; Calvert & Clemitshaw, 2003; Lopes et, 2009)។ គ្រប់មុខវិជ្ជាទាំងអស់ត្រូវតែធ្វើការបង្រួបបង្រួមបញ្ចូលគ្នា ដើម្បីធ្វើអោយប្រសើរឡើងនូវការយល់ឃើញដ៏ល្អប្រសើរអំពីការអប់រំពលរដ្ឋពេញលេញនៅក្នុងបរិស្ថានសាលារៀន និងទឹកចិត្តអ្នកសិក្សា។ វិធានការនេះនឹងធ្វើអោយគុណសម្បត្តិនៃការអប់រំពលរដ្ឋពេញលេញមានភាពប្រសើរឡើង និងផ្តល់ឱកាសយ៉ាងធំធេងសម្រាប់អោយអ្នកសិក្សាយល់ដឹងពីមុខវិជ្ជាថ្មីៗ (Arthur et al, 2001) ។ ហើយវានឹងមានភាពប្រសើរឡើងក្នុងការបង្រៀនការអប់រំពលរដ្ឋពេញលេញ តាមរយៈមុខវិជ្ជាសំខាន់ៗ នៅក្នុងកម្មវិធីសិក្សាជាជាងការដាក់វាអោយនៅជាមុខវិជ្ជាឯករាជ្យ។ ការអប់រំពលរដ្ឋពេញលេញគឺជាគោលដៅសំខាន់

ដែលគ្រប់ការអប់រំទាំងអស់គួរតែទទួលយក (Simon, 1936; Brett, 2005) ហើយការកកើតឡើងនេះ មិនគួរត្រូវបានកំណត់ជាមុខវិជ្ជាមួយនោះទេ។

តាមលោក Lea Mae Gabunal (2016) បាននិយាយថា ទោះបីជាមុខវិជ្ជាភាសាអង់គ្លេស មិនជាប់ទាក់ទង ជាមួយនឹងមុខវិជ្ជាឯកទេសក៏ដោយ ក៏នៅតែចាំបាច់ក្នុងការសិក្សាភាសាអង់គ្លេស ព្រោះវាជាមូលដ្ឋានគ្រឹះលើគ្រប់មុខវិជ្ជាឯកទេសទាំងអស់។ សិស្សដែលមានបំណិនផ្នែកភាសាអង់គ្លេស អាចនិយាយ អាចសរសេរបានល្អ គឺធ្វើឱ្យសិស្សមានភាពក្លាហាន និងមានទំនាក់ទំនងល្អនៅក្នុងសង្គម។ ភាសាអង់គ្លេសគឺ ជាស្ពានឆ្លងទៅរកភាពជោគជ័យក្នុងការងារនៅអនាគត។ ភាសាអង់គ្លេសជាប់ទាក់ទង ទៅគ្រប់អ្វីៗ ដែលយើងធ្វើមិនថានៅផ្ទះ ឬនៅសាលា វាអាចជួយយើងបានលើគ្រប់មុខវិជ្ជាឯកទេស ពេលដែលយើងចូលរៀននៅសាកលវិទ្យាល័យនានា ពង្រឹងជំនាញទំនាក់ទំនង និងធ្វើឱ្យមានភាពល្អ ប្រសើរនៅក្នុងជីវិត។

តាមលោក Guilherme (2002) បានបញ្ជាក់ថា បរិបទនយោបាយ សេដ្ឋកិច្ច និងសង្គម អនាគតពលរដ្ឋរបស់យើងនឹងត្រូវតែចូលមកក្នុង លក្ខខណ្ឌជាមួយនឹងតម្រូវការនៃសញ្ញាណនៃការអប់រំ ពលរដ្ឋសាកល ដែលកាន់តែមានភាពបត់បែន កាន់តែមានសិទ្ធិអំណាច។ ដើម្បីសម្រេចគោលបំណងនេះ គឺមាន តែភាសាអន្តរជាតិ និង វប្បធម៌នៃការអប់រំដែលជួយសម្រួលការប្រាស្រ័យទាក់ទងរវាង វប្បធម៌ និង វប្បធម៌ រវាងពលរដ្ឋនៅក្នុង សង្គមពហុវប្បធម៌ និង ក្នុងពិភពលោកទាំងមូល។

ក្នុងសៀវភៅណែនាំសម្រាប់ការបង្រៀនភាសាអង់គ្លេស និងពលរដ្ឋសកលបានបញ្ជាក់ថាវិធីសាស្ត្រនៃភាពជាពលរដ្ឋសកលតាមរយៈការបង្រៀនភាសាអង់គ្លេសផ្តល់នូវអត្ថប្រយោជន៍ យ៉ាងខ្លាំងក្នុងបរិបទទូលំទូលាយចាំបាច់ត្រូវយល់អំពីភាសា និងអក្សរសាស្ត្រឱ្យបានពេញលេញ។ វាអាចឱ្យអ្នកសិក្សាពេញចិត្តនឹងកម្រិតទស្សនវិស័យស្វែងយល់កម្រិតខុសប្លែកគ្នានៃសង្គមប្រវត្តិសាស្ត្រផ្សេងៗគ្នា និងបរិបទវប្បធម៌ដែលមានឥទ្ធិពលទៅលើតម្លៃការសន្មត់ និងអត្ថន័យនៃអត្តសញ្ញាណនានា (Oxfam, 2015)។

ដោយសារការអប់រំពលរដ្ឋពេញលេញ មិនត្រូវបានដាក់ជាមុខវិជ្ជាឯករាជ្យនេះហើយ ទើបភាសាអង់គ្លេសគឺជាគន្លឹះដ៏សំខាន់មួយ ដែលជាស្ពានសម្រាប់អោយការអប់រំពលរដ្ឋពេញលេញមានភាពប្រសើរឡើង។

## ២.៦. បញ្ហាលំបាកនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស

ជាទូទៅការបង្កើតកម្មវិធីសិក្សា ឬអភិវឌ្ឍកម្មវិធីសិក្សាមានលក្ខណៈស្តង់ដា មានកម្រិតខ្ពស់ ទំហំធំ តែការអនុវត្តមិនអាចធ្វើបានទាំងស្រុង ឬត្រូវបានកាត់បន្ថយដោយសារមូលហេតុនានា ជាពិសេសការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសមានភាពលំបាកជាច្រើន។

តាមរយៈការសិក្សាស្រាវជ្រាវរបស់លោក Sahirudin (2013) បានធ្វើការអង្កេតទៅលើបញ្ហាដែលជួបប្រទះក្នុងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសមានដូចជា៖ សិស្សជាច្រើនខ្វះការលើកទឹកចិត្ត ខ្វះអត្តចរិកក្នុងការរៀនភាសាបរទេស ថ្នាក់ធំពេក គ្រូគ្មានគុណភាព ហើយរបាំងនៃវប្បធម៌របស់គ្រូបង្រៀនក្នុងការទទួលយកច្បាប់នៃការសម្របសម្រួលថ្មីៗ ក៏ជាឧបសគ្គក្នុងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស។ លោក Ofsted (2003) បានបញ្ជាក់ថា ការអប់រំពលរដ្ឋពេញលេញ គឺជាមុខវិជ្ជាដែលត្រូវបានបង្រៀនតិចបំផុតនៅក្នុងកម្មវិធីសិក្សា។ Clemitshaw, G. & Calvert, M (2005) បានបញ្ជាក់ថាការអប់រំពលរដ្ឋពេញលេញ ជួបប្រទះនូវបញ្ហាលំបាកជាច្រើន ជាពិសេសស្ថានភាពនៃមុខជំនាញ ធនធាន កម្រិតយល់ដឹង ការបណ្តុះបណ្តាល និងការប្តេជ្ញាចិត្តរបស់បុគ្គលិកអប់រំ។ Clemitshaw, G. & Calvert, M (2005) And Brett, (2006) បានបន្ថែមថាបញ្ហាលំបាកនៃការអប់រំពលរដ្ឋពេញលេញគឺខ្វះការយល់ដឹងជាមួយនឹងមុខវិជ្ជាជំនាញដែលទាក់ទងគ្នា។ ហើយបញ្ហាសំខាន់ជា ច្រើនទៀតរួមមាន៖ ខ្វះការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ខ្វះឯកសារសម្ភារៈគ្រប់គ្រាន់សម្រាប់ការ បង្រៀន និងដំណើរការវាយតម្លៃការបង្រៀន។ ការអប់រំពលរដ្ឋពេញលេញគឺ ត្រូវបានបញ្ជ្រាបទៅលើគ្រប់មុខវិជ្ជាទាំងអស់ដើម្បីអោយសិស្សានុសិស្សមាន បំណិនសម្បទា វិជ្ជាសម្បទា កាយសម្បទា និងចរិយាសម្បទាពេញលេញមុខវិជ្ជាទាំងអស់នោះរួមមាន ១.អក្សរសាស្ត្រ និងលេខសាស្ត្រ ២. ភាសាបរទេស ៣. បច្ចេកវិទ្យា

និងទូរគមនាគមន៍ ៤. ប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម ៥. ពិចារណា និងការបង្កើតថ្មី ៦. អនុវត្តចំណេះដឹង និងជំនាញ ៧. អភិវឌ្ឍន៍បុគ្គល គ្រួសារ និងសង្គម ៨. សហគ្រិនភាព និងភាពជាអ្នកដឹកនាំ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)។ ដូច្នេះតាមការសិក្សាស្រាវជ្រាវទាំងអស់ខាងលើ ការអប់រំពលរដ្ឋពេញលេញមានភាពលំបាកជាច្រើននោះមានន័យថាការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញតាមរយៈមុខវិជ្ជាភាសាអង់គ្លេសក៏នៅមានបញ្ហាប្រឈមជាច្រើនដូចគ្នាដែរ។ ហេតុនេះហើយបានជាក្នុងឆ្នាំសិក្សាថ្មីនេះ អ្នកសិក្សាត្រូវធ្វើការសិក្សាបន្ថែម ដើម្បីស្វែងយល់អោយបានស៊ីជំម្រៅទៅលើបញ្ហាទាំងឡាយដែលបានកើតមាន និងដើម្បីរកដំណោះស្រាយអោយបានល្អប្រសើរជាងមុន។

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកតាមគោលបំណងក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ដោយជ្រើសយកតែភាគសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវទិន្នន័យបានជាក់លាក់ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីទីតាំងភូមិសាស្ត្រ ភាគសំណាក ឧបករណ៍ស្រាវជ្រាវ ដំណើរការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.១. គម្រោងវិភាគ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិក្នុងការបញ្ជ្រាបការ អប់រំពលរដ្ឋពេញលេញទៅ ក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅខេត្តឧត្តរមានជ័យ"ក្នុងគោលបំណងរកអោយឃើញនូវកម្រិតនៃការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ធៀបនឹងកម្រិតនៃការយល់ដឹងរបស់សិស្សដើម្បីក្លាយជាពលរដ្ឋពេញលេញ ក្រោយពីបានសិក្សាមុខវិជ្ជានេះរួច។ ក្នុងការវិភាគយើងប្រើប្រាស់អថេរអាស្រ័យ (DV) និង អថេរមិនអាស្រ័យ (IV) ដើម្បីធ្វើការវិភាគ។ អថេរមិនអាស្រ័យគឺ សំដៅទៅលើចំណេះដឹង ក្នុងការអភិវឌ្ឍសមត្ថភាពដើម្បីក្លាយជាពលរដ្ឋពេញលេញរបស់សិស្សរួមមានសមត្ថភាពទំនាក់ទំនង កិច្ចសហប្រតិបត្តិការ ការដោះស្រាយបញ្ហា គំនិតបង្កើតថ្មី និងសមត្ថភាពក្នុងការត្រិះរិះពិចារណា។ រីឯអថេរអាស្រ័យគឺកំណត់យកនូវកត្តាដែលមានឥទ្ធិពលសំខាន់ៗមួយចំនួនរួមមាន៖ ចំនួនម៉ោងសិក្សា ធៀបទៅនឹងខ្លឹមសារនៃមេរៀន ឬខ្លឹមសារនៃមេរៀនធៀបជាមួយនឹងបម្រែបម្រួលគុណភាពសិស្ស និងសមត្ថភាពគ្រូបង្រៀន ធៀបទៅនឹងសៀវភៅសិក្សាគោល។ល។

## ៣.២. ការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះត្រូវបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យដោយប្រើកម្រងបញ្ជីសំណួរដែលបានបង្កើតទៅតាមគោលបំណងនៃការស្រាវជ្រាវ តាមរយៈកម្រងសំណួរដែលបានបង្កើតដើម្បីប្រមូលទិន្នន័យមកធ្វើការ វិភាគ។

បន្ទាប់ពីកម្រងសំណួរបានបង្កើតរួចរាល់ ហើយត្រូវបានត្រួតពិនិត្យដោយសាស្រាចារ្យណែនាំរួចអ្នកស្រាវជ្រាវក៏ធ្វើលិខិតស្នើចុះសិក្សាស្រាវជ្រាវពីវិទ្យាស្ថានជាតិអប់រំ ដើម្បីចុះប្រមូលទិន្នន័យតាមសាលាគោលដៅ ដូចដែលបានកំណត់។ ក្រោយពីទទួលបានលិខិតអនុញ្ញាត្តិចុះប្រមូលទិន្នន័យពីវិទ្យាស្ថានជាតិអប់រំ អ្នកស្រាវជ្រាវក៏បានធ្វើទំនាក់ទំនងជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំខេត្ត ដើម្បីសុំលិខិតអនុញ្ញាត្តិប្រមូលទិន្នន័យតាមសាលាគោលដៅ ដោយមានការស្នើសុំ និងកិច្ចសហការពីគណៈគ្រប់គ្រងសាលាគោលដៅទាំងអស់នៅក្នុងខេត្ត បន្ទាប់មកធ្វើការទំនាក់ទំនងជាមួយនឹងគ្រូបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិទាំងអស់ ដើម្បីណែនាំនិងផ្តល់កម្រងសំណួរទៅអោយពួកគាត់ជួយបំពេញពត៌មានទៅតាមស្ថានភាពពិតជាក់ស្តែងតាមសាលានីមួយៗ។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរដែលបានបង្កើត ដើម្បីប្រមូលទិន្នន័យតាមបែបបរិមាណវិស័យដោយប្រើកម្រងសំណួរត្រូវបានបង្កើតឡើង ដោយយោងទៅលើ Likert Scale ដើម្បីធ្វើការវាស់ស្ទង់ទៅលើកម្រិតយល់ឃើញរបស់គ្រូបង្រៀនទៅលើ ការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ ដោយបែងចែកកម្រិតនៃការវាយតម្លៃជា៥កម្រិត គឺ១. មិនយល់ស្រប ឬមិនពេញចិត្តទាំងស្រុង ២. មិនយល់ស្រប ឬ មិនពេញចិត្ត ៣. ធម្មតា ៤. យល់ស្រប ឬ ពេញចិត្ត ៥. យល់ស្រប ឬពេញចិត្តទាំងស្រុង។ កម្រងសំណួរត្រូវបានបែងចែកជាពីរផ្នែកសំខាន់ៗគឺ ផ្នែកទី១ ពត៌មានទូទៅមាន៦សំណួរ និងផ្នែកទី២ស្តីពី ស្ថានភាពនិងបញ្ហាប្រឈមនានាក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅខេត្តឧត្តរមានជ័យជាសំណួរស្ទង់មតិ

មាន៤ផ្នែកសំខាន់គឺ ទី១ មានបីសំណួរចាប់ពីសំណួរទី៧ ដល់ទី៩ ស្តីពីពេលវេលាក្នុងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ទី២ មាន៣សំណួរចាប់ពីសំណួរទី១០ ដល់ទី១២ ស្តីពីសៀវភៅសិក្សាគោលធៀបជាមួយពេលវេលា និងសមត្ថភាពគ្រូ សិស្ស ផ្នែកទី៣ មាន៩សំណួរ ចាប់ពីសំណួរទី១៣ ដល់សំណួរទី២១ ស្តីពីគុណភាពក្នុងការអភិវឌ្ឍបំណិននានានៃការអប់រំពលរដ្ឋពេញលេញ តាមរយៈកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ និងផ្នែកទី៤ មាន១សំណួរ ជាសំណួរចុងក្រោយ ស្តីពីវិធីសាស្ត្រនានាក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យអោយកាន់តែមានភាពល្អប្រសើរឡើង។

## ៣.៤. ការជ្រើសរើសភាគសំណាក

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាបានសម្រេចជ្រើសយកគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ ជាគ្រូបង្រៀនផ្នែកភាសាអង់គ្លេសសុទ្ធសាធ មានន័យថាជាគ្រូបង្រៀនដែលបានបញ្ចប់ការបណ្តុះបណ្តាលគ្រូ ដែលមានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម ឬសញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាអង់គ្លេស និងជាគ្រូដែលបានបង្រៀនសិស្សដោយផ្ទាល់ ដើម្បីអាចមានលទ្ធភាពខ្ពស់ ក្នុងការយល់ដឹង និងវិភាគទៅលើស្ថានភាពនៃការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសដើម្បីបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅដល់សិស្សានុសិស្សនៅក្នុងថ្នាក់រៀន។ ការជ្រើសរើសនេះត្រូវបានសម្រេចយកវិទ្យាល័យទាំង៩ នៅក្នុងខេត្តឧត្តរមានជ័យ ហើយគ្រូបង្រៀន មុខវិជ្ជាភាសាអង់គ្លេសទាំងអស់ដែលបង្រៀននៅតាមវិទ្យាល័យទាំង៩គឺត្រូវបានជ្រើសរើសជា ភាគសំណាកដើម្បីទទួលបានព័ត៌មានជាក់លាក់ពីស្ថានភាពពិតជាក់ស្តែងដែលកំពុងកើតមាននៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យទាំងមូលដែលមានទាំងតំបន់ទីប្រជុំជនទីរួមខេត្ត ទីរួមស្រុក និងតំបន់ឆ្ងាយពីទីប្រជុំជន។ គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅវិទ្យាល័យទាំង៩នៅក្នុងខេត្តឧត្តរមានជ័យមានចំនួនសរុប១៩នាក់ ស្រី៦នាក់។ ការជ្រើសយកគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសទាំងអស់មកធ្វើជាភាគសំណាក មានន័យថាការប្រមូលទិន្នន័យនេះភាគរយនៃការចូលរួមគឺ ស្មើនឹង១០០% កាលណាភាគរយអ្នកផ្តល់ចម្លើយខ្ពស់នោះទិន្នន័យដែលទទួលបានក៏មានកម្រិតត្រឹមត្រូវ

ខ្ពស់ដូចគ្នាដែរ ព្រោះគ្មានចម្លើយណាផ្សេងទៀតក្រៅពី ចម្លើយដែលទទួលបាន មានន័យថាការសិក្សានេះ អាចទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយពីអ្នកផ្តល់ ចម្លើយទាំងអស់។

**តារាង៣.១៖ ចំនួនភាគសំណាក ភេទ និង ភាគរយ គ្រូបង្រៀនភាសាអង់គ្លេស នៅតាមវិទ្យាល័យទាំង៩ ក្នុងខេត្តឧត្តរមានជ័យ**

| ល.រ | វិទ្យាល័យ | ចំនួន | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | វិទ្យាល័យហ៊ុនសែនឧត្តរមានជ័យ | ៣ | ០ |
| ២ | វិទ្យាល័យតេជោសែនសំរោង | ៣ | ៣ |
| ៣ | វិទ្យាល័យហ៊ុនសែនចុងកាល់ | ១ | ០ |
| ៤ | វិទ្យាល័យហ៊ុនសែនពង្រ | ១ | ០ |
| ៥ | វិទ្យាល័យហ៊ុនសែនត្រពាំងប្រាសាទ | ២ | ០ |
| ៦ | វិទ្យាល័យបន្ទាយអំពិល | ២ | ០ |
| ៧ | វិទ្យាល័យអំពិល | ៣ | ២ |
| ៨ | វិទ្យាល័យតេជោសែនត្រពាំងតាវ | ២ | ១ |
| ៩ | វិទ្យាល័យអន្លង់វែង | ២ | ០ |
| **សរុបរួម** | | **១៩** | **៦** |

ដោយយោងទៅលើទីតាំង ដែលវិទ្យាល័យទាំងអស់ស្ថិតនៅសព្វទីកន្លែងទូទាំងខេត្តឧត្តរមានជ័យ ព្រមទាំងភាគសំណាកដែលជ្រើសរើសជាគ្រូបង្រៀនមុខវិជ្ជាគោលដៅសុទ្ធសាធ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះមានលក្ខណៈច្បាស់លាស់ ប្រាកដប្រជាអាចយកជាឯកសារគោលសម្រាប់ការសិក្សាទៅថ្ងៃក្រោយទៀតបាន។

## ៣.៥. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះអ្នកសិក្សាបានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យតាមកម្មវិធី SPSS Statistics តាម Descriptive Analysis ដើម្បីវិភាគទៅលើទិន្នន័យ **បែបបរិមាណវិស័យ** ប្រើប្រាស់សម្រាប់ រកតម្លៃមធ្យម (Mean) គម្លាតស្តង់ដា (Standard Diviation) ដោយប្រើតារាង និងវិភាគដោយប្រើរូបមន្ត ភាគរយ ប្រេកង់ ដែលអាចអោយយើងយកមកធ្វើការបកស្រាយពន្យល់បានតាមរយៈ Min, Max, Mean ដើម្បីវិភាគពីកម្រិតនៃភាពជឿជាក់ ឬភាពពេញចិត្តនៅក្នុងកម្រងសំណួរសម្រាប់បំពេញដោយគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យយោងតាមការបែងចែកកម្រិតដែលចងក្រងដោយ Oxford និង Burry-Stock (1995) កម្រិតមធ្យមត្រូវបានបែងចែកជាបីក្រុម គឺកម្រិតខ្ពស់ (M=3.50 ឡើង) កម្រិតមធ្យម (M=2.50 – 3.49) និងកម្រិតទាប (M=2.49 ចុះ)។

# ជំពូក៤

# លទ្ធផលស្រាវជ្រាវ និង ការពិភាក្សា

នៅក្នុងការវិភាគនេះ យើងបានចែកទិន្នន័យទៅតាមប្រភេទ និងក្រុមនីមួយៗ ហើយ ដោយជ្រើសរើសតែទិន្នន័យណាដែលចាំបាច់មកវិភាគ។ ចំពោះកម្រងសំណួរដែលបានរៀបចំ អ្នកស្រាវជ្រាវបានផ្ញើរជូនទៅអោយអ្នកឆ្លើយចំនួន១៩នាក់ ជួយបំពេញសម្រាប់កម្រងសំណួរបំពេញ ហើយប្រមូលបានមកវិញគ្រប់ចំនួន ដូច្នេះយើងមានភាគសំណាកចំនួន១៩ សម្រាប់យកមកធ្វើការវិភាគ។

ក្រោយពីទទួលបានទិន្នន័យដែលអាចយកជាការបាន តាមរយៈកម្រងសំណួរបំពេញរួចមក អ្នកស្រាវជ្រាវបានយកទិន្នន័យនោះមកវិភាគ និងបានជាលទ្ធផលដូចខាងក្រោម៖

## ៤.១. លទ្ធផលការស្រាវជ្រាវសំណួរទី១

អ្នកស្រាវជ្រាវផ្តោតសំខាន់ទៅលើ ស្ថានភាពទូទៅក្នុងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស និងគុណភាពក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធិសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តឧត្តរមានជ័យ ដោយផ្អែកទៅលើកម្រងសំណួរបំពេញដោយ គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស។ ស្ថិតិដែលប្រើសម្រាប់វិភាគរួមមាន ប្រេកង់ (Frequency) មធ្យម (Mean) និងគម្លាតស្តង់ដា (Standard Deviation) ដើម្បីវិភាគ និងបកស្រាយអំពីលទ្ធផលនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ។

នៅក្នុងផ្នែកនេះ យើងបែងចែកជាពីរផ្នែកសំខាន់ៗ គឺ ផ្នែកទី១ ទាក់ទងជាមួយនឹងស្ថានភាពនៃការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ និងផ្នែកទី២ គុណភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស (មាន៩ ចំណុច ចាប់ពីសំណួរទី១៣ ដល់ ២១)។

**តារាង ៤.១៖ ប្រេកង់ និង ភាគរយ កម្រិតបណ្តុះបណ្តាលគ្រូតាមកម្រិតថ្នាក់ មុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ** (N=19)

| កម្រិតសញ្ញាបត្របណ្តុះបណ្តាលគ្រូ | | |
|---|---|---|
| **សញ្ញាបត្រ** | ប្រេកង់ (F) | ភាគរយ(%) |
| គ្រូបង្រៀនកម្រិតមូលដ្ឋាន | 9 | 47.4 |
| គ្រូបង្រៀនកម្រិតឧត្តម | 10 | 52.6 |
| **សរុប** | **19** | **100.0** |

យោងតាមតារាងខាងលើ លទ្ធផលបង្ហាញអោយឃើញថា ក្នុងចំនោមគ្រូបង្រៀនទាំង១៩នាក់នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ មានគ្រូ១០នាក់ជាគ្រូបង្រៀនដែលមានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម ស្មើនឹង៥២.៦% និងគ្រូបង្រៀន៩នាក់ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ស្មើនឹង៤៧.៤%។ ដូចនេះយើងអាចសន្និដ្ឋានបានថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ ប្រើប្រាស់គ្រូបង្រៀនមិនទាន់បានត្រឹមត្រូវនៅឡើយទេ ដោយមានគ្រូបង្រៀន៩នាក់ ស្មើនឹង ៤៧.៤% ជាគ្រូបង្រៀនកម្រិតមូលដ្ឋានទៅបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

## តារាង៤.២៖ ចំនួនម៉ោងបង្រៀនតាមកម្រិតថ្នាក់

| ចំនួនម៉ោងបង្រៀនតាមកម្រិតថ្នាក់ | | | |
|---|---|---|---|
| កម្រិតថ្នាក់ | ម៉ោងសិក្សា | | សរុប |
| | ២ម៉ោង | ៤ម៉ោង | |
| Grade10 | 3 | 7 | **10** |
| Grade11 | 4 | 0 | **4** |
| Grade12 | 5 | 0 | **5** |
| **សរុប** | **12** | **7** | **19** |

យោងតាមតារាងខាងលើ លទ្ធផលបង្ហាញអោយឃើញថា នៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តឧត្តរមានជ័យនៅថ្នាក់ទី១០ អនុវត្តរយៈពេលបង្រៀន២ម៉ោងក្នុង១សប្តាហ៍ មាន៣នាក់ និង៤ម៉ោងក្នុង១សប្តាហ៍មាន៧នាក់ នៅថ្នាក់ទី១១ អនុវត្តរយៈពេលបង្រៀន២ម៉ោងក្នុង១សប្តាហ៍មាន ៤នាក់ និងនៅថ្នាក់ទី១២ អនុវត្តរយៈពេលបង្រៀន២ម៉ោងក្នុង១សប្តាហ៍មាន៥នាក់។ សរុបមកឃើញថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះថ្នាក់ទី១១ និងថ្នាក់ទី១២ មានភាពត្រឹមត្រូវតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយឡែកថ្នាក់ទី១០ ពុំទាន់បានត្រឹមត្រូវទាំងស្រុងតាមកម្មវិធីសិក្សានោះទេដោយនៅមានគ្រូ៣នាក់ ស្មើនឹង ១៥.៨% បង្រៀន២ម៉ោងក្នុង១សប្តាហ៍ តិចជាងចំនួនម៉ោងក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## តារាង៤.៣៖ ចំនួនម៉ោង នៃការអនុវត្តកម្មវិធីសិក្សា ធៀបជាមួយនឹងចំនួនម៉ោងដែលគ្រូបង្រៀនត្រូវការ( N=19 )

| | | ចំនួនម៉ោងដែលគ្រូបង្រៀនត្រូវការក្នុង១សប្តាហ៍ | | | | **សរុប** |
|---|---|---|---|---|---|---|
| | | ២ម៉ោង | ៣ម៉ោង | ៤ម៉ោង | ៦ម៉ោង | |
| ចំនួនម៉ោងបង្រៀន ក្នុង១សប្តាហ៍ ក្នុង១កម្រិតថ្នាក់ | ២ម៉ោង | 1 | 1 | 9 | 1 | **12** |
| | ៤ម៉ោង | 0 | 0 | 4 | 3 | **7** |
| **សរុប** | | **1** | **1** | **13** | **4** | **19** |

យោងតាមតារាងខាងលើ លទ្ធផលបង្ហាញអោយឃើញថា នៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តឧត្តរមានជ័យ ចំនួនម៉ោងបង្រៀន២ម៉ោងក្នុង ១សប្តាហ៍ មាន១២នាក់ តែចំនួនម៉ោងដែលគ្រូយល់ថាគ្រប់គ្រាន់គឺ ២ម៉ោង ក្នុង១សប្តាហ៍ មាន១នាក់ ៣ម៉ោងក្នុង១សប្តាហ៍មាន០១នាក់ ៤ម៉ោងក្នុង១សប្តាហ៍មាន៩នាក់ និង៦ម៉ោងក្នុង១សប្តាហ៍មាន០១នាក់។ ចំនួនម៉ោងបង្រៀន៤ម៉ោងក្នុង ១សប្តាហ៍មាន៧នាក់ តែចំនួនម៉ោងដែលគ្រូយល់ថាគ្រប់គ្រាន់គឺ៤ម៉ោង ក្នុង១សប្តាហ៍មាន៤នាក់ និង៦ម៉ោងក្នុង១សប្តាហ៍មាន៣នាក់។ ដូចនេះតាមការបកស្រាយបង្ហាញ អោយឃើញថាចំពោះ ម៉ោងបង្រៀនដែលល្អជាងគេគឺ ៤ម៉ោងក្នុង១សប្តាហ៍ក្នុង១កម្រិតថ្នាក់ ដែលគ្រូបង្រៀនភាគច្រើនចង់បាន (១៣នាក់ស្មើនឹង៦៨.៤% ក្នុងចំណោមគ្រូបង្រៀនភាសាអង់គ្លេសទាំង១៩នាក់ នៅខេត្តឧត្តរ មានជ័យ)។

**តារាង៤.៤៖ មធ្យម គម្លាតស្តង់ដា នៃរយៈពេលបង្រៀន ១សប្តាហ៍ ក្នុង១កម្រិតថ្នាក់ ធៀបជាមួយនឹងខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល** (N=19)

| រយៈពេលនៃការបង្រៀនក្នុង១សប្តាហ៍ ធៀបជាមួយនឹងខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល | |
|---|---|
| មធ្យម(Mean) | គម្លាតស្តង់ដា (Std) |
| 2.58 | 0.77 |

តាមលទ្ធផលក្នុងតារាងខាងលើ បង្ហាញថារយៈពេលនៃការបង្រៀន ក្នុង១សប្តាហ៍ ក្នុងមួយកម្រិតថ្នាក់ ធៀបជាមួយខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល មានមធ្យមស្មើនឹង២.៥៨ (M=2.58) ជាមធ្យមកម្រិតមធ្យមទាប។ មានន័យថាពេលវេលានៃការបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ក្នុង១សប្តាហ៍ក្នុងមួយកម្រិតថ្នាក់ នៅមិនទាន់សមស្របជាមួយនឹងខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលនៅឡើយទេ ដោយសារក្នុង១សប្តាហ៍ត្រូវបង្រៀន៤ម៉ោង ស្មើនឹង២ជំពូក នៅថ្នាក់ទី១០ និងបង្រៀន២ម៉ោង ស្មើនឹង១ជំពូក នៅកម្រិតថ្នាក់ទី១១ និងទី១២ (ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស របស់ក្រសួង អប់រំ យុវជន និងកីឡា) ហើយក្នុងមួយជំពូកៗ គឺមានខ្លឹមសារមេរៀនច្រើនដូច្នេះត្រូវប្រើ ពេលវេលាបង្រៀនច្រើនម៉ោងក្នុង១ជំពូក ទើបសមស្របជាមួយនឹងខ្លឹមសារនៅក្នុងសៀភៅសិក្សាគោល។

**តារាង៤.៥៖ មធ្យម គម្លាតស្តង់ដា នៃខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល ធៀបជាមួយនឹងពេលវេលាបង្រៀនក្នុង១ឆ្នាំសិក្សា** (N=19)

| **ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល ធៀបជាមួយនឹងរយៈពេលបង្រៀនក្នុង១ឆ្នាំសិក្សា** | |
|---|---|
| មធ្យម (Mean) | គម្លាតស្តង់ដា (Std) |
| 2.53 | 0.96 |

តាមលទ្ធផលក្នុងតារាងខាងលើ បង្ហាញថារយៈពេលនៃការបង្រៀនក្នុង១ឆ្នាំសិក្សា ក្នុងមួយកម្រិតថ្នាក់ ធៀបជាមួយខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល មានមធ្យមស្មើនឹង២.៥៣ (M=2.53) ជាមធ្យម កម្រិតមធ្យមទាប។ មានន័យថាខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាអង់គ្លេ មិនទាន់សមស្របជាមួយនឹងពេលវេលានៃការបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ក្នុង១កម្រិតថ្នាក់ ក្នុង១ឆ្នាំសិក្សនៅឡើយទេ មានន័យថាពេលវេលាបង្រៀនតិច តែសៀវភៅសិក្សាគោលមានច្រើនមេរៀន ខ្លឹមសារមេរៀនច្រើន (មាន២០មេរៀន ស្មើនឹង៦០ជំពូក ក្នុង១ឆ្នាំសិក្សា) ដូចច្នេះពេលវេលាប៉ុណ្ណឹង មិនអាចបង្រៀនបានចប់ ឬទាន់កម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា នោះទេ។

**តារាង៤.៦៖ មធ្យម គម្លាតស្តង់ដា នៃខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល ធៀបជាមួយនឹងសមត្ថភាពសិស្ស** (N=19)

| **ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល ធៀបនឹង សមត្ថភាពសិស្ស** | |
|---|---|
| មធ្យម (Mean) | គម្លាតស្តង់ដា (Std) |
| 2.47 | 0.90 |

តាមលទ្ធផលក្នុងតារាងខាងលើ បង្ហាញថាខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល ធៀបជាមួយនឹងសមត្ថភាពសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ មានមធ្យមស្មើនឹង២.៤៧ (M=2.47) មានតម្លៃទាបជាង២.៥០ ជាមធ្យមកម្រិតទាប។ មានន័យថាខ្លឹមសារនៅក្នុងសៀវភៅ សិក្សាគោលមុខវិជ្ជាអង់គ្លេស មិនសមស្របជាមួយនឹងសមត្ថភាពសិស្សនោះឡើយ គឺខ្លឹមសារនៅក្នុង សៀវភៅសិក្សាគោលមានកម្រិតខ្ពស់ជាងសមត្ថភាពសិស្ស។

**តារាង៤.៧៖ មធ្យម គម្លាតស្តង់ដា នៃខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល ធៀបជាមួយនឹងសមត្ថភាពគ្រូ** (N=19)

| ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល ធៀបនឹង សមត្ថភាពគ្រូបង្រៀន | |
|---|---|
| មធ្យម (Mean) | គម្លាតស្តង់ដា (Std) |
| 3.21 | 0.79 |

តាមលទ្ធផលក្នុងតារាងខាងលើ បង្ហាញថាខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល ធៀបជាមួយនឹងសមត្ថភាពគ្រូបង្រៀន នៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ មានមធ្យមស្មើនឹង ៣.២១ (M=3.21) ជាមធ្យម កម្រិតមធ្យមខ្ពស់។ មានន័យថាខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាអង់គ្លេស នឹងសមត្ថភាពគ្រូបង្រៀនគឺមានភាពសមស្របគ្នា។

**តារាង៤.៨៖ មធ្យម គម្លាតស្តង់ដា នៃស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋ ពេញលេញនៅក្នុងកម្មវិធីសិក្សា** (N=19)

| ល.រ | ខ្លឹមសារ | កម្រិតអនុវត្ត | | |
|---|---|---|---|---|
| | | មធ្យម (Mean) | គម្លាតស្តង់ដា (Std) | កម្រិត |
| ១ | តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍបំណិនក្នុងការទំនាក់ទំនងរបស់សិស្សដែរឬទេ? | 2.79 | 0.98 | **មធ្យម** |
| ២ | តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភវឌ្ឍបំណិនក្នុងការសហការ ឬកិច្ចសហប្រតិបត្តិការរបស់សិស្សដែរឬទេ? | 2.95 | 0.78 | **មធ្យម** |
| ៣ | អ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃ នេះមានគុណភាពក្នុងការអភិវឌ្ឍបំណិនក្នុងការតស៊ូមតិ ឬការ ដឹកនាំរបស់សិស្សដែរឬទេ? | 2.63 | 0.95 | **មធ្យម** |

| | | | | |
|---|---|---|---|---|
| ៤ | តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍការគិត ឬការត្រិះរិះពិចារណារបស់សិស្សដែរឬទេ? | 3.21 | 0.79 | **មធ្យម** |
| ៥ | តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍគំនិតបង្កើតថ្មី និងការច្នៃ ប្រឌិតរបស់សិស្សដែរឬទេ? | 2.74 | 0.87 | **មធ្យម** |
| ៦ | តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍការវិភាគ និងការដោះ ស្រាយបញ្ហារបស់សិស្សដែរឬទេ? | 2.84 | 0.83 | **មធ្យម** |
| ៧ | តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះ មានគុណភាពអភិវឌ្ឍសមត្ថភាពក្នុងការបន្តការសិក្សាពេញមួយជីវិតរបស់សិស្សដែរឬទេ? | 3.26 | 0.87 | **មធ្យម** |
| ៨ | តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះ មានគុណភាពអភិវឌ្ឍសមត្ថភាពសិក្សា និងការរស់នៅរបស់សិស្ស ក្នុងបរិបទទំនើបនៃបច្ចេកវិទ្យាដែរឬទេ? | 2.84 | 0.90 | **មធ្យម** |
| ៩ | តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស សព្វថ្ងៃនេះ មានគុណភាពក្នុងការអភិវឌ្ឍការសិក្សាស្រាវជ្រាវរបស់សិស្សដែរឬទេ? | 2.89 | 0.81 | **មធ្យម** |
| **សរុប** | | **2.90** | **0.86** | **មធ្យម** |

យោងតាមតារាងខាងលើ លទ្ធផលបានបង្ហាញថាការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅក្នុងខេត្តឧត្តរមានជ័យ គឺចាប់ពីកម្រិត៣.២៦ រហូតដល់កម្រិត២.៦៣។ មានន័យថាត្រង់ចណុច៧៖ គុណភាពនៃការអភិវអភិវឌ្ឍសមត្ថភាពក្នុងការបន្តការសិក្សាពេញមួយជីវិតរបស់សិស្ស គឺមានមធ្យម៣.២៦ (M=3.26) និងបន្តរបន្ទាប់តាមចំណុចនីមួយៗគឺចំណុច៤៖ គុណភាពក្នុងការអភិវឌ្ឍការគិត ឬការត្រិះរិះពិចារណា មានមធ្យម៣.២១ (M=3.21)។

ចំណុច ២៖ គុណភាពក្នុងការអភិវឌ្ឍបំណិនក្នុងការសហការ ឬកិច្ចសហប្រតិបត្តិការរបស់សិស្សមានមធ្យម២.៩៥ (M=2.95)។ ចំណុច៩៖ គុណភាពក្នុងការអភិវឌ្ឍការសិក្សាស្រាវជ្រាវរបស់សិស្ស មានមធ្យម២.៨៩ (M=2.89)។ ចំណុច៦៖ គុណភាពក្នុងការអភិវឌ្ឍការវិភាគ និងការដោះស្រាយ បញ្ហារបស់សិស្ស មានមធ្យម២.៨៤ (M=2.84)។ ចំណុច៨៖ មានគុណភាពអភិវឌ្ឍសមត្ថភាពសិក្សា និងការរស់នៅរបស់សិស្សក្នុងបរិបទទំនើបនៃបច្ចេក មានមធ្យម២.៨៤ (M=2.84)។ ចំណុច១៖ គុណភាពក្នុងការអភិវឌ្ឍបំណិនក្នុងការទំនាក់ទំនងរបស់សិស្ស មានមធ្យម២.៧៩ (M=2.79)។ ចំណុច៥៖ គុណភាពក្នុងការអភិវឌ្ឍគំនិតបង្កើតថ្មី និងការច្នៃប្រឌិត មានមធ្យម២.៧៤ (M=2.74) និងចុងក្រោយ គឺចំណុច៣៖ គុណភាពក្នុងការអភិវឌ្ឍបំណិនក្នុងការតស៊ូមតិ ឬការដឹកនាំរបស់សិស្ស មានមធ្យម២.៦៣ (M=2.63)។

ជារួមតាមលទ្ធផលតារាងខាងលើបង្ហាញថា យើងអាចបញ្ជ្រាប សមត្ថភាពក្នុងការបន្តការសិក្សាពេញមួយជីវិតរបស់សិស្ស និងសមត្ថភាពក្នុងការអភិវឌ្ឍការគិត ឬការត្រិះរិះពិចារណា តាមរយៈកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសបានល្អ ជាងបំណិនដទៃទៀត ដោយបំណិនទាំងពីរនេះមាន មធ្យមខ្ពស់ជាងគេ ហើយបំណិតដទៃទៀតក៏មានតម្លៃ ប្រហាក់ប្រហែលគ្នាដោយមានមធ្យម កម្រិតមធ្យមទាំងអស់ គ្មានមធ្យមកម្រិតទាបនោះទេ។ អាស្រ័យដូចនេះបង្ហាញអោយឃើញថា ការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅក្នុងខេត្តឧត្តរមានជ័យ គឺស្ថិតនៅកម្រិតមធ្យមទាប ដែលមានមធ្យមសរុប ២.៩០ (M=2.90) និងមានគម្លាតស្តង់ដា ០.៨៦ (Sdt=0.86)។

## ៤.២. លទ្ធផលនៃការស្រាវជ្រាវសំណួរទី២

បញ្ហាប្រឈមនានាដែលកើតមានលើដំណើរការអនុវត្តកម្មវិធី សិក្សាមុខវិជ្ជាភាសាអង់គ្លេស និងបញ្ហារាំងស្ទះក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធិ សិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តឧត្តរមានជ័យ ដោយផ្អែកទៅលើកម្រងសំណួរបំពេញដោយគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយ។ ស្ថិតិដែល ប្រើសម្រាប់វិភាគរួមមានមធ្យម

(Mean) និងគម្លាតស្តង់ដា (Standard Deviation) ដើម្បីវិភាគ និងបកស្រាយអំពីបញ្ហាប្រឈមនានានៃការបញ្ជ្រាបការអប់រំពេលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជា ភាសាអង់គ្លេសនៅខេត្តឧត្តរមានជ័យ។

នៅក្នុងផ្នែកនេះ ជាលទ្ធផល ឬជាចម្លើយដែលផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលនៅក្នុងសំណួរស្រាវជ្រាវទី១ ត្រូវបានបែងចែកជាពីរផ្នែកសំខាន់ៗ ផ្នែកទី១ចាប់ពីសំណួរទី១០ រហូតដល់ទី២១ ស្តីពីបញ្ហាប្រឈមនានាដែលកើតមានក្នុងដំណើរការបញ្ជ្រាបការអប់រំពេលរដ្ឋពេញលេញ ទៅក្នុងកម្មវិធី សិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ និងផ្នែកទី២ត្រង់សំណួរទី២២ បង្ហាញអំពីវិធីសាស្ត្រដែលធ្វើអោយការបញ្ជ្រាបការអប់រំមានភាពល្អប្រសើរ ដែលវិភាគចេញ ជាតារាងដូចខាងក្រោម៖

**តារាង៤.៩៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមនៃខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាអង់គ្លេសធៀបជាមួយនឹង ពេលវេលាបង្រៀនក្នុង១ឆ្នាំសិក្សា** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា (Std) | កម្រិត |
|---|---|---|---|---|
| 1 | ម៉ោងតិច តែសកម្មភាព និង កិច្ចការ ឬលំហាត់ដែលត្រូវអនុវត្តច្រើនពេក | 1.4 | 0.5 | **ខ្សោយ** |
| 2 | មូលដ្ឋានចំណេះដឹងភាសាអង់គ្លេសរបស់សិស្សខ្សោយ និង ចម្រុះសមត្ថភាពរបស់សិស្ស | 1.7 | 0.5 | **ខ្សោយ** |
| 3 | ខ្លឹមសារនៃមេរៀនខ្ពស់ មានចំណុចពិបាកៗច្រើន ស្មុគស្មាញ គ្មានលំដាប់លំដោយ ពិបាកបង្រៀន ចំណាយពេលវេលាច្រើនក្នុងការបង្រៀន។ | 1.7 | 0.5 | **ខ្សោយ** |
| **សរុប** | | **1 .6** | **0.5** | **ខ្សោយ** |

យោងទៅលើតារាងខាងលើ បង្ហាញអំពីបញ្ហាប្រឈមដែលមានចំពោះខ្លឹមសារនៃមេរៀននៅក្នុងសៀវភៅសិក្សាគោល ធៀបជាមួយពេលវេលាបង្រៀនក្នុង១ឆ្នាំសិក្សាមានបីចំណុចចំបងៗ គឺ ទី១ ម៉ោងបង្រៀនតិច តែសកម្មភាព និង កិច្ចការឬ លំហាត់ដែលត្រូវអនុវត្តច្រើនពេក មានមធ្យម ១.៤ (Mean =1.4) ទី២ មូលដ្ឋានចំនេះដឹងភាសាអង់គ្លេសរបស់សិស្សខ្សោយ និង ចម្រុះសមត្ថភាពរបស់សិស្ស មានមធ្យម ១.៧ (Mean=1.7) និង ទី៣ គឺ ខ្លឹមសារនៃមេរៀនខ្ពស់ មានចំណុចពិបាកពិបាកច្រើន ស្មុគស្មាញ គ្មានលំដាប់លំដោយ ពិបាកបង្រៀន ចំណាយពេលវេលាច្រើនក្នុងការបង្រៀន មានមធ្យម ១.៧ (Mean=1.7)។ សរុបជារួមបញ្ហាទាំងបីចំណុចខាងលើនេះ មានមធ្យមប្រហាក់ប្រហែលគ្នាគឺ ចំណុចទី១ ១. ៤ និង ចណុចទី២ និង ទី៣ មានមធ្យម ១.៧ ។ សរុបមានមធ្យមភាគ ១.៦ ជាមធ្យមកម្រិតទាប និង គម្លាតស្តង់ដា ០.៥ មានន័យថា ចំពោះខ្លឹមសារនៃមេរៀននៅក្នុងសៀវភៅសិក្សាគោល ធៀបជាមួយពេលវេលាបង្រៀនក្នុង១ឆ្នាំសិក្សា នៅមានបញ្ហាប្រឈម តែជាបញ្ហាកម្រិតស្រាល។

**តារាង៤.១០៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមនៃខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាអង់គ្លេសធៀបជាមួយនឹងសមត្ថភាពរបស់សិស្ស** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | **កម្រិត** |
|---|---|---|---|---|
| 1 | សិស្សភាគច្រើនមានមូលដ្ឋានចំណេះដឹងទាប | 1.4 | 0.5 | **ខ្សោយ** |
| 2 | ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមានកម្រិតខ្ពស់ លំបាក និងមានភាពស្មុគស្មាញច្រើន | 1.7 | 0.5 | **ខ្សោយ** |
| 3 | សៀវភៅសិក្សាគោលចាស់ពេក គ្មានការធ្វើបច្ចុប្បន្នភាព មិនសមស្របជាមួយនឹងបរិបទក្នុងការរស់នៅរបស់សិស្ស | 1.8 | 0.4 | **ខ្សោយ** |

| | | | | |
|---|---|---|---|---|
| 4 | សិស្សភាគច្រើនមិនអោយតម្លៃ ឬមិនចាប់អារម្មណ៍ការសិក្សា មុខវិជ្ជាភាសាអង់គ្លេសដោយសារមិនមែនជាមុខវិជ្ជាគោលគ្មានការប្រឡង មានរបបពិន្ទុតិច ឬជាពិន្ទុបន្ថែម។ | 1.9 | 0.2 | **ខ្សោយ** |
| **សរុប** | | **1.7** | **0.4** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះខ្លឹមសារនៃមេរៀនក្នុងសៀវភៅសិក្សាគោលធៀប ជាមួយនឹងសមត្ថភាពរបស់សិស្ស គឺមានកត្តា៤យ៉ាង ជាចំណុចសំខាន់គឺ ទី១សិស្សភាគច្រើនមានមូលដ្ឋានចំណេះដឹងទាប មានមធ្យម១.៤ (Mean=1.4) ទី២ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមានកម្រិតខ្ពស់ លំបាក និងមានភាពស្មុគស្មាញច្រើន មានមធ្យម១.៧ (Mean=1.7) ទី៣ សៀវភៅសិក្សាគោលចាស់ពេក គ្មានការធ្វើបច្ចុប្បន្នភាព មិនសមស្របជាមួយនឹងបរិបទក្នុងការរស់នៅរបស់សិស្ស មានមធ្យម១.៨ (Mean=1.8) និងទី៤សិស្សភាគច្រើនមិនអោយតម្លៃ ឬមិនចាប់អារម្មណ៍ការសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដោយសារមិនមែនជាមុខវិជ្ជាគោលដែលមានការប្រឡងមានរបបពិន្ទុតិច ឬជាពិន្ទុបន្ថែម មានមធ្យម១.៩ (Mean=1.9)។ ជារួមចំពោះបញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសចំពោះខ្លឹមសារនៃមេរៀនធៀបជាមួយសមត្ថភាពសិស្សគឺមានបួនចំណុច ដែលមានមធ្យមប្រហាក់ប្រហែលគ្នា គឺ ចំណុចទី១ មានមធម្យម១.៤ ទី២ មធ្យម១.៧ ទី៣ មធ្យម១.៨ និងទី៤ មធ្យម១.៩។ សរុបរួម ចំណុចទាំងបួនមានមធ្យមភាគ១.៧ ជាមធ្យមកម្រិតទាប និងមានគម្លាតស្តង់ដា០.៤ ដូច្នេះមានន័យថាបញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះខ្លឹមសារនៃមេរៀនក្នុងសៀវភៅសិក្សាគោលធៀបជាមួយនឹងសមត្ថភាពរបស់សិស្ស មានបញ្ហាប្រឈម៤ចំណុចសំខាន់តាមលទ្ធផលខាងលើ។

**តារាង៤.១១៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមនៃខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាអង់គ្លេស ធៀបជាមួយនឹងសមត្ថភាពរបស់គ្រូបង្រៀន** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា (Std) | កម្រិត |
|---|---|---|---|---|
| 1 | មេរៀនមួយចំនួន នៅក្នុងសៀវភៅសិក្សាមានភាពស្មុគស្មាញ និង កម្រិតខ្ពស់ ពិបាកក្នុងការបង្រៀន | 1.8 | 0.4 | **ខ្សោយ** |
| 2 | សៀវភៅសិក្សាគោល ខ្លឹមសារចាស់ គ្មានការធ្វើបច្ចុប្បន្នភាព មិនសមស្របជាមួយនឹងបរិបទនៃការរស់នៅរបស់សិស្ស | 1.8 | 0.4 | **ខ្សោយ** |
| **សរុប** | | **1.8** | **0.4** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះខ្លឹមសារនៃមេរៀនក្នុងសៀវភៅសិក្សាគោល ធៀបជាមួយនឹងសមត្ថភាពគ្រូបង្រៀន គឺមានកត្តា២យ៉ាងជាចំណុចប្រឈម គឺទី១ មេរៀនមួយចំនួន នៅក្នុងសៀវភៅសិក្សា មានភាពស្មុគស្មាញ និងកម្រិតខ្ពស់ពិបាកក្នុងការបង្រៀន មានមធ្យម១.៨ (Mean=1.8) និងទី២ សៀវភៅសិក្សាគោល ខ្លឹមសារចាស់ គ្មានការធ្វើបច្ចុប្បន្នភាព មិនសមស្របជាមួយនឹងបរិបទបច្ចុប្បន្ន មានមធ្យម១.៨ (Mean=1.8)។ ចំណុចទាំងពីរនេះមាន មធ្យមស្មើគ្នាគឺ១.៨ ជាមធ្យមកម្រិតទាប និងមានគម្លាតស្តង់ដា០.៤ មានន័យថាចំពោះសមត្ថភាពគ្រូបង្រៀនធៀបជាមួយនឹងខ្លឹមសារ នៅក្នុងសៀវភៅសិក្សាគោលគឺនៅមានបញ្ហាប្រឈមតិចតួចបំផុត។

**តារាង៤.១២៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនទំនាក់ទំនងរបស់សិស្ស** (N=19)

| ល.រ | ខ្លឹមសារ | កម្រិតអនុវត្ត | | |
|---|---|---|---|---|
| | | មធ្យម (Mean) | គម្លាតស្តង់ដា (Std) | កម្រិត |
| ១ | ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមិនសូវសមស្រប ជាមួយនឹង ជំនាញទំនាក់ទំនង និងមេរៀនដែលទាក់ ទងមានតិចតួចបំផុត | 1.7 | 0.4 | **ខ្សោយ** |
| ២ | គ្រូបង្រៀនភាគច្រើនមិនដែលបានចូលរួមវគ្គបណ្តុះបណ្តាលនូវ ជំនាញថ្មីដើម្បីបង្រៀនសិស្ស | 1.9 | 0.3 | **ខ្សោយ** |
| ៣ | គ្រូបង្រៀនភាគច្រើនមិនបានផ្តោតការយកចិត្តទុក ដាក់លើសកម្មភាព ឬជំនាញទំនាក់ទំនងដោយផ្តោតសំខាន់ទៅលើតែការបង្រៀនភាសាអង់គ្លេស | 1.9 | 0.3 | **ខ្សោយ** |
| ៤ | សមត្ថភាពរបស់សិស្សមានកម្រិតទាបជាងសៀវភៅសិក្សាគោលសិស្សភាគច្រើនមានមូលដ្ឋានភាសាអង់គ្លេសតិច ដូច្នេះ ពិបាក បញ្ជ្រាប | 1.6 | 0.5 | **ខ្សោយ** |
| ៥ | ភាសាអង់គ្លេសមិនត្រូវបានប្រើប្រាស់ជាទូទៅសិស្សានុសិស្ស និង មនុស្សភាគច្រើនមិនមានចំណាប់ អារម្មណ៍ ហើយគិតថាការរៀនភាសាអង់គ្លេសគ្មានសារៈប្រយោជន៍ | 1.8 | 0.4 | **ខ្សោយ** |
| ៦ | គ្មានពេលវេលាគ្រប់គ្រាន់សម្រាប់ការអនុវត្តក្នុងថ្នាក់ | 1.9 | 0.2 | **ខ្សោយ** |
| **សរុប** | | **1.8** | **0.3** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការអភិវឌ្ឍបំណិនទំនាក់ទំនងរបស់សិស្ស មាន៦ចំណុច ដែលមានមធ្យមប្រហាក់ប្រហែលគ្នាពីមធ្យម១.៦ ដល់ មធ្យម១.៩ មានទី១ ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមិនសូវសមស្របជាមួយនឹងជំនាញទំនាក់ទំនង និងមេរៀនដែលទាក់ទងមានតិចតួចបំផុត មានមធ្យម១.៧ (Mean=1.7) និងទី២ គ្រូបង្រៀនភាគច្រើនមិនដែលបានចូលរួមវគ្គបណ្តុះបណ្តាលនូវជំនាញថ្មី ដើម្បីបង្រៀនសិស្ស មានមធ្យម១.៩ (Mean=1.9) ទី៣ គ្រូបង្រៀនភាគច្រើនមិនបានផ្តោតការយកចិត្ត ទុកដាក់លើសកម្មភាព ឬជំនាញទំនាក់ទំនង ដោយផ្តោតសំខាន់ទៅលើតែការបង្រៀនភាសាអង់គ្លេស មានមធ្យម១.៩ (Mean=1.9) ទី៤ សមត្ថភាពរបស់សិស្សមានកម្រិតទាបជាងសៀវភៅសិក្សាគោល សិស្សភាគច្រើនមានមូលដ្ឋានភាសាអង់គ្លេសខ្សោយពិបាកក្នុងការបញ្ជ្រាបមានមធ្យម១.៦ (Mean=1.6) ទី៥ ភាសាអង់គ្លេសមិនត្រូវបានប្រើប្រាស់ជាទូទៅ សិស្សានុសិស្ស និង មនុស្សភាគច្រើនមិនមាន ចំណាប់អារម្មណ៍ ហើយគិតថាការរៀនភាសាអង់គ្លេសគ្មានសារៈប្រយោជន៍ មានមធ្យម១.៨ (Mean=1.8) និងទី៦ គ្មានពេលវេលាគ្រប់គ្រាន់សម្រាប់ការអនុវត្តក្នុងថ្នាក់ មានមធ្យម១.៩ (Mean=1.9)។ យោងទៅលើលទ្ធផលខាងលើនេះ ការបញ្ជ្រាបសមត្ថភាពក្នុងការអភិវឌ្ឍ បំណិន ក្នុងការទំនាក់ទំនង ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅ ខេត្តឧត្តរមានជ័យ នៅមានបញ្ហាប្រឈមជាច្រើនចំណុចតាមចំណុចទាំង៦នេះ និងមានមធ្យមសរុប១.៨ (Mean=1.8) ជាមធ្យមកម្រិតទាប និង មានគម្លាតស្តង់ដា ០.៣។

**តារាង៤.១៣៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិន កិច្ចសហប្រតិបត្តិការរបស់សិស្ស** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | កម្រិត |
|---|---|---|---|---|
| 1 | ការបង្រៀនផ្តោតលើមេរៀន ឬទ្រឹស្តី មិនផ្តោតលើការអនុវត្ត | 1.9 | 0.3 | **ខ្សោយ** |
| 2 | សិស្សមានចំណេះដឹងមូលដ្ឋានអង់គ្លេសទាប តែខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមានកម្រិតខ្ពស់ | 1.8 | 0.4 | **ខ្សោយ** |
| 3 | គ្រូបង្រៀនខ្វះសមត្ថភាពក្នុងការបង្រៀនជំនាញនេះ ឯសិស្សមិនអនុវត្ត ឬ ខ្វះការអនុវត្ត | 1.8 | 0.4 | **ខ្សោយ** |
| 4 | មានមេរៀនដែលទាក់ទងជំនាញសហប្រតិបត្តិការតិចតួចបំផុតនៅក្នុងសៀវភៅសិក្សាគោល | 1.8 | 0.4 | **ខ្សោយ** |
| 5 | សិស្សភាគច្រើនមិនអាចប្រើប្រាស់ភាសាអង់គ្លេសបាន ពួកគេមិនអាចអនុវត្ត ឬ មិនសូវអនុវត្ត | 1.8 | 0.4 | **ខ្សោយ** |
| **សរុប** | | **1.8** | **0.4** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំ ពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការអភិវឌ្ឍបំណិនសហប្រតិបត្តិការរបស់សិស្ស មាន៥ចំណុចដែល ចំណុចទី១ ការបង្រៀនផ្តោតលើមេរៀន ឬទ្រឹស្តី មិនផ្តោតលើការអនុវត្ត មានមធ្យម១.៩ (Mean=1.9) និងចំណុច ទី២ដល់ទី៥ មានមធ្យមស្មើគ្នាគឺ មធ្យម១.៨ (Mean=1.8) ដែលមានខ្លឹមសារដូចតទៅ៖ ចំណុចទី២ សិស្សមានចំណេះដឹងមូលដ្ឋានអង់គ្លេសទាប តែខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមានកម្រិតខ្ពស់ ទី៣ គ្រូបង្រៀនខ្វះសមត្ថភាពក្នុងការបង្រៀនជំនាញនេះ ឯសិស្សមិនអនុវត្ត ឬ ខ្វះការ

អនុវត្ត ទី៤ មេរៀនដែលទាក់ទងជំនាញសហប្រតិបត្តិការមានតិចតួចបំផុតនៅក្នុងសៀវភៅសិក្សាគោល និងចំណុចទី៥ សិស្សភាគច្រើនមិនអាចប្រើប្រាស់ភាសាអង់គ្លេសបាន ពួកគេមិនអាចអនុវត្ត ឬ មិនសូវអនុវត្ត។ សរុបរួមការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការអភិវឌ្ឍបំណិនកិច្ចសហប្រតិបត្តិការ មានបញ្ហាប្រឈម៤ចំណុច ដោយមានមធ្យមសរុប១.៨ (Mean=1.8) ជាមធ្យមកម្រិតទាប និងមានគម្លាតស្តង់ដា០.៤។

**តារាង៤.១៤៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិននៃភាពជាអ្នកដឹកនាំ ឬ ការតស៊ូមតិរបស់សិស្ស** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | កម្រិត |
|---|---|---|---|---|
| 1 | ថ្នាក់រៀនមានសិស្សច្រើនពេកក្នុង១ថ្នាក់ៗ ពិបាកក្នុងការអនុវត្ត | 1.9 | 0.2 | **ខ្សោយ** |
| 2 | កម្មវិធីសិក្សាគ្មានទំនាក់ទំនងជាមួយនឹងភាពជាអ្នកដឹកនាំ ឬ ការតស៊ូមតិ | 1.8 | 0.4 | **ខ្សោយ** |
| 3 | សិស្សានុសិស្សខ្សោយក្នុងការអាន ការស្តាប់ ការនិយាយ គ្មានភាពក្លាហាន គ្មានទំនុកចិត្តក្នុងការនិយាយភាសាអង់គ្លេស ខ្វះខាតភាពជាអ្នកដឹកនាំ ឬ តស៊ូមតិ | 1.4 | 0.5 | **ខ្សោយ** |
| 4 | សំណួរ លំហាត់ ឬ មេរៀននៅក្នុងសៀវភៅសិក្សាគោលមិនទាក់ទងជាមួយនឹងការតស៊ូមតិ និង ភាពជាអ្នកដឹកនាំ និង មានការអនុវត្តការនិយាយតិចតួចបំផុត | 1.8 | 0.4 | **ខ្សោយ** |
| **សរុប** | | **1.7** | **0.3** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំ ពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការអភិវឌ្ឍបំណិនក្នុងការតស៊ូមតិ និង ភាពជាអ្នកដឹកនាំ របស់សិស្ស មាន៤ចំណុច ដែលមានមធ្យម១.៤មាន១ចំណុច មធ្យម១.៨ មាន២ចំណុច និងមធ្យម១.៩ មាន ១ចំណុច។ ចំណុចទី១ ថ្នាក់រៀនមានសិស្សច្រើនពេកក្នុង១ថ្នាក់ៗពិបាកក្នុងការអនុវត្តមានមធ្យម១.៩ (Mean=1.9) ចំណុចទី២ កម្មវិធីសិក្សាគ្មានទំនាក់ទំនងជាមួយនឹងភាពជាអ្នកដឹកនាំ ឬការតស៊ូមតិ មានមធ្យម១.៨ (Mean=1.8) ចំណុចទី៣ សិស្សានុសិស្សខ្សោយក្នុងការអាន ការស្តាប់ ការនិយាយ គ្មានភាពក្លាហាន គ្មានទំនុកចិត្តក្នុងការនិយាយភាសាអង់គ្លេស ខ្វះខាតភាពជាអ្នកដឹកនាំ ឬតស៊ូមតិ មានមធ្យម១.៤ (Mean=1.4) និងចំណុចទី៤ សំណួរ លំហាត់ ឬមេរៀននៅក្នុងសៀវភៅសិក្សាគោល មិនទាក់ទងជាមួយនឹងការតស៊ូមតិ និងភាពជាអ្នកដឹកនាំ និងមានការអនុវត្តការនិយាយតិចតួចបំផុត មានមធ្យម១.៨ (Mean=1.8)។ សរុបរួមការបញ្ជ្រាបបំណិនភាពជាអ្នកដឹកនាំ ឬការតស៊ូមតិទៅក្នុងកម្ម វិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមានបញ្ហាប្រឈម៤ចំណុចសំខាន់ៗ ដោយមានមធ្យមភាគ១.៧ ជាមធ្យមកម្រិតទាប និង មានគម្លាតស្តង់ដា០.៣ ។

**តារាង៤.១៥៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិននៃការគិតពិចារណារបស់សិស្ស** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | កម្រិត |
|---|---|---|---|---|
| 1 | សៀវភៅសិក្សាគោលហាក់ដូចជាសៀវភៅប្រវត្តិវិទ្យា គ្មានការធ្វើបច្ចុប្បន្នភាពថ្មី | 1.9 | 0.2 | **ខ្សោយ** |
| 2 | គ្រូបង្រៀនមិនបានបញ្ជ្រាប ឬមិនដឹងថាត្រូវបញ្ជ្រាបដូចម្តេច | 1.9 | 0.2 | **ខ្សោយ** |

| | | | | |
|---|---|---|---|---|
| 3 | ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមិនផ្តោតសំខាន់លើកបំណិនក្នុងការគិតពិចារណា ភាគច្រើនគឺផ្តោតសំខាន់តែលើការ សិក្សាភាសាអង់គ្លេស | 1.9 | 0.3 | **ខ្សោយ** |
| 4 | សិស្សភាគច្រើនខ្សោយ ពួកគេមិនមានគំនិតពិចារណា ហើយគិតថាការរៀនភាសាអង់គ្លេសគ្មានប្រយោជន៍ | 1.6 | 0.5 | **ខ្សោយ** |
| **សរុប** | | **1.9** | **0.3** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការអភិវឌ្ឍបំណិនក្នុងគិតពិចារណា របស់សិស្ស មាន៤ចំណុច ដែលមានមធ្យម១.៦ មាន១ចំណុច និងមធ្យម១.៩ មាន៣ចំណុច។ចំណុចទី១ សៀវភៅសិក្សាគោលហាក់ដូចជាសៀវភៅប្រវត្តិវិទ្យា គ្មានការធ្វើបច្ចុប្បន្នភាពថ្មី មានមធ្យម១.៩ (Mean=1.9) ចំណុចទី២ គ្រូបង្រៀនមិនបានបញ្ជ្រាប ឬ មិនដឹងថាត្រូវបញ្ជ្រាបដូចម្តេច មានមធ្យម១.៩ (Mean=1.9) ចំណុចទី៣ ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមិនផ្តោតសំខាន់លើកបំណិនក្នុងការគិតពិចារណា ភាគច្រើនគឺផ្តោតសំខាន់តែលើការសិក្សាភាសាអង់គ្លេសមានមធ្យម១.៩ (Mean=1.9) និងចំណុចទី៤ សិស្សភាគច្រើនខ្សោយ ពួកគេមិនមានគំនិតពិចារណា ហើយគិតថាការរៀនភាសាអង់គ្លេសគ្មានប្រយោជន៍ ១.៦ (Mean=1.6)។ សរុបរួមការបញ្ជ្រាបបំណិនក្នុងការគិតពិចារណា ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមានបញ្ហាប្រឈមមួយចំនួនដូចបានរៀបរាប់ខាងលើ ហើយចំណុចទាំងបួនខាងលើមានមធ្យម១.៩ ជាមធ្យមកម្រិតទាប និងមានគម្លាតស្តង់ដា០.៣។

**តារាង៤.១៦៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិន នៃការច្នៃប្រឌិត ឬ គំនិតបង្កើតថ្មីរបស់សិស្ស** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std ) | កម្រិត |
|---|---|---|---|---|
| 1 | ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោល មានលក្ខណៈប្រពៃណី គ្មានការធ្វើបច្ចុប្បន្នភាព | 1.8 | 0.4 | **ខ្សោយ** |
| 2 | សិស្សភាគច្រើន មានមូលដ្ឋានការគិតពិចារណាខ្សោយ ពួកគេមិនចង់រៀន ឬមិនមានគំនិតច្នៃប្រឌិត ឬការបង្កើតថ្មី | 1.6 | 0.5 | **ខ្សោយ** |
| 3 | ខ្លឹមសារមេរៀនមិនសូវមានខ្លឹមសារ ឬ ការអនុវត្តទាក់ទងជាមួយនឹងការបង្កើតថ្មី ឬ គំនិតច្នៃប្រឌិត | 1.9 | 0.3 | **ខ្សោយ** |
| 4 | គ្រូបង្រៀនមិនចេះពីវិធីក្នុងការបញ្ជ្រាប | 1.9 | 0.2 | **ខ្សោយ** |
| **សរុប** | | **1.6** | **0.3** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់ រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការអភិវឌ្ឍបំណិនក្នុងការច្នៃប្រឌិត ឬគំនិតបង្កើតថ្មី របស់សិស្សមាន ៤ ចំណុច ដែលមានមធ្យម១.៦ មាន១ចំណុច មធ្យម១.៨ មាន១ចំណុច និងមធ្យម១.៩ មាន២ចំណុច។ ចំណុចទី១ ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោល មានលក្ខណៈប្រពៃណី គ្មានការធ្វើបច្ចុប្បន្នភាព មានមធ្យម ១.៨ (Mean=1.8) ចំណុចទី២ សិស្សភាគច្រើន មានមូលដ្ឋានការគិតពិចារណាខ្សោយ ពួកគេ

មិនចង់រៀន ឬ មិនមានគំនិតច្នៃប្រឌិត ឬការបង្កើតថ្មី មានមធ្យម១.៦ (Mean=1.6) ចំណុចទី៣ ខ្លឹមសារ មេរៀនមិនសូវមានខ្លឹមសារ ឬការអនុវត្តទាក់ទងជាមួយនឹងការបង្កើតថ្មី ឬគំនិតច្នៃប្រឌិត មានមធ្យម១.៩ (Mean=1.9) និង ចំណុចទី៤ គ្រូបង្រៀនមិនចេះពីវិធីក្នុងការបញ្ជ្រាប មានមធ្យម ១.៩ (Mean=1.9)។ សរុបរួមការបញ្ជ្រាបបំណិនក្នុងការច្នៃប្រឌិត ឬការបង្កើតថ្មី ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅ មានបញ្ហាប្រឈមកម្រិតខ្សោយ៤ចំណុច ដូចបានរៀបរាប់ខាងលើ ដោយចំណុចទាំងបួនខាងលើមាន មធ្យមភាគសរុប១.៦ ជាមធ្យមកម្រិតទាប និងមានគម្លាតស្តង់ដា០.៣ ។

**តារាង៤.១៧៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិននៃ ការវិភាគ និង ការដោះស្រាយបញ្ហារបស់សិស្ស** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | កម្រិត |
|---|---|---|---|---|
| 1 | សៀវភៅសិក្សាគោលមិនសូវមានខ្លឹមសារអោយសិស្សចេះគិត ពិចារណា វិភាគ និង ការដោះស្រាយបញ្ហា សំណួរ និង ចម្លើយ ភាគច្រើន ផ្តោតសំខាន់តែលើសៀវភៅសិក្សាគោល | 1.7 | 0.5 | **ខ្សោយ** |
| 2 | ពុំសូវមានសកម្មភាព ឬ គ្មានសកម្មភាពនៃការដោះស្រាយបញ្ហា ភាគច្រើនគឺផ្តោតតែទៅលើការរៀនភាសាអង់គ្លេស | 1.5 | 0.5 | **ខ្សោយ** |
| **សរុប** | | **1.6** | **0.5** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការវិភាគ និងដោះស្រាយបញ្ហារបស់សិស្ស មាន២ចំណុច ដែលមាន

មធ្យម ១.៧ និងមធ្យម១.៥។ ចំណុចទី១ សៀវភៅសិក្សាគោលមិនសូវមានខ្លឹមសារអោយសិស្ស ចេះគិតពិចារណា និងការដោះស្រាយបញ្ហា សំណួរ ចម្លើយភាគច្រើន ផ្តោតសំខាន់តែលើសៀវភៅ សិក្សាគោលមានមធ្យម១.៧ (Mean=1.7) ចំណុចទី២ ពុំសូវមានសកម្មភាព ឬគ្មានសកម្មភាពនៃ ការដោះស្រាយបញ្ហា ភាគច្រើនគឺផ្តោតតែទៅលើការរៀនភាសាអង់គ្លេសមានមធ្យម១.៥(Mean=1.5)។ សរុបរួម ការបញ្ជ្រាបបំណិនក្នុងការដោះស្រាយបញ្ហារបស់សិស្ស ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសា អង់គ្លេសនៅមានបញ្ហាប្រឈមតិចតួច ដោយសារមានបញ្ហាប្រឈមតែ២ចំណុច ហើយមានមានមធ្យម១.៦ ជាមធ្យមកម្រិតទាប ដែលមានគម្លាតស្តង់ដា០.៥។

**តារាង៤.១៨៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនក្នុងការបន្តការសិក្សាពេញមួយជីវិតរបស់**(N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | កម្រិត |
|---|---|---|---|---|
| 1 | សិស្សភាគច្រើនជាសិស្សខ្សោយ ពួកគេគ្មានសមត្ថភាព ដើម្បី បន្តការសិក្សាពេញមួយជីវិតរបស់ពួកគេនោះទេ | 1.8 | 0.4 | **ខ្សោយ** |
| 2 | មេរៀននៅក្នុងសៀវភៅសិក្សាមិនផ្តោតសំខាន់លើការអប់រំ ពេញមួយជីវិត | 1.9 | 0.3 | **ខ្សោយ** |
| **សរុប** | | **1.8** | **0.4** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការដោះស្រាយបញ្ហារបស់សិស្ស មាន២ចំណុច ដែលមានមធ្យម១.៨ និងមធ្យម១.៩។ ចំណុចទី១ សិស្សភាគច្រើនជាសិស្សខ្សោយ ពួកគេគ្មានសមត្ថភាពដើម្បីបន្តការសិក្សាពេញមួយជីវិតរបស់ពួកគេនោះទេ មានមធ្យម១.៨ (Mean=1.8) ចំណុចទី២ ពុំមេរៀននៅក្នុងសៀវភៅសិក្សា

មិនផ្តោតសំខាន់លើការអប់រំពេលពេញមួយជីវិត មានមធ្យម១.៩ (Mean=1.9)។ សរុបរួមការបញ្ជ្រាបបំណិនក្នុងការសិក្សាពេញមួយជីវិតរបស់សិស្ស ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមានបញ្ហាប្រឈមតិចតួច ដោយសារមានបញ្ហាប្រឈមតែ២ចំណុច ហើយមានមធ្យម១.៨ ជាមធ្យមកម្រិតទាប និងមានគម្លាតស្តង់ដា០.៤។

**តារាង៤.១៩៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនក្នុងការសិក្សា និង ការរស់នៅក្នុងបរិបទទំនើបនៃបច្ចេកវិទ្យា** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | កម្រិត |
|---|---|---|---|---|
| 1 | ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលមានលក្ខណៈប្រពៃណី មិនមានលក្ខណៈបច្ចេកវិទ្យា គ្មានការធ្វើបច្ចុប្បន្នភាព មិនអាចឈរនៅក្នុងបរិបទនៃសង្គមបច្ចេកវិទ្យាបានទេ | 1.6 | 0.5 | **ខ្សោយ** |
| 2 | មេរៀននៅក្នុងសៀវភៅសិក្សាគោលស្ថិតនៅក្នុងបរិបទចាស់ វាមិនបង្ហាញអំពីតថភាពជាក់ស្តែងនៃការរស់នៅរបស់សិស្សក្នុងបរិបទថ្មីបច្ចុប្បន្ន | 1.8 | 0.4 | **ខ្សោយ** |
| 3 | សិស្សភាគច្រើនជាសិស្សខ្សោយ ពួកគេពិបាកក្នុងការប្រើប្រាស់ នូវសម្ភារៈបច្ចេកវិទ្យាទំនើបថ្មីៗសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ | 1.7 | 0.5 | **ខ្សោយ** |
| **សរុប** | | **1.7** | **0.5** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពេលវេញពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុង ការសិក្សា និងការរស់នៅក្នុងបរិបទទំនើបនៃបច្ចេកវិទ្យា របស់សិស្ស មាន

៣ ចំណុច ដែលមានមធ្យមពី១.៦ ដល់មធ្យម១.៨។ ចំណុចទី១ ខ្លឹមសារនៅក្នុងសៀវភៅ សិក្សាគោល មានលក្ខណៈប្រពៃណី មិនមានលក្ខណៈបច្ចេកវិទ្យា គ្មានការធ្វើបច្ចុប្បន្នភាព មិនអាចឈរ នៅក្នុងបរិបទនៃ សង្គមបច្ចេកវិទ្យាបាន មានមធ្យម១.៦ (Mean=1.៦) ចំណុចទី២ ពុំមេរៀននៅ ក្នុង សៀវភៅសិក្សាគោលស្ថិតនៅក្នុងបរិបទចាស់ វាមិនបង្ហាញអំពីតថភាពជាក់ស្តែងនៃការរស់ នៅរបស់សិស្សក្នុងបរិបទថ្មីបច្ចុប្បន្ន មានមធ្យម១.៨ (Mean=1.8) និង ចំណុចទី៣ សិស្សភាគច្រើនជាសិស្ស ខ្សោយ ពួកគេពិបាកក្នុងការប្រើប្រាស់នូវសម្ភារៈបច្ចេកវិទ្យាទំនើបថ្មីៗសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ មានមធ្យម១.៧ (Mean=1.7) ។ សរុបរួមការបញ្ហាបបំណិនក្នុង ការសិក្សានិង ការរស់នៅក្នុង បរិបទទំនើបនៃបច្ចេកវិទ្យារបស់សិស្ស ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមាន បញ្ហាប្រឈម ៣ចំណុចសំខាន់ៗ ដែលមានមធ្យម១.៧ ជាមធ្យមកម្រិតទាប និង មានគម្លាតស្តង់ដា០.៥ ។

**តារាង៤.២០៖ មធ្យម គម្លាតស្តង់ដា បញ្ហាប្រឈមក្នុងការអភិវឌ្ឍបំណិនក្នុងការសិក្សាស្រាវជ្រាវរបស់សិស្ស** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | កម្រិត |
|---|---|---|---|---|
| 1 | គ្រូបង្រៀនមិនសូវជម្រុញសិស្សអោយមានស្វ័យសិក្សា | 2.0 | 0.5 | **ខ្សោយ** |
| 2 | គ្មានពេលវេលាគ្រប់គ្រាន់ គ្មានមេរៀន កិច្ចការ ឬលំហាត់សម្រាប់អោយសិស្សធ្វើការសិក្សាស្រាវជ្រាវ | 1.8 | 0.4 | **ខ្សោយ** |
| 3 | ចំណេះដឹងរបស់សិស្សមានកំណត់ ដូច្នេះពួកគេមិនអាចធ្វើការសិក្សាស្រាវជ្រាវមួយចំនួនបាន មានតែការស្រាវជ្រាវបែបប្រពៃណី | 1.6 | 0.5 | **ខ្សោយ** |
| 4 | សាលាភាគច្រើនគ្មានសៀវភៅសិក្សាគោល គ្មាន | 1.8 | 0.4 | **ខ្សោយ** |

| | | | | |
|---|---|---|---|---|
| | សម្ភារៈ អេឡិចត្រូនិច គ្មានសេវាអ៊ិនធើណែត សម្រាប់ធ្វើការស្រាវ ជ្រាវ | | | |
| សរុប | | 1.8 | 0.5 | ខ្សោយ |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា បញ្ហាប្រឈមក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ចំពោះសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវមាន៤ចំណុច ដែលមានមធ្យមពី១.៦ ដល់មធ្យម ២.០។ ចំណុចទី១ គ្រូបង្រៀនមិនសូវជម្រុញសិស្សអោយមានស្វៃសិក្សា មានមធ្យម ២.0 (Mean=2) ចំណុចទី២ គ្មានពេលវេលាគ្រប់គ្រាន់ គ្មានមេរៀន កិច្ចការ ឬលំហាត់សម្រាប់អោយសិស្សធ្វើការ សិក្សាស្រាវជ្រាវ មានមធ្យម១.៨ (Mean=1.8) ចំណុចទី៣ ចំណេះដឹងរបស់សិស្សមានកំណត់ ដូច្នេះ ពួកគេមិនអាចធ្វើការសិក្សាស្រាវជ្រាវមួយចំនួនបាន មានតែការស្រាវជ្រាវបែបប្រពៃណី មានមធ្យម១.៦ (Mean=1.6) និងចំណុចទី៤ សាលាភាគច្រើនគ្មានសៀវភៅសិក្សាគោល គ្មានសម្ភារៈអេឡិចត្រូនិច គ្មានសេវាអ៊ិនធើណែត សម្រាប់ធ្វើការស្រាវជ្រាវ មានមធ្យម១.៨ (Mean=1.8)។ សរុបរួមការបញ្ជ្រាបបំណិនក្នុងការសិក្សាស្រាវជ្រាវរបស់សិស្ស ទៅក្នុងកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេស នៅមានបញ្ហា៤ចំណុចដូចបានរៀបរាប់ខាងលើមានមធ្យម១.៨ ជាមធ្យមកម្រិតទាប និងមានគម្លាតស្តង់ដា០.៥។

**តារាង៤.២១៖ មធ្យម គម្លាតស្តង់ដា នៃវិធីសាស្រ្តនានាក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស** (N=19)

| ល.រ | ខ្លឹមសារ | មធ្យម (Mean) | គម្លាតស្តង់ដា ( Std) | **កម្រិត** |
|---|---|---|---|---|
| 1 | ផ្តល់ពត៌មានត្រឡប់ទៅដល់សិស្ស ព្យាយាមនូវវិធីសាស្រ្តថ្មី និង លើកទឹកចិត្តសិស្សអោយខិតខំសិក្សារៀនសូត្រ | 1.4 | 0.5 | **ខ្សោយ** |
| 2 | ធ្វើបច្ចុប្បន្នភាព ឬ បង្កើតសៀវភៅសិក្សាគោលថ្មី ទាក់ទង | 1.6 | 0.5 | **ខ្សោយ** |

| | | | | |
|---|---|---|---|---|
| | នឹងការរស់នៅក្នុងបរិបទទំនើប | | | |
| 3 | បន្ថែមម៉ោងសិក្សា ការបង្រៀន ការរៀន ការអនុវត្ត និងកិច្ចការស្រាវជ្រាវនានាត្រូវមាននៅក្នុងសៀវភៅសិក្សាគោល | 1.8 | 0.4 | **ខ្សោយ** |
| 4 | ការបង្រៀនត្រូវតែបញ្ចូល ឬ ជាប់ទាក់ទងទៅនឹងបរិបទនៃការរស់នៅបច្ចុប្បន្នរបស់សិស្ស | 1.6 | 0.5 | **ខ្សោយ** |
| 5 | គ្រូបង្រៀនត្រូវធ្វើជាគម្រូល្អដល់សិស្សានុសិស្ស | 1.8 | 0.4 | **ខ្សោយ** |
| 6 | បន្ថែមមេរៀន កិច្ចការ និង លំហាត់ទាក់ទងទៅនឹងការអប់រំពលរដ្ឋពេញលេញ | 1.8 | 0.4 | **ខ្សោយ** |
| 7 | ផ្តល់ឱកាសដល់គ្រូបង្រៀនដើម្បីទទួលបានចំណេះដឹងថ្មី និង វិធីសាស្ត្របង្រៀនថ្មី តាមរយៈវគ្គបណ្តុះបណ្តាលនានាទាំងក្នុង និង ក្រៅប្រទេស អំពីការអប់រំពលរដ្ឋពេញលេញ | 1.9 | 0.4 | **ខ្សោយ** |
| 8 | ដាក់មុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាសិក្សាគោល មានរបបពិន្ទុដូចមុខវិជ្ជាដទៃ( មិនមែនជាពិន្ទុថែម) ជាពិសេសក្នុងការប្រឡងសញ្ញាបត្រថ្នាក់ជាតិ។ | 1.7 | 0.5 | **ខ្សោយ** |
| 9 | គ្រប់សាលារៀនទាំងអស់ត្រូវតែមានការប្រកួតប្រជែងផ្នែកភាសាអង់គ្លេសតាមរយៈ ការសរសេរអត្ថបទ ឬ ការការពារនានាដើម្បីអោយសិស្សក្លាយទៅជាពលរដ្ឋពេញលេញ | 1.9 | 0.2 | **ខ្សោយ** |
| **សរុប** | | **1.7** | **0.5** | **ខ្សោយ** |

តាមលទ្ធផលតារាងខាងលើបង្ហាញអោយឃើញថា ដើម្បីអោយការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យអោយកាន់តែមានភាពល្អប្រសើរគឺត្រូវមានចំណុចទាំង៩ខាងលើ ដែលមាន ទី១ ផ្តល់ពត៌មានត្រឡប់ទៅដល់សិស្ស ព្យាយាមនូវវិធីសាស្ត្រថ្មី និង លើកទឹកចិត្តសិស្សអោយខិតខំសិក្សារៀនសូត្រ មានមធ្យម១.៤ (Mean=1.4) ទី២ ធ្វើបច្ចុប្បន្នភាព ឬបង្កើតសៀវភៅសិក្សាគោលថ្មី សម្រាប់ការរស់នៅក្នុងបរិបទទំនើបមានមធ្យម១.៦ (Mean=1.6) ទី៣ បន្ថែមម៉ោងសិក្សា ការបង្រៀន ការរៀន ការអនុវត្ត និង កិច្ចការស្រាវជ្រាវនានាត្រូវមាននៅក្នុងសៀវភៅសិក្សាគោល មានមធ្យម១.៨ (Mean=1.8) ទី៤ ការបង្រៀនត្រូវតែបញ្ចូល ឬជាប់ទាក់ទងទៅនឹងបរិបទនៃការរស់នៅបច្ចុប្បន្នរបស់សិស្ស មានមធ្យម១.៦ (Mean=1.6 )ទី៥ គ្រូបង្រៀនត្រូវធ្វើជាគម្រូល្អដល់សិស្សានុសិស្ស មានមធ្យម១.៨ (Mean=1.8) ទី៦ បន្ថែមមេរៀនកិច្ចការ និងលំហាត់ទាក់ទងទៅនឹងការអប់រំពលរដ្ឋពេញលេញ មានមធ្យម១.៨ (Mean=1.8) ទី៧ ផ្តល់ឱកាសដល់គ្រូបង្រៀនដើម្បីទទួលបានចំណេះដឹងថ្មី និងវិធីសាស្ត្របង្រៀនថ្មី តាមរយៈវគ្គបណ្តុះបណ្តាលនានាទាំងក្នុង និងក្រៅប្រទេស អំពីការអប់រំពលរដ្ឋពេញលេញ មានមធ្យម ១.៩ (Mean=1.9) ទី៨ ដាក់មុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាសិក្សាគោលមានរបបពិន្ទុដូច មុខវិជ្ជាដទៃ (មិនមែនជាពិន្ទុថែម) ជាពិសេសក្នុងការប្រឡងសញ្ញាបត្រថ្នាក់ជាតិ មានមធ្យម១.៧ (Mean=1.7) និងទី៩ គ្រប់សាលារៀនទាំងអស់ត្រូវតែមានការប្រកួតប្រជែងផ្នែកភាសាអង់គ្លេសតាមរយៈ ការសរសេរអត្ថបទ ឬការការពារនានាដើម្បីអោយសិស្សក្លាយទៅជាពលរដ្ឋពេញលេញ មានមធ្យម១.៩ (Mean=1.9)។ សរុបរួម បញ្ហាប្រឈមនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ មានមធ្យម១.៧ ជាមធ្យមកម្រិតទាប និងមានគម្លាតស្តង់ដា ០.៥ ដូចនេះយើងអាចសន្និដ្ឋានបានថាបញ្ហាប្រឈមនៃការបញ្ជ្រាប ការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស កម្រិតមធ្យមសិក្សាទុតិយភូមិនៅ ខេត្តឧត្តរមានជ័យមានបញ្ហាប្រឈម៩ចំណុចសំខាន់ដែលត្រូវដោះស្រាយ។

## ៤.៣. ការពិភាក្សា

យោងទៅលើលទ្ធផលនៃការស្រាវជ្រាវខាងលើ ឃើញថាស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅខេត្តឧត្តរមានជ័យអាចពិភាក្សាបានដូចតទៅៈ ការប្រើប្រាស់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យមិនទាន់មានភាពល្អប្រសើរនៅឡើយទេ ដោយសារគ្រូបង្រៀន៩នាក់ស្មើនឹង៤៧.៤% ជាគ្រូបង្រៀនកម្រិតមូលដ្ឋានទៅបង្រៀននៅវិទ្យាល័យ។ តាមការសិក្សារបស់ Sithika Sun (2019) បានបង្ហាញឱ្យឃើញថាការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សានៅកម្ពុជា ស្ថិតនៅក្នុងការពិចារណាត្រូវធ្វើការពិនិត្យ និងកែតម្រូវឱ្យប្រសើរឡើងវិញដោយសារនៅមានបញ្ហាមួយចំនួន ក្នុងនោះបញ្ហាទី១គឺបញ្ហាគ្រូបង្រៀបង្រៀនដោយ គ្រូបង្រៀនមួយចំនួនធំនៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ទៅតាមកម្រិតសញ្ញាបត្រ ជាគ្រូបង្រៀនភាសាអង់គ្លេស មានន័យថាក្រោយពីពួកគាត់បានរៀនចប់ថ្នាក់ទី១២ ពួកគាត់បានក្លាយជាគ្រូភាសាអង់គ្លេស តាមរយៈការប្រឡងចូលគ្រូ ដោយទទួលការបណ្តុះបណ្តាលរយៈពេលពីរឆ្នាំ (គ្រូកម្រិតមូលដ្ឋាន) គឺមិនទាន់មានចំណេះដឹងគ្រប់គ្រាន់ក្នុងការបង្រៀនសិស្សនោះទេ ដោយសារការសិក្សានៅសាលាបណ្តុះបណ្តាលគ្រូ ត្រូវរៀនច្រើនមុខវិជ្ជា ហើយចំណេះដឹងមូលដ្ឋានរបស់ពួកគាត់គឺមានកម្រិត ដូច្នេះការបង្រៀនភាសាអង់គ្លេសរបស់គ្រូភាគច្រើនគឺ មិនទាន់មានសមត្ថភាពឆ្លើយតបទៅនឹងគុណភាពអប់រំនោះទេ។ ចំពោះពេលវេលាក្នុងការអនុវត្តកម្មវិធីសិក្សាគឺអនុវត្តបានល្អ ដោយក្នុងចំណោមវិទ្យាល័យទាំង៩ នៅខេត្តឧត្តរមានជ័យមាន៨សាលា អនុវត្តម៉ោងសិក្សាបានត្រឹមត្រូវតាមកម្មវិធីសិក្សាគោល ដោយឡែកនៅមានវិទ្យាល័យមួយអនុវត្តម៉ោងបង្រៀនតិចជាងកម្មវិធីសិក្សាគោលដោយនៅថ្នាក់ទី១០ អនុវត្តការបង្រៀន និងរៀន២ម៉ោងក្នុង១សប្តាហ៍មាន៣ថ្នាក់ ស្មើនឹង ១៥.៨% ខុសពីចំនួនម៉ោងក្នុងកម្មវិធីសិក្សាគោលដែលតម្រូវអោយអនុវត្តការបង្រៀន៤ម៉ោងក្នុង១សប្តាហ៍។ ចំណែកឯខ្លឹមសារនៅក្នុងសៀវភៅសិកក្សាគោល ធៀបជាមួយនឹងសមត្ថភាពគ្រូបង្រៀនគឺមានលទ្ធផលមធ្យម ដោយមានមធ្យម៣.២១ ជាមធ្យមកម្រិតមធ្យមខ្ពស់ តែបើប្រៀបធៀបជាមួយនឹងសមត្ថភាពសិស្សគឺមិនសមស្របនោះទេ ដោយលទ្ធផលសិក្សា មានមធ្យម២.៤៧ ជាមធ្យមកម្រិតទាប ហើយបើធៀបជាមួយពេលវេលា

បង្រៀនក្នុង១ឆ្នាំសិក្សា ក៏មិនទាន់ទទួលបានលទ្ធផលល្អនៅឡើយទេដោយសារលទ្ធផល មានមធ្យម ២.៥៣ ជាមធ្យមកម្រិតមធ្យមទាប។ ចំពោះគុណភាពនៃការអភិវឌ្ឍបំណិននានានៃការអប់រំពលរដ្ឋពេញលេញ តាមរយៈការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅខេត្តឧត្តរមានជ័យទទួលបានលទ្ធផលមធ្យម ដោយមានមធ្យមសរុប២.៩០ (M=2.90) និងមានគម្លាតស្តង់ដា០.៨៦ (Std=0.86) [Oxford និងBurry-Stock (1995) មធ្យម កម្រិតខ្ពស់ (M=3.50 ឡើង) កម្រិតមធ្យម (M=2.50 – 3.49) និងកម្រិតទាប (M=2.49 ចុះ)]។ ដូច្នេះលទ្ធផលនេះគឺមានចំណុចល្អតិចតួច ឯចំណុចគួរកែលំអរមានច្រើនចំណុច។ ចំណុចល្អមានដូចជា៖ សមត្ថភាពគ្រូបង្រៀន ធៀបជាមួយនឹងសៀវភៅសិក្សាគោល គឺមានភាពសមស្របដោយមានមធ្យម៣.២១ (M=3.21) ជាមធ្យម កម្រិតមធ្យមខ្ពស់។ សមត្ថភាពក្នុងការបន្តការសិក្សាពេញមួយជីវិតរបស់សិស្ស មានមធ្យម៣.២៦ (M=3.26) ជាមធ្យម កម្រិតមធ្យមខ្ពស់ និងសមត្ថភាពក្នុងការអភិវឌ្ឍការគិត និងការត្រិះរិះពិចារណារបស់សិស្ស មានមធ្យម៣.២១ (M=3.21) ជាមធម្យម កម្រិតមធ្យមខ្ពស់។ ដូច្នេះការបញ្ជ្រាបបំណិនទាំងពីរនេះទៅក្នុងកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យគឺមានលទ្ធផលល្អប្រសើរជាងគេ រីឯបំណិនផ្សេងៗទៀតមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយទេ។ ដូចនេះការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសគឺ អាស្រ័យទៅលើការអនុវត្តកម្មវិធីសិក្សាទាំងស្រុង ហើយកម្មវិធីសិក្សាត្រូវតែមានការកែលំអរអោយមានភាពសមស្រប និងស៊ីសង្វាក់គ្នាជាមួយនឹងខ្លឹមសារនៃការអប់រំពលរដ្ឋពេញលេញ ទើបធ្វើអោយស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញមានភាពប្រសើរឡើង។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងដើម្បី ចង់ដឹងអំពីស្ថានភាពក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ និងដើម្បីរកអោយឃើញនូវបញ្ហាប្រឈមនានាដែលកើតមានលើដំណើរបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សា និងអាចរកដំណោះស្រាយតាមរយៈចម្លើយដែលទទួលបានពីក្រុមគ្រូបង្រៀន ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។

យោងទៅលើលទ្ធផលនៃការស្រាវជ្រាវសំណួរទី១ដែលបានធ្វើការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា ការបញ្ជ្រាបការអប់រំពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យ សម្រេចបានលទ្ធផលកម្រិតមធ្យមទាប ដោយសារការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាអង់គ្លេស អាចអភិវឌ្ឍសមត្ថភាពនានានៃបំណិននៃការអប់រំពលរដ្ឋពេលលេញមានមធ្យម ២.៩ ជាមធ្យមកម្រិតមធ្យមទាប និងមានគម្លាតស្តង់ដា០.៨៦ ចំពោះលទ្ធផលដែលទទួលបានពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិទាំង១៩នាក់នៅខេត្តឧត្តរមានជ័យ។ ចំពោះលទ្ធផលនៃសំណួរស្រាវជ្រាវទី២ស្តីពី បញ្ហាប្រឈម ឬឧបសគ្គនានាដែលរាំងស្ទះដល់ការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស កម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តឧត្តរមានជ័យរួមមានមាន៖ (ទី១) កត្តាសិស្ស៖ សិស្សានុសិស្សជនបទភាគច្រើនមានចំណេះដឹងមូលដ្ឋានភាសាអង់គ្លេសទាប និងគ្មានការចាប់អារម្មណ៍ ឬមិនអោយតម្លៃលើការសិក្សាភាសាអង់គ្លេសពិបាកក្នុងការបញ្ជ្រាប (ទី២) កត្តាសៀវភៅសិក្សាគោល៖ សៀវភៅ សិក្សាគោលមានកម្រិតខ្ពស់ មានភាពស្មុគស្មាញគ្មានការធ្វើបច្ចុប្បន្នភាព មិនសូវមានចំណុចទាក់ទងនឹងការអប់រំពលរដ្ឋពេញលេញ ជាពិសេសមិនមានភាពស៊ីគ្នាជាមួយនឹងបរិបទជាក់ស្តែងក្នុងជីវភាពរស់នៅរបស់សិស្សានុសិស្ស ហើយសិស្សភាគច្រើនគ្មាន

សៀវភៅសិក្សាគោលសម្រាប់សិក្សា (ទី៣) កត្តាគ្រូបង្រៀនៈ គ្រូបង្រៀនមិនដែលទទួលបានការបណ្តុះបណ្តាលទាក់ទង និងការអប់រំពលរដ្ឋពេញលេញ ពួកគាត់មានភាពពិបាក ខ្វះវិធីសាស្រ្ត ខ្វះជំនាញ មិនដឹងត្រូវបញ្ជ្រាបដោយវិធីណា ហើយគ្រូមួយចំនួនជាគ្រូបង្រៀនកម្រិតមូលដ្ឋានមានកម្រិតបណ្តុះបណ្តាលទាបទៅបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ (ទី៤) កត្តាកម្មវិធីសិក្សាៈ កម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស មិនត្រូវបានដាក់ជាកម្មវិធីសិក្សាគោល ម៉ោងបង្រៀនមិនសមស្របជាមួយនឹងខ្លឹមសារមេរៀន ថ្នាក់រៀនមានចំនួនធំ សិស្សច្រើន ពិបាកបង្រៀន គ្មានសកម្មភាពទាក់ទងនឹងការអប់រំពលរដ្ឋពេញលេញ (ទី៥) កត្តាសាលារៀនៈ សាលារៀនភាគច្រើន គ្មានសម្ភារៈបច្ចេកទេសសម្រាប់អោយសិស្សអនុវត្ត ការសិក្សាស្រាវជ្រាវ ការពិសោធន៍នានា ដើម្បីអោយសិស្សមានបំណិនក្លាយជាពលរដ្ឋពេញលេញ តាមសាលាភាគច្រើនគ្មានសៀវភៅសិស្សាគោលសម្រាប់សិស្ស (ទី៦) កត្តាសង្គមៈ សង្គមគ្មានការបើប្រាស់ភាសាអង់គ្លេសជាទូទៅ គ្មានការប្រឡងភាសាអង់គ្លេស ឬធ្វើតេស្តក្នុងការចូលបម្រើការងារនានា សម្ភារៈបច្ចេកទេសមិនសូវសំបូរបែសប សេវាអ៊ិនធើណែតខ្សោយ មិនអំណោយផលដល់ការសិក្សាស្រាវជ្រាវនានាដើម្បីបង្កើនបញ្ញាសិស្ស និងអាចបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញបាន។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ ជួបប្រទៈនូវបញ្ហាលំបាកច្រើន ដែលជាឧបសគ្គ នាំអោយការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញមិនទាន់ទទួលបាននូវលទ្ធផលល្អនៅឡើយ។ ដូចនេះបើចង់អោយការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសទទួលបាននូវលទ្ធផលល្អប្រសើរនោះគប្បីអនុវត្តនូវចំណុចសំខាន់ៗ ដូចតទៅៈ (ទី១) ផ្តល់ពត៌មានត្រឡប់ទៅដល់សិស្ស ព្យាយាមប្រើប្រាស់ វិធីសាស្ត្រថ្មី និងលើកទឹកចិត្តសិស្សអោយខិតខំ សិក្សារៀនសូត្រ (ទី២) ធ្វើបច្ចុប្បន្នភាព ឬបង្កើតសៀវភៅ សិក្សាគោលថ្មីសមស្របសម្រាប់ការរស់នៅក្នុងបរិបទ ទំនើបរបស់សិស្ស (ទី៣) បន្ថែមម៉ោងសិក្សា៤ម៉ោង ក្នុង១សប្តាហ៍ យោងទៅលើលទ្ធផលស្រាវជ្រាវពីទស្សនៈយល់ឃើញ របស់គ្រូបង្រៀននៅកម្រិតមធ្យម សិក្សាទុតិយភូមិ១៣នាក់ ស្មើនឹង៦៨.៤% (ទី៤) ការបង្រៀន ការរៀន ការអនុវត្ត និងកិច្ចការស្រាវជ្រាវនានាត្រូវមាននៅក្នុងសៀវភៅសិក្សាគោល (ទី៥)

ការបង្រៀន ត្រូវតែបញ្ចូល ឬជាប់ទាក់ទងទៅនឹង បរិបទនៃការរស់នៅក្នុងបរិបទបច្ចុប្បន្នរបស់សិស្ស (ទី៦) គ្រូបង្រៀនត្រូវធ្វើជាគម្រូល្អដល់សិស្សានុសិស្ស (ទី៧) បន្ថែមមេរៀន កិច្ចការ និងលំហាត់ទាក់ទងទៅនឹងការអប់រំពលរដ្ឋពេញលេញទៅក្នុងសៀវភៅសិក្សាគោល (ទី៨) ផ្តល់ឱកាសដល់គ្រូបង្រៀនដើម្បីទទួលបានចំណេះដឹងថ្មី និងវិធីសាស្ត្របង្រៀនថ្មីតាមរយៈវគ្គបណ្តុះបណ្តាលនានាទាំងក្នុង និងក្រៅប្រទេសជាពិសេសការអប់រំពលរដ្ឋពេញលេញ (ទី៩) ដាក់មុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាសិក្សាគោលមានរបបពិន្ទុដូចមុខវិជ្ជាដទៃ (មិនមែនជាពិន្ទុថែម) ជាពិសេសក្នុងការប្រឡងសញ្ញាបត្រថ្នាក់ជាតិ និង (ទី១០) គ្រប់សាលារៀន ទាំងអស់ត្រូវតែមានការប្រកួតប្រជែងផ្នែកភាសាអង់គ្លេសតាមរយៈការសរសេរអត្ថបទ ឬការការពារនានា ដើម្បីអោយសិស្សមានបំណិនក្លាយទៅជាពលរដ្ឋពេញលេញ។ សរុបមកយើងឃើញថាស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ ទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិពិតជាមានភាពលំបាកជាច្រើន។

ដូចេះដើម្បីអោយការបញ្ជ្រាបមានភាពប្រសើរឡើង នោះគួរគប្បីមានការកែលំអរដូចបានរៀបរាប់ខាងលើ ទើបធ្វើអោយការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិមានភាពល្អប្រសើរឡើង ដែលអាចធ្វើអោយពលរដ្ឋគ្រប់រូបមានបំណិនគ្រប់គ្រាន់ ដើម្បីឈានទៅរកការអភិវឌ្ឍសមត្ថភាពក្លាយជាពលរដ្ឋពេញលេញនៅថ្ងៃអនាគតបាន។

## ៥. ២. សំណូមពរ

### ក. ចំពោះគ្រូបង្រៀន៖

- អនុវត្តសកម្មភាពនានាទាក់ទងនឹងបំណិននៃការអប់រំពលរដ្ឋពេញលេញនៅក្នុងថ្នាក់រៀនអោយបានច្រើន ដើម្បីអោយសិស្សទទួលបានចំណេះដឹង និងក្លាយទៅជាពលរដ្ឋពេញលេញពិតប្រាកដនៅថ្ងៃអនាគត។

### ខ. ចំពោះគណៈគ្រប់គ្រងសាលា៖

- ផ្តល់ជំនួយផ្នែកសម្ភារឧបទេស និងសៀវភៅសិក្សាគោល ដែលជាតម្រូវការក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស ដើម្បីជាទុនឈានទៅរកការអនុវត្តសកម្មភាពនានានៅក្នុងថ្នាក់រៀនអោយបានច្រើនធ្វើអោយសិស្សមានបំណិន និងអាចអភិវឌ្ឍខ្លួនទៅជាពលរដ្ឋសកម្មនៅក្នុងថ្នាក់រៀន ក្នុងសង្គម និងអាចក្លាយខ្លួនជាពលរដ្ឋពេញលេញ។
- បង្កើតការប្រឡងសំណេរ និងការនិយាយភាសាអង់គ្លេស ជារាងរាល់ឆ្នាំប្រចាំសាលា ដើម្បីអោយសិស្សមានបំណិនក្នុងការគិត ការអាន ការសរសេរ ការនិយាយ និងឈានទៅដល់ការតស៊ូមតិ និងការដោះស្រាយបញ្ហានានានៅក្នុងសង្គម។

### គ. ចំពោះក្រសួងអប់រំ យុវជន និង កីឡា៖

- ធ្វើការបោះពុម្ព ឬកែប្រែសៀវភៅសិក្សាគោលថ្មី អោយសមស្របជាមួយនឹងកម្មវិធីសិក្សាគោល (ពេលវេលាបង្រៀន និងរៀន) និងបន្ថែមខ្លឹមសារទាក់ទងទៅនឹងបំណិនថ្មីៗ នៃការអប់រំពលរដ្ឋពេញលេញអោយបានច្រើនសម្រាប់សិស្សអនុវត្ត។
- គាំទ្រផ្តល់ជំនួយផ្នែកសម្ភារឧបទេសបង្រៀន និងរៀន និង ធនធានគ្រូបង្រៀនអោយចំទៅនឹងជំនាញឯកទេសនិងសមត្ថភាពដែលទទួលបានពីការបណ្តុះបណ្តាល។

### ឃ. សំណូមពរសម្រាប់ការស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងតែទៅលើគ្រូបង្រៀនមុខវិជ្ជាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តឧត្តរមានជ័យតែប៉ុណ្ណោះ ហេតុនេះអ្នកសិក្សាស្រាវជ្រាវក្រោយៗ ដែលមានបំណងសិក្សាស្រាវជ្រាវបន្តលើប្រធានបទនេះ អាចធ្វើការសិក្សាលើការអនុវត្តកម្មវិធីសិក្សាការអប់រំពលរដ្ឋពេញលេញនៅមធ្យមសិក្សាបឋមភូមិនៅខេត្តឧត្តរមានជ័យ ឬពង្រីកទៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា ឬបន្ថែមវិសាលភាពជាមួយនឹងសិស្សានុសិស្ស ឬគណៈគ្រប់គ្រងសាលារៀនបន្ថែមទៀត។

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា. ( ២០២១). ស្ថិតិ និងសូចនាករអប់រំសាធារណៈ ឆ្នាំ២០២០-២០២១. រាជធានីភ្នំពេញ: នាយកដ្ឋានប្រព័ន្ធគ្រប់គ្រងអប់រំ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). សេចក្តីណែនាំស្តីពីការបង្រៀន និងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា. រាជធានីភ្នំពេញ: Moeys.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). ស្ថិតិ និងសូចនាករអប់រំសាធារណៈ. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). ផែនទីបង្ហាញផ្លូវ ការអប់រំនៅកម្ពុជា ឆ្នាំ២០៣០៖ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤. រាជធានីភ្នំពេញ: Moeys.

ក្រសួងអប់រំយុវជន និង កីឡា. (២០១០). សេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅនៅមធ្យមសិកក្សាទុតិយភូមិ. ដំណើរការគ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ, pp. ១-២.

ក្រសួងអប់រំយុវជន និង កីឡា. (២០១៥). ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និង អប់រំបច្ចេកទេស. ភ្នំពេញ: នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា.

ក្រសួងអប់រំយុវជន និង កីឡា. (២០១៥). ក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស. ភ្នំពេញ: ក្រសួងអប់រំយុវជន និង កីឡា.

ក្រសួងអប់រំយុវជន និង កីឡា. (២០១៧). ស្ថិតិ និង សូចនាករអប់រំសាធារណៈ. ភ្នំពេញ: នាយកដ្ឋានផែនការ.

ក្រសួងអប់រំយុវជន និង កីឡា. (២០១៨). ការរៀបចំ និងការប្រព្រឹត្តិទៅនៃការប្រឡងនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ. ២០១៨-២០១៩, pp. ២-៧.

ក្រសួងអប់រំយុវជន និង កីឡា. (២០១៥). ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និង អប់រំបច្ចេកទេស. ភ្នំពេញ: នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា.

គោលនយោបាយជាតិ. (២០១៩). ការសិក្សាពេញមួយជីវិត. ភ្នំពេញ: រាជរដ្ឋាភិបាល.

ជួន ណាត. (១៩៦៧). វចនានុក្រមខ្មែរ. ភ្នំពេញ: វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ.

មន្ទីរផែនការខេត្តឧត្តរមានជ័យ. (២០២១). ឯកសារពត៌មានស្ថានភាពស្តីពី សេដ្ឋកិច្ច សង្គមកិច្ច. ក្រុងសំរោង: មន្ទីរផែនការខេត្តឧត្តរមានជ័យ.

វចនានុក្រមខ្មែរ. (២០២០). (H. A. Pornmoniroth, Ed.) ភ្នំពេញ: សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, អគ្គីសនីកម្ពុជា.

សេចក្ដីប្រកាសទីក្រុង អ៊ីនឈុន. (២០១៥). វិស័យអប់រំឆ្នាំ២០៣០ ឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ណ្ណ សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា. ក្រសួងអប់រំ យុវជន និងកីឡា.

Astrologers, T. (2020). Daily horoscope for December. chicagotribune.com.

Bestor. (1956). Curriculum Definition Collection. Dr. Robert Sweetland's notes.

Bobbit, B. (1918). Curriculum Definition Collection. Dr. Robert Sweetland's notes.

Bonsor, F. G. (1920). The Elementary School Curriculum. New York: Macmillan.

Brett. (2006). Citizenship into Practice in England: the continuing professional development challenge,. 97-118.

BRITISH STUDY CENTERS. (n.d.). The importance of English language. Why learning English is so importance.

Candy PC, C. G. (1994). Developing lifelong learners. Canberra.

Caswell, H. L. ( 1935). Curriculum Development. New York: John Mark Ockerbloom.

Cheng KM, J. X. (1999). From training to education. Lifelong. China.

Cice Jean Monnet Network. (2017). Citizenship Education in a diverse Europe: Guidelines for Teacher Educator.

Clemitshaw, G. & Calvert, M. (2005). Implementing Citizenship in the English Secondary School Curriculum. Citizenship, Social and Economics Education, 31-36.

Cohen. (1975). Lifelong learning: A definition and a challenge.

Cropley. (1979). Lifelong education.

Dave, R. (1975). Investigating lifelong learning dispositions of students. Şenel Elaldı, 2.

Dave, R. (1976). Foundation of Life Long Education. Muhammad Javed Iqbal , 14-25.

Davw. (1975). Reflections on lifelong education and the school.

Dewey. (2018). The Palgrave Handbook of Citizenship and Education . GroningenThe Netherlands: Piet A van der Ploeg.

Dinevsk. (2004). The concepts of university lifelong.

Doll, R. C. (1988). Curriculum Definition Collection. Dr. Robert Sweetland's notes.

Dowd. (1979). The challenge of lifelong learning.

Faure. (1972). The world of education today and. Paris.

Guilherme. (2002). CRITICAL CITIZENS FOR AN INTERCULTURAL WORLD.

Javis P. (1990). An International dictionary of adult and continuing. London and New York: Routledge.

Lengrand. (1970). An introduction to lifelong education. London: Croom Helm.

Lima, C.O. & Brown, S.W. (2017). Examining the Perceptions of English Instructors Regarding the Incorporation of Global Citizenship Education into ELT. Language Education and Teaching, 3.

London Metopolitan University. (2017). Citizenship Education in a diverse Europe: Guidelines for Teacher Educator. London: London Metopolitan University.

Matthew Hayes. (n.d.). Global Citizenship Education in the ELT classroom. Professonal Development.

Merriam, W. (1828). Integration meaning.

Ofsted. (2003). Citizenship through History – What is good practice. Peter Brett.

Oliver, A. (1977). Curriculum Definition Collection. Dr. Robert Sweetland's notes.

Oxford Language. (2021). Curriculum meaning. Oxford University Press.

Oxford, R. L. & Burri-Stock, J. A. (1995). Assessing language learning strategies worldwide with the ESL/EFL verson of the strategy inentoryfor laguage learning. System.

Palma, J. (2017). Professonal Development (Curriculum Development). Slideshare.

Preece. (2011). Research in adult education and lifelong learning .

Sahirudin. (2013). he implementation of the 2013 curriculum and the issues of English language teaching and learning in Indonesia. Yulia Nur Ekawati.

Sell. (1978). A handbook of terminology for classifying and describing. Denver, CO.

Sithika, S. (2019). A Case Study Evaluation of Curriculum of English Subject for Lower Secondary School in . American International Journal of Social Science , 87-88.

Tuschling A, E. C. (2006). From education to lifelong learning.

Vira, N. (2002). Teaching English in Cambodian secondary schools. Hiroshima: Bulletin, Graduate School of Education, Hiroshima University Part II, 51, pp. 197-20.

Wain. (2009). Lifelong learning and philosophy. New York.

Wikipedia. (2009). Implementation. Wikipedia.

WIKIPEDIA. (2021). Education. The free Encylopedia.

Witt, J. C. (2012). Measuring the Effectiveness of Professional Development. Ibrahim Garba.

Young, Commins, and Kington. (2002). Global citizenship. Oxfam

## ឧបសម្ព័ន្ធទី១៖ កម្រងបញ្ជីសំណួរ

**ប្រធានបទ៖**
**ស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ**

UPPER SECONDARY TEACHER'S PERCEPTIONS OF INTEGRATING CITIZENSHIP EDUCATION ON ENGLISH'S CURRICULUM IN ODDOR MEANCHEY PROVINCE

### កម្រងសំណួរបំពេញដោយគ្រូបង្រៀន

ខ្ញុំបាទ រស់ សុភាន់ ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ នៅវិទ្យាស្ថានជាតិអប់រំ កំពុងធ្វើនិក្ខេបទក្រោមប្រធានបទ "**ស្ថានភាពនៃការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅខេត្តឧត្តរមានជ័យ**"។

**គោលបំណង៖** ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដើម្បី ប្រមូលពត៌មានអំពីស្ថានភាពនៃការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសដើម្បីបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញ នៅខេត្តឧត្តរមានជ័យ ដោយជ្រើសយកវិទ្យាល័យទាំង៩ជាគោលដៅក្នុងការសិក្សា។ ហើយពត៌មានដែលប្រមូលបាននឹងត្រូវយកទៅវិភាគតាមកម្មវិធីវិភាគទិន្នន័យ ដើម្បីអាចវាយតម្លៃបាននូវលទ្ធផលជារួម អាចធ្វើការកែប្រែចំណុចខ្វះខាត និងអាចផ្តល់ជាអនុសាសន៍ សម្រាប់ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដើម្បីបញ្ជ្រាបការអប់រំពលរដ្ឋពេលលេញអោយកាន់តែមានភាពល្អប្រសើរឡើង។

ខ្ញុំបាទសូមរក្សាការសម្ងាត់នូវរាល់ចម្លើយដែលទទួលបានពីលោកគ្រូ-អ្នកគ្រូ ហើយគ្រប់ចម្លើយនការព្រួយបារម្ភ និងសូមចូលរួមផ្តល់ចម្លើយអោយបានគ្រប់ជ្រុងជ្រោយ ព្រោះរាល់ចម្លើយ ដែលទទួលបានពីលោកគ្រូ-អ្នកគ្រូពិតជាមានសារៈសំខាន់ និងមានតម្លៃយ៉ាងខ្លាំង សម្រាប់ការសិក្សាស្រាវជ្រាវមួយនេះ។

សូមគោរពអរគុណ ក្នុងការចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចូលរួមផ្តល់ចម្លើយ។

➢ **ផ្នែកទី១៖ ព័ត៌មានទូទៅ**

1. ឈ្មោះសាលា៖.......................................................................................................................

2. ភេទ ប្រុស □ ស្រី □

3. សញ្ញាបត្រ៖ គ្រូបង្រៀនកម្រិតមូលដ្ឋាន □ គ្រូបង្រៀនកម្រិតឧត្តម □

4. កម្រិតវប្បធម៌៖ បាក់ឌុប□ បរិញ្ញាបត្ររង□ បរិញ្ញាបត្រ□ អនុបណ្ឌិត□ បណ្ឌិត□

5. បង្រៀនថ្នាក់ទី៖ 1. ថ្នាក់ទី១០ □ 2. ថ្នាក់ទី១១ □ 3. ថ្នាក់ទី១២ □

6. បទពិសោធន៍បង្រៀន៖ 1. តិចជាង៥ឆ្នាំ □ 2. ៥ដល់១០ឆ្នាំ □ 3. ១០ដល់១៥ឆ្នាំ□

   4. ១៥ដល់២០ឆ្នាំ □ 5. ២០ដល់២៥ឆ្នាំ □ 6. ២៥ដល់៣០ឆ្នាំ □ 7. ច្រើនជាង៣០ឆ្នាំ □

➢ **ផ្នែកទី២៖ ស្ថានភាពនៃការបញ្ច្រាបការអប់រំពលរដ្ឋពេញលេញ ចូលទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស**

7. តើការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសរបស់អ្នកមានរយៈពេលប៉ុន្មានម៉ោងក្នុង១សប្តាហ៍?

   1. ១ម៉ោង □ 2. ២ម៉ោង □ 3. ៣ម៉ោង □ 4. ៤ម៉ោង □ 5. ច្រើនជាង៤ម៉ោង □

8. តើរយៈពេលនៃការបង្រៀនក្នុង១សប្តាហ៍របស់អ្នក សមស្របជាមួយខ្លឹមសារមេរៀនដែរ ឬទេ?

   1. មិនសមស្របទាំងស្រុង □ 2. មិនសមស្រប □ 3. ធម្មតា □ 4. សមស្រប □

   5. សមស្របទាំងស្រុង □

9. តើអ្នកគិតថា ត្រូវប្រើរយៈពេលប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍ទើបគ្រប់គ្រាន់?

   1. ២ម៉ោង □ 2. ៣ម៉ោង □ 3. ៤ម៉ោង □ 4. ៥ម៉ោង □ 5. ៦ម៉ោង □

   6. ច្រើនជាង៦ម៉ោង □

10. តើខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោល សមស្របជាមួយពេលវេលាបង្រៀនក្នុងមួយឆ្នាំសិក្សាដែរ ឬទេ?

   1. មិនសមស្របទាំងស្រុង □ 2. មិនសមស្រប □ 3. ធម្មតា □ 4. សមស្រប □

   5. សមស្របទាំងស្រុង □

   បើមិនសមស្រប តើមានកត្តាអ្វីខ្លះដែលជាបញ្ហា?..............................................................

11.តើខ្លឹមសារនៃមេរៀនក្នុងសៀវភៅសិក្សាគោល សមស្របជាមួយនឹងសមត្ថភាពមូលដ្ឋានរបស់សិស្សដែរឬទេ?

1. មិនសមស្របទាំងស្រុង ☐ 2. មិនសមស្រប ☐ 3. ធម្មតា ☐ 4. សមស្រប ☐

5. សមស្របទាំងស្រុង ☐

បើមិនសមស្រប តើមានកត្តាអ្វីខ្លះដែលជាបញ្ហា?...........................................................................

12. តើខ្លឹមសារនៃមេរៀនក្នុងសៀវភៅសិក្សាគោល សមស្របជាមួយនឹងសមត្ថភាពមូលដ្ឋាន និងសមត្ថភាពបង្រៀនរបស់អ្នកដែរឬទេ?

1. មិនសមស្របទាំងស្រុង ☐ 2. មិនសមស្រប ☐ 3. ធម្មតា ☐ 4. សមស្រប ☐

5. សមស្របទាំងស្រុង ☐

បើមិនសមស្រប តើមានកត្តាអ្វីខ្លះដែលជាបញ្ហា?...........................................................................

13. តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍបំណិនក្នុងការទំនាក់ទំនងរបស់សិស្សដែរឬទេ?

1. មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐ 3.ធម្មតា ☐

4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាព តើអ្វីទៅដែលជាបញ្ហា?...........................................................................

14.តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍបំណិនក្នុងការសហការ ឬកិច្ចសហប្រតិបត្តិការរបស់សិស្សដែរឬទេ?

1. មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐ 3. ធម្មតា ☐

4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាព តើអ្វីទៅដែលជាបញ្ហា?...........................................................................

15. តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះ មានគុណភាពក្នុងការអភិវឌ្ឍបំណិនក្នុងការតស៊ូមតិ ឬ ការដឹកនាំរបស់សិស្សដែរឬទេ?

1. មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐ 3. ធម្មតា ☐

4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាព តើអ្វីទៅដែលជាបញ្ហា ?..................................................................

16.តើអ្នកគិតថាការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍការគិត ឬការ ត្រិះរិះពិចារណា របស់សិស្សដែរឬទេ ?

1. មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐ 3. ធម្មតា ☐

4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាព តើអ្វីទៅដែលជាបញ្ហា ?..................................................................

17.តើអ្នកគិតថាការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍគំនិតបង្កើតថ្មី និង ការច្នៃប្រឌិត របស់សិស្សដែរឬទេ ?

1. មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐ 3. ធម្មតា ☐

4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាព តើអ្វីទៅដែលជាបញ្ហា ?..................................................................

18.តើអ្នកគិតថាការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះមានគុណភាពក្នុងការអភិវឌ្ឍការវិភាគ និង ការដោះស្រាយបញ្ហារបស់សិស្សដែរឬទេ ?

1. មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐ 3. ធម្មតា ☐

4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាព តើអ្វីទៅដែលជាបញ្ហា ? ..................................................................

19.តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះ មានគុណភាពអភិវឌ្ឍសមត្ថភាពក្នុងការបន្តការសិក្សាពេញមួយជីវិតរបស់សិស្សដែរឬទេ ?

1.មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐ 3. ធម្មតា ☐

4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាព តើអ្វីទៅដែលជាបញ្ហា ? ..................................................................

20. តើអ្នកគិតថាការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះ មានគុណភាពអភិវឌ្ឍសមត្ថភាពសិក្សា និងការរស់នៅរបស់សិស្សក្នុងបរិបទទំនើបនៃបច្ចេកវិទ្យាដែរឬទេ?

1. មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐ 3. ធម្មតា ☐

4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាពតើអ្វីទៅដែលជាបញ្ហា? ..............................................................

21. តើអ្នកគិតថា ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសសព្វថ្ងៃនេះ មានគុណភាពក្នុងការអភិវឌ្ឍការសិក្សាស្រាវជ្រាវរបស់សិស្សដែរឬទេ?

1. មិនមានគុណភាពទាំងស្រុង ☐ 2. មិនមានគុណភាព ☐

3. ធម្មតា ☐ 4. មានគុណភាព ☐ 5. មានគុណភាពទាំងស្រុង ☐

បើមិនទាន់មានគុណភាព តើអ្វីទៅដែលជាបញ្ហា? ..............................................................

22. តើអ្នកគិតថា ត្រូវធ្វើដូចម្តេចខ្លះក្នុងការបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញទៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស អោយកាន់តែមានភាពល្អប្រសើរឡើង?........................................................

**សូមអរគុណ!**

## ឧបសម្ព័ន្ធទី ២៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខៈ ២៤០៩ អយក. ទីឯរ

ថ្ងៃ ... ខែ ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

**ជម្រាបមក**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨។

**យោង៖** -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-លិខិតលេខ១៤៣៥ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី ប្រធាន** ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ចំនួន៣១នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមរាជធានី-ខេត្តនានាតាមប្រព័ន្ធអនឡាញ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី ប្រធាន** ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម **លោក លោកស្រី ប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី ខេត្តពាក់ព័ន្ធ

"ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ឧបសម្ព័ន្ធទី ៣៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជននិងកីឡាខេត្តឧត្តរមានជ័យ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ

លេខ:១២២៣ អយកឧ. ទុប

ថ្ងៃ អង្គារ១១កើត ខែ ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ឧត្តរមានជ័យ.ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២១

**ជម្រាបមក**

**លោកនាយក ឧត្តរល័យទាំងអស់ ក្នុងខេត្ត**

កម្មវត្ថុ៖ ការសម្ភាសន៍ និងប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទ របស់ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី ៨

យោង: -លិខិតលេខ ២៤០៩ អយក.វជអ ចុះថ្ងៃ សុក្រ ៧កើត ខែ ទុតិយសាឍ ឆ្នាំឆ្លូវ ទោស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា

-លិខិតឧទ្ទេសនាមលេខ ១៤៣៤ អយក.ឧទន ចុះថ្ងៃ ពុធ ៧កើត ខែ បឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០២១ របស់ក្រសួងអប់រំ យុវជននិងកីឡា

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបលោកនាយកជ្រាបថា៖ លោក រស់ សុភាន់ នាយករងវិទ្យាល័យហ៊ុន សែន ចុងកាល់ ស្រុកចុងកាល់ ត្រូវសរសេរនិក្ខេបបទបញ្ចប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ នៅវិទ្យាស្ថានជាតិអប់រំ លើប្រធានបទស្រាវជ្រាវ "ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ លើការអនុវត្តកម្មវិធីមុខវិជ្ជាភាសាអង់គ្លេសដើម្បីបញ្ជ្រាបការអប់រំពេលវេញពេញលេញ " ក្នុងការសរសេរនិក្ខេបបទ ត្រូវការសម្ភាសន៍ និងប្រមូលទិន្នន័យពីគ្រូបង្រៀនឯកទេសភាសាអង់គ្លេសកំពុងបង្រៀនថ្នាក់ទី ១០ ដល់ទី១២ នៅតាមបណ្តាវិទ្យាល័យ ក្នុងខេត្ត ។ កាលបរិច្ឆេទសម្ភាសន៍ និងប្រមូលទិន្នន័យ (តាមរយៈប្រព័ន្ធអនឡាញ) ចាប់ពីថ្ងៃទី ០៥ ខែកក្កដា ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២១ ។

អាស្រ័យហេតុនេះ សូមលោកនាយកជ្រាប និងផ្សព្វផ្សាយដល់គ្រូបង្រៀនពាក់ព័ន្ធ ចូលរួមសហការផ្តល់សម្ភាសន៍ជាមួយលោក រស់ សុភាន់ តាមការគួរ ។

សូមលោកនាយក ទទួលនូវការរាប់អានពីខ្ញុំ ។

ចម្លងជូន៖

-រដ្ឋបាលក្រុង/ស្រុក

"ដើម្បីជ្រាប និងសហការ"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-ឯកសារ -កាលប្បវត្តិ

ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត

ប៊ិច តេជា

អាសយដ្ឋានៈ ក្រុងសំរោង ខេត្តឧត្តរមានជ័យ កម្ពុជា

អ៊ីមែល: oddarmeanchheay@moeys.gov.kh

ទូរស័ព្ទ: 099 847 823 / 012 313 653

គេហទំព័រ: www.moeys.gov.kh

CS Scanned with CamScanner